ELECTRICITE DU CAMBODGE



# របាយការណ៍ប្រចាំឆ្នាំ ២០១៧

យើងប្តេជ្ញា នឹងផ្តល់ជូននូវទំនុកចិត្ត
និងសេវាកម្មដ៏ល្អបំផុត

# សារពី

# ប្រធានក្រុមប្រឹក្សាភិបាល



តាងនាមឲ្យក្រុមប្រឹក្សាភិបាល ខ្ញុំសូមសំដែងនូវការកោតសរសើរយ៉ាងស្មោះចំពោះអគ្គិសនីកម្ពុជា ដែលបានបញ្ចេញនូវរបាយការណ៍ប្រចាំឆ្នាំ២០១៧។ យើងមានមោទនភាព និងការកោតសរសើរចំពោះលទ្ធផល ដែលអគ្គិសនីកម្ពុជាសម្រេចបានក្នុងអំឡុងឆ្នាំ ២០១៧ និងជឿជាក់យ៉ាងមុតមាំថា អគ្គិសនីកម្ពុជានឹងឈានឆ្ពោះទៅកាន់ការសម្រេចបាននូវគោលដៅ និងចក្ខុវិស័យរបស់ខ្លួនក្នុងគោលបំណង ដើម្បីក្លាយជាក្រុមហ៊ុនឈានមុខគេលើវិស័យថាមពលនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយកសាងទំនាក់ទំនង និងសេវាកម្មល្អប្រកបដោយទំនុកចិត្តក្នុងការផ្គត់ផ្គង់អគ្គិសនីឲ្យបានគ្រប់គ្រាន់ និងតម្លៃសមរម្យជូនអតិថិជនរបស់ខ្លួន។

ក្នុងនាមជាប្រធានក្រុមប្រឹក្សាភិបាល ខ្ញុំមានសេចក្ដីពេញចិត្តយ៉ាងខ្លាំង ចំពោះភាពជោគជ័យ ដ៏ធំធេងដែលនិយោជិត និងថ្នាក់ដឹកនាំអគ្គិសនីកម្ពុជាសម្រេចបានក្នុងឆ្នាំកន្លងមក។ សមិទ្ធផលដែលកើតមានជាបន្តបន្ទាប់នាប៉ុន្មានឆ្នាំកន្លងមកនេះ គឺជាសមិទ្ធផលដែលមិនធ្លាប់មានពីមុនមក។

ក្នុងឱកាសនេះ ខ្ញុំសូមសំដែងនូវអំណរគុណអស់ពីដួងចិត្ត ចំពោះថ្នាក់ដឹកនាំ និងនិយោជិតអគ្គិសនីកម្ពុជាទាំងអស់ ដែលបានបំពេញការងារអស់ពីកម្លាំងកាយ និងបញ្ញាស្មារតីដែលធ្វើឲ្យសម្រេចបាននូវសមិទ្ធផលជាច្រើនកន្លងមក ដើម្បីឈានដល់ទិសដៅ និងចក្ខុវិស័យរបស់ខ្លួន។

**ប្រធានក្រុមប្រឹក្សាភិបាល**



**ទិចឆ័រ ហ្សូនា**

# សារពីប្រតិភូរាជរដ្ឋាភិបាលកម្ពុជា
## ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា



**ឯកឧត្តម កែវ រតនៈ**

អគ្គនាយកអគ្គិសនីកម្ពុជា

ខ្ញុំមានមោទនភាព សូមបង្ហាញជូននូវរបាយការណ៍ប្រចាំឆ្នាំ២០១៧ ដែលអគ្គិសនីកម្ពុជាទទួលបាន ដែលជាចំណុចរបត់ថ្មីមួយទៀត នៃការអភិវឌ្ឍន៍វិស័យថាមពល ក្នុងព្រះរាជាណាចក្រកម្ពុជា។ ចក្ខុវិស័យ របស់អគ្គិសនីកម្ពុជាគឺធ្វើយ៉ាងណាឲ្យក្លាយជាអង្គភាពអគ្គិសនីឈានមុខគេនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយត្រូវខិតខំយ៉ាងខ្លាំងក្នុងការបំពេញតម្រូវការប្រើប្រាស់ថាមពលអគ្គិសនី នឹងធ្វើឲ្យប្រសើរឡើងនូវគុណភាព និងប្រសិទ្ធភាពនៃការផ្គត់ផ្គង់ ។ នេះក៏ជាឆ្នាំនៃការខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លា ដើម្បីពង្រឹងបន្ថែមផ្នែកសេវាកម្មរបស់យើងជូនអតិថិជន។

ក្នុងឆ្នាំ២០១៧ ការលក់ថាមពលអគ្គិសនីរបស់អគ្គិសនីកម្ពុជា បានកើនឡើងដល់ ៦.៩៩៤ ជីហ្គាវ៉ាត់ ម៉ោង (GWh) ឬ ១៤,៤៥% ច្រើនជាងឆ្នាំមុន ។ ការបាត់បង់លើប្រព័ន្ធទាំងមូលក្នុងឆ្នាំ២០១៧ មកត្រឹម ៨% ។ ចំណូលប្រចាំឆ្នាំមានការកើនឡើងដល់ ៤.៦៧៩ ប៊ីលានរៀល ឬ ១០,៥% ច្រើនជាងឆ្នាំមុន។ អគ្គិសនីកម្ពុជាមាននិយោជិតសរុបចំនួន ៥.០៨៧ នាក់ សម្រាប់បម្រើសេវាកម្មជូនអតិថិជនចំនួន ៩៨៧.៣៤៦។

ម៉ាស៊ីនទី១ អានុភាព ៥០ មេហ្គាវ៉ាត់ ក្នុងចំណោមអានុភាពសរុបប្រមាណ ៤០០ មេហ្គាវ៉ាត់នៃរោងចក្រវារីអគ្គិសនីសេសានក្រោម២ បានដាក់ឲ្យដំណើរការនៅចុងឆ្នាំ២០១៧។ ស្របពេលនោះដែរ ខ្សែបញ្ជូនតង់ស្យុង ២៣០ kV ពីអនុស្ថានីយកំពង់ចាម ទៅអនុស្ថានីយក្រចេះ និងភ្ជាប់បន្តទៅអនុស្ថានីយស្ទឹងត្រែង បានដាក់ឲ្យដំណើរការ ដើម្បីបញ្ជូនថាមពលដោយផ្ទាល់ពីរោងចក្រវារីអគ្គិសនីសេសានក្រោម២មកប្រព័ន្ធបណ្តាញជាតិ ដែលអនុញ្ញាតឲ្យខេត្តក្រចេះនិងខេត្តស្ទឹងត្រែងមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការស្រូបថាមពលដោយផ្ទាល់ ពីបណ្តាញជាតិ។

ថាមពលកកើតឡើងវិញ បានក្លាយជាមុខព្រួញក្នុងការអភិវឌ្ឍន៍វិស័យថាមពលនៅកម្ពុជា ដោយមានការយកចិត្តទុកដាក់ខ្ពស់ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីជំរុញការផលិតថាមពលកកើតឡើងវិញ(ថាមពលស្អាត)ឲ្យមានភាគរយខ្ពស់ក្នុងប្រព័ន្ធបណ្តាញជាតិ ។ គម្រោងសាកល្បងនៃថាមពលពន្លឺព្រះអាទិត្យ នៅទីក្រុងបាវិត ខេត្តស្វាយរៀងបានដាក់ឲ្យដំណើរការលើផ្ទៃដីប្រមាណ ២១ ហិកតា មានអានុភាព ១០ មេហ្គាវ៉ាត់។ គម្រោងនេះបានបើកសករាជថ្មី នៃការអភិវឌ្ឍន៍ថាមពលកកើតឡើងវិញនៅកម្ពុជា ក៏ដូចជាការចូលរួមចំណែក កាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និងការអភិវឌ្ឍន៍វិស័យថាមពលប្រកបដោយចីរភាព។

ក្រៅពីខ្សែបញ្ជូនតង់ស្យុង ២៣០ គីឡូវ៉ុល ភ្ជាប់ពីខេត្តកំពង់ចាម ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ក៏មានខ្សែបញ្ជូនតង់ស្យុង ១១៥ គីឡូវ៉ាត់ មួយខ្សែទៀតត្រូវបានដាក់ឲ្យដំណើរការក្នុងឆ្នាំ ២០១៧ ដើម្បីផ្តល់ឲ្យតំបន់មួយចំនួននូវការផ្គត់ផ្គង់អគ្គិសនី ដែលភ្ជាប់ចេញពីប្រភពបណ្តាញជាតិ។ ខ្សែបញ្ជូនអគ្គិសនីតង់ស្យុង ១១៥គីឡូវ៉ុល ដែលមានប្រវែងប្រមាណ ៦០គីឡូម៉ែត្រ ដែលភ្ជាប់ពីព្រំដែនឡាវ មកខេត្តព្រះវិហារ ត្រូវបានដាក់ឲ្យដំណើរការនៅឆ្នាំ២០១៧ ក្នុងការនាំយកថាមពលអគ្គិសនីពីប្រទេសឡាវ មកផ្គត់ផ្គង់នៅខេត្តព្រះវិហារ ព្រមទាំងផ្នែកមួយចំនួននៃខេត្តកំពង់ធំ និងខេត្តស្ទឹងត្រែង។ នេះគឺជាការបើកទំព័រប្រវត្តិសាស្ត្រថ្មីនៃការធ្វើពាណិជ្ជកម្មថាមពលរវាងប្រទេសទាំងពីរ ក្នុងការនាំថាមពលអគ្គិសនីក្នុងកម្រិតតង់ស្យុងខ្ពស់ ១១៥ គីឡូវ៉ុល ជាលើកដំបូងពីប្រទេសឡាវ។ ការដាក់ឲ្យដំណើរការខ្សែបញ្ជូនតង់ស្យុងខ្ពស់ ១១៥ គីឡូវ៉ុល ពីអនុស្ថានីយសៀមរាប ទៅអនុស្ថានីយថ្មីខាងកើតសៀមរាប បានបង្កើននូវការផ្គត់ផ្គង់បន្ថែមក្នុងខេត្តនេះផងដែរ។ ខ្សែបញ្ជូនតង់ស្យុង ១១៥ គីឡូវ៉ុល ពីអនុស្ថានីយទី៧ ក្នុងរាជធានីភ្នំពេញទៅខេត្តព្រៃវែង និងក្រុងបាវិតក្នុងខេត្តស្វាយរៀង បានធ្វើឲ្យខេត្តទាំងពីរ មានលទ្ធភាពគ្រប់គ្រាន់ក្នុងការទទួលថាមពលអគ្គិសនីពីបណ្តាញជាតិ។ ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ១១៥គីឡូវ៉ុល ពីខេត្តបាត់ដំបងទៅស្រុករតនមណ្ឌលបានបញ្ចប់ការសាងសង់ជាស្ថាពរ ដែលវាជាផ្នែកមួយនៃខ្សែបញ្ជូនពីខេត្តបាត់ដំបងទៅខេត្តប៉ៃលិន។

អំឡុងឆ្នាំ២០១៧ ចំនួននៃគម្រោងខ្សែបញ្ជូនជាច្រើនកំពុងស្ថិតក្រោមការសាងសង់ ដែលនៅពេលគម្រោងទាំងអស់នោះ ត្រូវបានបញ្ចប់ជាស្ថាពរ យើងនឹងអាចធានាបាននូវការផ្គត់ផ្គង់ថាមពលអគ្គិសនីប្រកបដោយនិរន្តរភាព និងស្ថិរភាព ដែលអាចទទួលយកបានសម្រាប់តំបន់ភ្ជាប់ថាមពលអគ្គិសនីថ្មី និងតំបន់ដែលមានអគ្គិសនីពីបណ្តាញជាតិ។ គម្រោងខ្សែបញ្ជូនកំពុងសាងសង់សំខាន់ៗរួមមាន៖ (១) គម្រោងខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០ គីឡូវ៉ុល ជុំវិញបឹងទន្លេសាប ដែលគ្របដណ្តប់លើខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តកំពង់ធំ និងខេត្តកំពង់ចាម (២) ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ១១៥ គីឡូវ៉ុលពី អនុស្ថានីយកំពង់ធំ ទៅអនុស្ថានីយខេត្តព្រះវិហារទី១ (៣) ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ១១៥ គីឡូវ៉ុលពី អនុស្ថានីយកំពង់សឺង្គ ទៅអនុស្ថានីយស្វាយអន្ទរ (៤) ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ១១៥ គីឡូវ៉ុលពី អនុស្ថានីយខេត្តព្រះសីហនុ ទៅអនុស្ថានីយរាម (៥) ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០ គីឡូវ៉ុលពីស្ទឹងត្រែង ទៅរតនគិរី (៦) ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០ គីឡូវ៉ុលពីក្រចេះ ទៅមណ្ឌលគិរី។

# សារពីប្រតិភូរាជរដ្ឋាភិបាលកម្ពុជា
## ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា (ត)

ហិរញ្ញប្បទានទាំងនោះ ត្រូវបានអនុម័តដោយធនាគារ ចិនអាហរណ៍និហរណ៍ សម្រាប់ការសាងសង់ខ្សែបណ្ដាញចែកចាយលើសពី ២០៤០គីឡូម៉ែត្រ ក្នុងខេត្ត-ក្រុង ចំនួន ១៤។

គិតត្រឹមចុងឆ្នាំ២០១៧ កិច្ចព្រមព្រៀងទិញ-លក់ថាមពលអគ្គិសនីចំនួន ២៣៨ ត្រូវបានចុះហត្ថលេខារវាងអគ្គិសនីកម្ពុជា និងសហគ្រាសអគ្គិសនីជនបទ (REEs) ឬ សេវាករ ដែលជាអ្នកផ្ដល់សេវាកម្មចែកចាយអគ្គិសនី ដើម្បីទទួលបានការផ្គត់ផ្គង់អគ្គិសនី ចេញពីបណ្ដាញជាតិ ដែលជាហេតុនាំឲ្យមានការបញ្ឈប់ដំណើរការម៉ាស៊ីនភ្លើងតូចៗ ដែលជាប្រភពប្រើប្រាស់ប្រេងមានតម្លៃខ្ពស់។

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៥-២០២០ ដោយមាន ៖ ១-គោលដៅគ្រប់ដណ្ដប់ លើតំបន់ផ្គត់ផ្គង់អគ្គិសនីទាំងឡាយ ដែលមានប្រភពអគ្គិសនីពីប្រព័ន្ធបណ្ដាញជាតិដើម្បីបន្ថយអត្រាថ្លៃលក់អគ្គិសនីទូទៅឲ្យមានអត្រាតម្លៃប្រហាក់ប្រហែលគ្នារវាងទីប្រជុំជន និងជនបទ។ ២-អ្នកប្រើប្រាស់មានជីវភាពទាបនៅតំបន់ជនបទប្រើប្រាស់អគ្គិសនីតិចតួច ។ ៣-ការផ្គត់ផ្គង់អគ្គិសនីសម្រាប់បូមទឹកធ្វើកសិកម្ម នូវតម្លៃអនុគ្រោះសម្រាប់ការប្រើប្រាស់អគ្គិសនីនៅពេលយប់ចាប់ពីម៉ោង ៩យប់ ដល់ម៉ោង ៧ព្រឹក។ ផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីនេះ ចាប់ផ្ដើមអនុវត្តលើថាមពលអគ្គិសនី ដែលប្រើប្រាស់នៅខែមីនា ឆ្នាំ២០១៧។

ផែនការកាត់បន្ថយអត្រាថ្លៃលក់ថាមពលអគ្គិសនី ត្រូវបានដាក់ឲ្យអនុវត្តចាប់តាំងពីខែមីនា ឆ្នាំ ២០១៦ ។ អគ្គិសនីកម្ពុជា បានផ្ដល់ថវិកាចំនួន ៥២ លានដុល្លារអាមេរិក និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ (KfW) ចំនួន ២,៦ លានដុល្លារអាមេរិក (សរុបចំនួន ៥៤,៦ លានដុល្លារអាមេរិក) សម្រាប់ប្រតិបត្តិការរបស់មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ (ម.អ.ជ) ដើម្បីអនុវត្តន៍ផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជាពីឆ្នាំ ២០១៥-២០២០ ដើម្បីបន្តការជំរុញ និងអភិវឌ្ឍន៍វិស័យអគ្គិសនីភាវូបនីយកម្មជនបនៅទូទាំងប្រទេស។



អគ្គិសនីកម្ពុជា បានបង្កើតនូវប្រព័ន្ធទូរស័ព្ទទំនាក់ទំនង ២៤ម៉ោង Hotline (២៤ម៉ោង / ៧ថ្ងៃ) និងបណ្ដាញសង្គមហ្វេសប៊ុកផ្លូវការ " **អគ្គិសនីកម្ពុជា**-EDC " ក្នុងការផ្ដល់និងទទួលព័ត៌មានសំខាន់ៗ ដើម្បីបង្កើនប្រសិទ្ធភាព ក្នុងការបម្រើសេវាអតិថិជន ព្រមទាំងផ្ដល់ព័ត៌មានសំខាន់ៗ និងសេចក្ដីជូនដំណឹងទាន់ហេតុការណ៍ជូនអតិថិជន។

លទ្ធផលនៃកិច្ចខំប្រឹងប្រែងខាងលើ បានផ្ដល់នូវប្រយោជន៍ដោយផ្ទាល់ និងដោយប្រយោលជាច្រើនជូនដល់ប្រជាជនរាប់លានគ្រួសារ និងក្រុមហ៊ុនពាណិជ្ជកម្មទូទាំងប្រទេស ដែលប្រការទាំងនេះ បានឆ្លុះបញ្ចាំងឲ្យឃើញពីភាពរឹងមាំ និងការរីកចម្រើនយ៉ាងពិតប្រាកដក្នុងការរួមចំណែកការអភិវឌ្ឍន៍ប្រទេសកម្ពុជា ដើម្បីស្ថាបនាបាននូវគ្រឹះដ៏រឹងមាំសម្រាប់កិច្ចអភិវឌ្ឍន៍ឲ្យមាននិរន្តរភាពសេដ្ឋកិច្ច និងសង្គមជាតិ។

ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំសូមធ្វើការកត់សម្គាល់ពីការចូលរួមចំណែក និងការប្ដេជ្ញាចិត្តដ៏មោះមុត របស់និយោជិតយើងទាំងអស់គ្នា ដែលបានដើរតួនាទីដ៏សំខាន់ និងមិនអាចខ្វះបានក្នុងការសម្រេចបានជោគជ័យជូនអង្គភាព ។ យើងខ្ញុំសូមសម្ដែងនូវកត្តញ្ញូដ៏ជ្រាលជ្រៅ ចំពោះការណែនាំដ៏មានសារៈសំខាន់ប្រកបដោយគតិបណ្ឌិតរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលសម្ដេចតែងផ្ដល់ការគាំទ្រជាគន្លឹះៗ នៅគ្រប់របត់សំខាន់ៗទាំងអស់។

យើងខ្ញុំសូមសម្ដែងនូវការដឹងគុណ ចំពោះក្រសួង រ៉ែ និង ថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានបន្តចង្អុលបង្ហាញទិសដៅ និងគាំទ្រយ៉ាងខ្លាំងក្លា។ យើងខ្ញុំសូមសំដែងនូវសេចក្ដីសោមនស្សរីករាយ ជាពិសេសជូនដល់អាជ្ញាធរអគ្គិសនីកម្ពុជា



និងចំពោះសមាជិកក្រុមប្រឹក្សាភិបាលអគ្គិសនីកម្ពុជា សម្រាប់ការចូលរួមចំណែក ការគាំទ្រ និងការណែនាំកន្លងមក ។ យើងខ្ញុំសូមវាយតម្លៃយ៉ាងខ្ពស់ផងដែរ  ចំពោះការគាំទ្រពីសំណាក់អតិថិជនគ្រប់ប្រភេទរបស់អគ្គិសនីកម្ពុជា។ ជាងនេះទៅទៀត យើងខ្ញុំសូមសម្តែងនូវការកោតសរសើរ ចំពោះដៃគូអភិវឌ្ឍន៍នានា ជាពិសេសធនាគារចិនអាហារណែនីហរណែរបស់សាធារណៈរដ្ឋប្រជាមានិតចិន  និងដៃគូផលិតករថាមពលឯករាជ្យទាំងអស់។ ជាមួយការរីកចម្រើននេះ អគ្គិសនីកម្ពុជាកំពុងបោះជំហានទៅមុខ ប្រកបដោយសុទិដ្ឋិនិយមក្នុងបេសកកម្មរបស់ខ្លួនដ៏ប្រសើរ ដើម្បីជួយអភិវឌ្ឍវិស័យថាមពលក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**



**កែវ រតនៈ**





# មាតិកា


**អំពីយើង**

| | |
|---|---|
| ការវិវឌ្ឍន៍របស់អគ្គិសនីកម្ពុជា | ៨ |
| ចក្ខុវិស័យ | ១០ |
| ទស្សនវិស័យ | ១០ |
| តួនាទី និងការទទួលខុសត្រូវ | ១០ |
| រចនាសម្ព័ន្ធគ្រប់គ្រង | ១២ |

**ចំណុចសំខាន់ៗផ្នែកហិរញ្ញវត្ថុ**

| | |
|---|---|
| តារាងតុល្យការ និងលំហូរសាច់ប្រាក់ | ១៤ |

**ការអភិវឌ្ឍន៍ធនធានមនុស្ស**

| | |
|---|---|
| ការបណ្តុះបណ្តាលចំណេះដឹងក្នុងស្រុក | ២១ |
| ការបណ្តុះបណ្តាលចំណេះដឹងក្រៅប្រទេស | ២២ |

**អាជីវកម្មស្នូល**

| | |
|---|---|
| ប្រភពផលិតកម្ម | ២៦ |
| តម្រូវការថាមពល និងការផ្គត់ផ្គង់អគ្គិសនីនៅក្នុងបណ្តាញជាតិ | ២៦ |
| បណ្តាញខ្សែបញ្ជូន | ៤៨ |
| បណ្តាញខ្សែចែកចាយ | ៥២ |

**មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទនៃអគ្គិសនីកម្ពុជា**

| | |
|---|---|
| ការបង្កើតស្ថាប័ន មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ(ម.អ.ជ) | ៥៨ |
| សកម្មភាពការងារដែល ម.អ.ជ សម្រេចបាន | ៥៨ |

**ផែនការអភិវឌ្ឍន៍ និងយុទ្ធសាស្ត្រលើវិស័យថាមពលអគ្គិសនី**

| | |
|---|---|
| គោលនយោបាយអភិវឌ្ឍន៍វិស័យថាមពល | ៦២ |
| ការព្យាករណ៍តម្រូវការថាមពល | ៦២ |
| ផែនការមេនៃការផលិតថាមពល និងប្រព័ន្ធខ្សែបញ្ជូន | ៦២-៦៣ |

**កិច្ចសហប្រតិបត្តិការជាមួយប្រទេសក្នុងតំបន់**

| | |
|---|---|
| ការភ្ជាប់បណ្តាញអគ្គិសនីជាមួយប្រទេសថៃឡង់ដ៍ | ៦៨ |
| ការភ្ជាប់បណ្តាញអគ្គិសនីជាមួយប្រទេសឡាវ | ៦៨ |
| ការភ្ជាប់បណ្តាញអគ្គិសនីជាមួយប្រទេសវៀតណាម | ៦៩ |
| ការតភ្ជាប់បណ្តាញអនុតំបន់ | ៦៩ |

**ទំនួលខុសត្រូវរបស់អគ្គិសនីកម្ពុជាចំពោះសង្គម**

| | |
|---|---|
| ការចុះជួយឧបត្ថម្ភកងទ័ព | ៧០ |
| ការងារមនុស្សធម៌ | ៧០ |
| ការចូលរួមលើកកម្ពស់វិស័យអប់រំ និងបណ្តុះបណ្តាលធនធានមនុស្ស | ៧១ |
| ការការពារបរិស្ថាន | ៧១ |

# ការវិវឌ្ឍន៍របស់អគ្គិសនីកម្ពុជា

ការប្រើប្រាស់អគ្គិសនី មានវត្តមាននៅប្រទេសកម្ពុជា ក្នុងឆ្នាំ១៩០៦ ។ មុនខែ តុលា ឆ្នាំ១៩៥៨ ថាមពលអគ្គិសនី និង ការប្រើប្រាស់សម្រាប់បំភ្លឺផ្សេងៗនៅប្រទេសកម្ពុជា ត្រូវបានផ្គត់ផ្គង់ដោយក្រុមហ៊ុនឯកជនចំនួន ០៣ ៖

- ក្រុមហ៊ុនទឹក និងអគ្គិសនី ហៅកាត់ថា CEE
- សហព័ន្ធអគ្គិសនីឥណ្ឌូចិន ហៅកាត់ថា UNEDI
- ក្រុមហ៊ុនអគ្គិសនីបារាំង-ខ្មែរ ហៅកាត់ថា CFKE




ក្រុមហ៊ុនទឹក និងអគ្គិសនី (CEE) បានបម្រើសេវាអគ្គិសនីយ៉ាងធំនៅតំបន់ទីក្រុងភ្នំពេញ។ សហព័ន្ធអគ្គិសនីឥណ្ឌូចិន (UNEDI) ទទួលខុសត្រូវគ្រប់បណ្តាខេត្តផ្សេងៗទាំងអស់លើកលែងតែខេត្តបាត់ដំបង ដែលត្រូវបានផ្គត់ផ្គង់អគ្គិសនីដោយក្រុមហ៊ុនអគ្គិសនីបារាំង-ខ្មែរ (CFKE)។

យោងតាមក្រឹត្យលេខ ៦៦៥-NS ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៥៨ ក្រុមហ៊ុនចំនួនពីរគឺក្រុមហ៊ុនទឹក និងអគ្គិសនី (CEE) និងសហព័ន្ធអគ្គិសនីឥណ្ឌូចិន (UNEDI) បានដាក់បញ្ចូលគ្នា ដោយដាក់ឈ្មោះថា **អគ្គិសនីកម្ពុជា** ។

អំឡុងឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៩ វិស័យថាមពលអគ្គិសនីនៅក្នុងប្រទេសបានឆ្លងកាត់ព្រឹត្តិការណ៍ចំនួនពីរ ដែលទទួលរងគ្រោះថ្នាក់ដោយសារ ៖ សង្គ្រាមស៊ីវិល (ពីឆ្នាំ១៩៧០-១៩៧៥) និងមានភាពចលាចល ជាប្រវត្តិសាស្ត្រ អំឡុងរបបខ្មែរក្រហម (ពីឆ្នាំ១៩៧៥-១៩៧៩)។ អំឡុងពេលនោះ មធ្យោបាយនៃការផលិត ការបញ្ជូន និងការចែកចាយ គ្រប់ប្រភេទទាំងអស់ត្រូវបានបំផ្លាញ មិនត្រឹមតែនៅរាជធានីភ្នំពេញទេ ប៉ុន្តែថែមទាំងនៅតំបន់ដទៃៗទៀតទូទាំងប្រទេសផងដែរ។

នៅឆ្នាំ១៩៧៩ អគ្គិសនីកម្ពុជាត្រូវបានបង្កើតឡើងវិញ ដោយរចនាសម្ព័ន្ធរដ្ឋបាល ស្ថិតក្រោមការគ្រប់គ្រង របស់ក្រសួងឧស្សាហកម្ម។ នៅឆ្នាំ ១៩៩១ អគ្គិសនីកម្ពុជា ត្រូវបានផ្ទេរឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់សាលារាជធានីភ្នំពេញដោយដាក់ឈ្មោះថា **អគ្គិសនីភ្នំពេញ** ហើយមានភារកិច្ចផ្គត់ផ្គង់អគ្គិសនីនៅរាជធានីភ្នំពេញ ទន្ទឹមនឹងនោះការផ្គត់ផ្គង់អគ្គិសនីនៅតាមបណ្តាខេត្តទាំងអស់ ត្រូវបានគ្រប់គ្រងដោយមន្ទីរឧស្សាហកម្មខេត្ត។

នៅឆ្នាំ ១៩៩២ អគ្គិសនីភ្នំពេញ ត្រូវបានផ្ទេរឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម ដោយប្តូរឈ្មោះជាថ្មីទៅជា **អគ្គិសនីកម្ពុជា** វិញ ។ ក្រោយការបោះឆ្នោតជាសកលនៅឆ្នាំ១៩៩៣ អគ្គិសនីកម្ពុជា ត្រូវបានធ្វើកំណែទម្រង់ឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ហើយទទួលខុសត្រូវសម្រាប់ការផ្គត់ផ្គង់ថាមពលអគ្គិសនីនៅរាជធានីភ្នំពេញ។ ចំណែកឯ អង្គភាពបម្រើសេវាកម្មថាមពលអគ្គិសនីនៅតាមបណ្តាខេត្តមួយចំនួន នៅតែស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរខេត្តប៉ុន្តែទទួលការឧបត្ថម្ភថវិកាតាមរយៈក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។



នៅខែមីនា ឆ្នាំ១៩៩៦ តាមព្រះរាជក្រឹត្យលេខ ០៣៩៦/១០ អគ្គិសនីកម្ពុជាបានក្លាយជាក្រុមហ៊ុនស្វយ័ត ទទួលខុសត្រូវមានកំណត់មួយជាកម្មសិទ្ធិរបស់រដ្ឋទាំងស្រុងដែលមានកាតព្វកិច្ចក្នុងការផលិត បញ្ជូន និងចែកចាយថាមពលអគ្គិសនីទូទាំងព្រះរាជាណាចក្រកម្ពុជា ។ អគ្គិសនីកម្ពុជាជាស្ថាប័នមួយស្របច្បាប់ ដោយមានស្វ័យភាពនៃការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ។ អគ្គិសនីកម្ពុជា ទទួលខុសត្រូវចំពោះប្រាក់ចំណេញប្រាក់ខាតបង់ និងទទួលសងបំណុលទៅតាមទំហំនៃតម្លៃទ្រព្យសម្បត្តិរបស់ខ្លួន។

# អង្គភាពលេខ និងរចនាសម្ព័ន្ធគ្រប់គ្រង អគ្គិសនីកម្ពុជា



## ១ ចក្ខុវិស័យ

ចក្ខុវិស័យរបស់អគ្គិសនីកម្ពុជា គឺធ្វើយ៉ាងណាឲ្យក្លាយជាអង្គភាពអគ្គិសនីឈានមុខគេ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយត្រូវខិតខំយ៉ាងខ្លាំង ក្នុងការបំពេញតម្រូវការប្រើប្រាស់ថាមពលអគ្គិសនី នឹងធ្វើឲ្យប្រសើរឡើងនូវគុណភាព និង ប្រសិទ្ធភាពនៃការផ្គត់ផ្គង់ថាមពលអគ្គិសនីជូនអតិថិជន។

## ២ ទស្សនវិស័យ

ផ្តល់ការផ្គត់ផ្គង់អគ្គិសនីឲ្យបានគ្រប់គ្រាន់ ប្រកបដោយស្ថិរភាព គុណភាព ប្រសិទ្ធភាព ជូនអតិថិជននៅក្នុងតំបន់ ដែលមានអាជ្ញាបណ្ណរបស់ខ្លួន ដោយតម្លៃប្រកួតប្រជែង បង្កើនប្រតិបត្តិការអាជីវកម្មឲ្យបានប្រសើរបំផុត និងប្រកបដោយប្រសិទ្ធភាព និងឧត្តមភាព នឹងចូលរួមអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីកាត់បន្ថយភាពក្រីក្រ ការពារបរិស្ថាន និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមជាតិ។

## ៣ តួនាទី និងការទទួលខុសត្រូវ



អគ្គិសនីកម្ពុជាមានសិទ្ធិ និងការទទួលខុសត្រូវចំពោះការផលិត បញ្ជូន និងចែកចាយថាមពលអគ្គិសនីទូទាំងព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមកាតព្វកិច្ចនៃការធ្វើពាណិជ្ជកម្មរបស់ខ្លួន ដែលមានចែងនៅក្នុងច្បាប់លក្ខន្តិកៈ អាជ្ញាបណ្ណ និងបទបញ្ញត្តិដទៃទៀតរបស់រាជរដ្ឋាភិបាលកម្ពុជា។

អគ្គិសនីកម្ពុជា ប្រតិបត្តិជាសហគ្រាសពាណិជ្ជកម្មមួយ មានឯករាជ្យភាព ក្នុងការរៀបចំអាជីវកម្មរបស់ខ្លួនលើការផលិតបញ្ជូន និងចែកចាយថាមពលអគ្គិសនី ព្រមទាំងបង្កើតទុនវិនិយោគ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និងមានការទទួលខុសត្រូវលើចំណូលចំណាយ។

អគ្គិសនីកម្ពុជាត្រូវអនុវត្តន៍តាមលក្ខខណ្ឌរបស់អាជ្ញាបណ្ណចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីផ្តល់សេវាកម្មអគ្គិសនី។ អគ្គិសនីកម្ពុជា ត្រូវអនុវត្តន៍ នឹងធ្វើឲ្យសម្រេចនូវផែនការអាជីវកម្មរបស់ខ្លួន ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាលអគ្គិសនីកម្ពុជា និងអនុលោមតាមគោលនយោបាយថាមពលអគ្គិសនីជាតិ និងផែនការអភិវឌ្ឍន៍ជាតិ ។

អគ្គិសនីកម្ពុជា ត្រូវកំណត់សកម្មភាពអាជីវកម្ម ដែលមានចែងនៅក្នុងលក្ខន្តិកៈ និងអាជ្ញាបណ្ណ ដែលបានអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា។

អគ្គិសនីកម្ពុជា ត្រូវបានអនុញ្ញាតលើការទទួលខុសត្រូវចំពោះ ៖

១- ការផលិត ការបញ្ជូន និងការបែងចែកថាមពលអគ្គិសនី ក្នុងគោលបំណង ដើម្បីឆ្លើយតបតាមតម្រូវការថាមពលរបស់អ្នកជាវគ្រប់ប្រភេទ។

២- នាំចូល និងនាំចេញថាមពលអគ្គិសនីជាមួយប្រទេសជិតខាង។

៣- ការសាងសង់ និងដាក់ឲ្យដំណើរការបណ្តាញជាតិបញ្ជូនអគ្គិសនី ដើម្បីធានានូវការផ្គត់ផ្គង់អគ្គិសនីឲ្យបានគ្រប់គ្រាន់ និងមានគុណភាព។



៤-ការសាងសង់ និងដាក់ឲ្យដំណើរការបណ្តាញបញ្ជូនរង ក្នុងគោលបំណង ចែកចាយអគ្គិសនី និងផ្គត់ផ្គង់ដល់តំបន់គ្រប់គ្រងដោយអគ្គិសនីកម្ពុជា និងតំបន់ដទៃទៀត។

៥-លក់ថាមពលអគ្គិសនី និងការបម្រើសេវាកម្មដែលពាក់ព័ន្ធ ។

៦-ទិញថាមពល ការបញ្ជូនថាមពល និងការទិញ-លក់ថាមពលរវាងអគ្គិសនីកម្ពុជានិងដៃគូអ្នកផលិតថាមពលឯករាជ្យផ្សេងៗ។

អគ្គិសនីកម្ពុជា បានប្រភពទុនមកពី ៖

១- ការផ្តល់ជំនួយពីរាជរដ្ឋាភិបាលកម្ពុជា ។

២- អចលនទ្រព្យ និងដីធ្លីទាំងឡាយ ដែលត្រូវបានផ្ទេរជូនអគ្គិសនីកម្ពុជា ដោយរាជរដ្ឋាភិបាលកម្ពុជា ដូចមាននៅក្នុងមាត្រា ៧ នៃអនុក្រឹត្យលេខ ២៣។

៣- ប្រាក់ចំណូល ដោយយោងតាមគោលការណ៍គណនេយ្យរបស់អគ្គិសនីកម្ពុជា ។

៤- ការផ្តល់ហិរញ្ញប្បទានឥតសំណង និងហិរញ្ញប្បទានឥណទានផ្សេងៗ ដែលអគ្គិសនីកម្ពុជាទទួលបាន ដោយមានការអនុម័តពីរាជរដ្ឋាភិបាលកម្ពុជា ។

៥-ការផ្តល់ឥណទានដល់អគ្គិសនីកម្ពុជាពីប្រភពហិរញ្ញវត្ថុផ្សេងៗ ដែលត្រូវអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា។

# រចនាសម្ព័ន្ធគ្រប់គ្រង



**ឯកឧត្តម វិចច័រ ហ្សូនា**
ប្រធាន
តំណាង ក្រសួងរ៉ែ និងថាមពល

## ១ ក្រុមប្រឹក្សាភិបាល



**ឯកឧត្តម ហែម ក្រាញ់ តូនី**
សមាជិក
តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី



**ឯកឧត្តម ចាន់ សុធី**
សមាជិក
តំណាង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



**ឯកឧត្តម កែវ រតនៈ**
សមាជិក
ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា
ទទួលបន្ទុកជា
អគ្គនាយកអគ្គិសនីកម្ពុជា

## ២ រចនាសម្ព័នរបស់អគ្គិសនីកម្ពុជា

**បណ្ឌិត ប្រាំង ជលសា**
អគ្គនាយករង
ផែនការ និងបច្ចេកទេស



**លោក ធីង អ៊ីង**
អគ្គនាយករង
ហិរញ្ញកិច្ច-អាជីវកម្ម





**លោក ជុន ពិសិដ្ឋ**
នាយក ផែនការយុទ្ធសាស្ត្រ
និងគម្រោងការ



**លោក អូន ហេមរិទ្ធ**
នាយក ផលិតកម្ម



**លោក អ៊ឹង ប្រសិទ្ធ**
នាយក បញ្ជូនអគ្គិសនី



**លោក ណុប សុភា**
នាយក អាជីវកម្ម-
ចែកចាយ



**កញ្ញា ស៊ិន សុវណ្ណនី**
នាយិកា ហិរញ្ញកិច្ច-
គណនេយ្យ

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ក្រសួង រ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគឺជាម្ចាស់សហកម្មសិទ្ធិលើក្រុមហ៊ុនអគ្គិសនីកម្ពុជា។ អគ្គិសនីកម្ពុជា ត្រូវបានដឹកនាំដោយប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា ដោយមានឋានៈស្មើនឹងរដ្ឋលេខាធិការក្នុងជួររាជរដ្ឋាភិបាល ដែលជាអ្នករាយការណ៍ជូនក្រុមប្រឹក្សាភិបាល និងទទួលរបាយការណ៍ត្រឡប់មកវិញ ដើម្បីរាយការណ៍ជូនទៅរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលទាំងពីរ។ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកអគ្គិសនីកម្ពុជា ត្រូវបានជួយការងារ ដោយអគ្គនាយករងចំនួន ០៤ រូប និងនាយក ចំនួន ១០ រូប ។ ឆ្នាំ២០១៧ ថ្នាក់គ្រប់គ្រងរបស់អគ្គិសនីកម្ពុជា រួមមាន៖



**លោក ហង់ ទូច**
សមាជិក
តំណាងនិយោជិតកម្មករអគ្គិសនីកម្ពុជា



**លោក គី ខេមលីន**
សមាជិក
តំណាង ក្រសួងយុត្តិធម៌



**លោកស្រី សុខ សុធាវី**
សមាជិក
តំណាង សភាពាណិជ្ជកម្មកម្ពុជា



**ឯកឧត្តម អេង គន្ធា**
អគ្គនាយករង
រដ្ឋបាល



**លោក កែវ វីរៈ**
អគ្គនាយករង
មូលនិធិអគ្គិសនីភាវូប-
នីយកម្មជនបទ



**លោក អ៊ុំ ពិសិដ្ឋ**
នាយក វិទ្យាស្ថាន
វិទ្យាសាស្ត្រអគ្គិសនី



**លោក លី ទីយា**
នាយក រដ្ឋបាល



**លោក លឿង កែវសិលា**
នាយក មូលនិធិអគ្គិសនី
ភាវូបនីយកម្មជនបទ



**លោក ង៉ែត សុខន**
នាយក លទ្ធកម្ម



**លោក អៀម វណ្ណថា**
នាយក សវនកម្មផ្ទៃក្នុង

## តារាងតុល្យការហិរញ្ញវត្ថុ របស់អគ្គិសនីកម្ពុជា សម្រាប់ចុងឆ្នាំ២០១៧

| | ២០១៧<br>ពាន់រៀល | ២០១៦<br>ពាន់រៀល |
|---|---|---|
| **ទ្រព្យសកម្ម** | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | |
| ទ្រព្យ រោងចក្រ និងបរិក្ខារ | ៥.៣០៣.២២០.៩៩០ | ៤.១៥៦.៩៦២.៤០៤ |
| ទ្រព្យសកម្មអរូបិយ | ១.៦១៩.៣៤៥ | ៧៥០.៩៣៩ |
| ទ្រព្យសកម្មរយៈពេលវែងផ្សេងៗ | - | - |
| | **៥.៣០៤.៨៤០.៣៣៥** | **៤.១៥៧.៧១៣.៣៤៣** |
| **ទ្រព្យសកម្មចរន្ត** | | |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ១.២៦២.៥០៩.៨៨១ | ១.១១៩.៥៦៧.០៧៥ |
| គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ | ៦៦៥.១០៣.៤៥២ | ៦០៨.៦៦៥.៧៥៣ |
| សន្និធិ | ៣៩៨.៨១១.៧៨៣ | ៣២៦.៣២៣.២៦៨ |
| | ២.៣២៦.៤២៥.១១៦ | ២.០៥៤.៥៥៦.០៩៦ |
| **ទ្រព្យសកម្មសរុប** | **៧.៦៣១.២៦៥.៤៥១** | **៦.២១២.២៦៩.៤៣៩** |
| **មូលធន** | | |
| ដើមទុន | ៨៣៣.៦៩១.៤៦១ | ៧៧២.៩០៦.៤៤១ |
| ប្រាក់ចំណេញរក្សាទុក | ២.៣៦៨.២៧៤.៧៩០ | ១.៩២៧.៥២០.២០៨ |
| | **៣.២០១.៩៦៦.២៥១** | **២.៧០០.៤២៦.៦៤៩** |
| **ទ្រព្យអកម្ម** | | |
| **បំណុលរយៈពេលវែង** | | |
| ប្រាក់កម្ចី | ៣.០៤៤.០១៧.៥៣៣ | ២.៤៣៣.៧១៣.៣១៤ |
| ប្រាក់កក់របស់អតិថិជន | ២៤៦.១០៧.២៥២ | ២១៤.៩១៣.១៧២ |
| សំវិធានធនសម្រាប់សោធននិវត្តន៍ | ៣.៣៩៨.២៦៤ | ៣.៣៤៩.៩៤៧ |
| បំណុលពន្ធពន្យារ, សុទ្ធ | ៤០.៣៥០.៩៥២ | ៣២.៩៩២.២៦៧ |
| | **៣.៣៣៣.៨៧៤.០០១** | **២.៦៨៤.៩៦៨.៧០០** |
| **បំណុលចរន្ត** | | |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ | ៨៦២.៨៩៣.៤៣៧ | ៦៣៤.០២៧.៦៥២ |
| ប្រាក់កម្ចី | ១៧២.១៣៨.៣៦០ | ១០៩.៦៩៣.៥៥៩ |
| ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំត្រូវទូទាត់ | ៦០.៣៩៣.៤០២ | ៨៣.១៥២.៨៧៩ |
| | **១.០៩៥.៤២៥.១៩៩** | **៨២៦.៨៧៤.០៩០** |
| **បំណុល និងមូលធនសរុប** | **៧.៦៣១.២៦៥.៤៥១** | **៦.២១២.២៦៩.៤៣៩** |

## របាយការណ៍លទ្ធផល របស់អគ្គិសនីកម្ពុជា សម្រាប់ចុងឆ្នាំ២០១៧

| | ២០១៧<br>ពាន់រៀល | ២០១៦<br>ពាន់រៀល |
|---|---|---|
| **ចំណូល** | | |
| ចំណូលពីការលក់ថាមពលអគ្គិសនី | ៤.៦២១.៤១៧.៣២២ | ៤.១៨៦.៩៨៦.៧៤៦ |
| ចំណូលពីការតភ្ជាប់បណ្តាញអគ្គិសនី | ៣៥.២៨៤.១៩៩ | ៣១.១១០.៤៧៣ |
| ចំណូលផ្សេងៗ | ២៣.១១៥.៥៣១ | ១៧.៨៣៦.៩៥៧ |
| | **៤.៦៧៩.៨១៧.០៥២** | **៤.២៣៥.៩៣៤.១៧៦** |
| **ចំណាយប្រតិបត្តិការ** | | |
| ការទិញថាមពល | (៣.៣១៤.០៦៣.៩១០) | (២.៩៤៩.៤២១.៦៨៧) |
| ចំណាយថ្លៃប្រេង | (៥.២៧៧.៣៨៣) | (១៨.៣៣២.៨០៨) |
| ចំណាយលើពន្ធនាំចូល | (២៥.៥០០.៣៨៧) | (២៨.០០៥.៣៤២) |
| ចំណាយលើប្រាក់បៀវត្សរ៍ និងអត្ថប្រយោជន៍ផ្សេង | (២២៧.២៦៨.៤៧១) | (១៨៥.៤៤១.១០៩) |
| ចំណាយប្រតិបត្តិការផ្សេងៗ | (៣២៧.៦៧១.៧៩១) | (២៧២.៥៤១.២៨៦) |
| រំលស់លើទ្រព្យរោងចក្រ និងបរិក្ខារ | (១៣៧.៤០៩.៤៧៧) | (១៤១.៣៧៩.០៨១) |
| រំលស់លើទ្រព្យសកម្មអរូបិយ | (៣៧៩.២០៧) | (២៣៣.០៧៧) |
| | | |
| ចំណេញប្រតិបត្តិការ | ៦៤២.២៤៦.៤២៦ | ៦៤០.៥៧៩.៧៨៦ |
| ចំណាយហិរញ្ញវត្ថុ-សុទ្ធ | (៧៦.៣៩២.៥៦៨) | (៤៦.២៩៣.៧៦៥) |
| ប្រាក់ចំណេញមុនដកពន្ធ | ៥៦៥.៨៥៣.៨៥៨ | ៥៩៤.២៨៦.០២១ |
| ពន្ធលើប្រាក់ចំណេញ | (១០១.៣៣៥.៦៦២) | (១១៩.០១២.១៨៤) |
| **ប្រាក់ចំណេញសុទ្ធ<br>សម្រាប់ការិយបរិច្ឆេទ/ចំណូលរួមសរុប** | **៤៦៤.៥១៨.១៩៦** | **៤៧៥.២៧៣.៨៣៧** |

## របាយការណ៍លំហូរសាច់ប្រាក់ របស់អគ្គិសនីកម្ពុជា សម្រាប់ចុងឆ្នាំ២០១៧

| | ២០១៧<br>ពាន់រៀល | ២០១៦<br>ពាន់រៀល |
|---|---|---|
| **លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | |
| **ប្រាក់ចំណេញប្រចាំឆ្នាំ** | **៤៦៤.៥១៨.១៩៦** | **៤៧៥.២៣៧.៨៣៧** |
| និយ័តកម្មលើ: | | |
| ចំណាយរំលស់ | ១៣៧.៧៨៨.៦៨៤ | ១៤១.៦១២.១៥៨ |
| ចំណេញ ឬខាតពីការប្តូររូបិយប័ណ្ណបរទេស | ៣២.៦១៧.៣៦៥ | (២៥.៨០៩.០៨២) |
| ខាតលើការលក់ទ្រព្យ រោងចក្រ និងបរិក្ខារ | ២៥.២៥៦ | ១១.៨១៨.៣៦៧ |
| ចំណាយការប្រាក់ | ៩២.០៧៣.១៦៥ | ៦២.៨៦៣.៨៩៧ |
| ចំណាយលើពន្ធប្រាក់ចំណេញ | ១០១.៣៣៥.៦៦២ | ១១៩.០១២.១៨៤ |
| សំវិធានធនសម្រាប់ | | |
| បន្ថែមលើគណនីអាក្រក់ និងជាប់សង្ស័យ | (១.៧០១.៣១១) | ៣.១៨០.៨៥២ |
| អត្ថប្រយោជន៍ចូលនិវត្តន៍ | ៤៨.៣១៧ | ១៩៩.៧៥៦ |
| សន្និធិខូច | ៦.០៨១.៦៧៣ | ៤.៣៤២.៣០៥ |
| | **៨៣២.៧៨៧.០០៧** | **៧៩២.៤៩៤.២៧៤** |
| ប្រែប្រួលនៃ: | | |
| គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ | (៦៥.០២៥.៧៤៣) | (៨៥.០៤៤.៥៥០) |
| សន្និធិ | (១៩២.៣៧៥.៣៩៣) | (២១៧.១៣៥.០៣៣) |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ | ២០៨.៩៤៨.២៩៦ | ៣.៤៩៩.០៩៧ |
| ប្រាក់កក់របស់អតិថិជន | ៣១.១៩៤.០៨០ | ៣៦.០៤១.៤៩៧ |
| សាច់ប្រាក់សុទ្ធទទួលបានពីប្រតិបត្តិការ | ៨១៥.៥២៨.២៤៧ | ៥២៩.៨៥៥.២៨៥ |
| ការប្រាក់បានបង់ | (៧២.១៥៥.៦៧៦) | (៥៩.៩៧១.៧០៩) |
| ពន្ធបានបង់ | (១១៦.៧៣៦.៤៥៤) | (៩៧.៤០៧.៣១៣) |
| **សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពប្រតិបត្តិការ** | **៦២៦.៦៣៦.១១៧** | **៣៧២.៤៧៦.២៦៣** |
| លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ | | |
| ការទិញ ទ្រព្យ រោងចក្រ និងបរិក្ខារ | (៤០៩.៥១៤.៦៧១) | (២២៩.០២៣.៦១៥) |
| ការទិញ ទ្រព្យអរូបី | (៥៤៩.៤៨៥) | (៤៦៣.៥០៨) |
| សាច់ប្រាក់ទទួលបានពីការលក់ទ្រព្យ រោងចក្រ និងបរិក្ខារ | ៣៧.១៥៦ | ៤៦.២៥៥ |
| ប្រាក់បញ្ញើរមានការកំណត់ | ១៤.៩១២.០៦២ | (១២៦.៦៣០.២៦០) |
| ដើមទុនរក្សាទុក | (៩.០០៨.៤៨៩) | (៦.០៥៨.៦៦៤) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | **៤០៤.១២៣.៤២៧** | **(៣៦២.១២៩.៧៩២)** |

## របាយការណ៍លំហូរសាច់ប្រាក់ របស់អគ្គិសនីកម្ពុជា សម្រាប់ចុងឆ្នាំ២០១៧ (ត)

| | ២០១៧<br>ពាន់រៀល | ២០១៦<br>ពាន់រៀល |
|---|---|---|
| **លំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | ៩.២៤៩.៣១២ | ១៤.៧២៤.៣២៦ |
| ការទូទាត់សងប្រាក់កម្ចី | (១០៩.៦៦២.១១៩) | (៨៦.៧២៥.៨៧៤) |
| ជំនួយដែលទទួលបាន | ៣៥.៧៥៤.៩៨៥ | ២.៦៤៣.៣៨៨ |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពហិរញ្ញប្បទាន** | **(៦៤.៦៥៧.៨២២)** | **(៦៩.៣៥៨.១៦០)** |
| **ការកើនឡើងសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | **១៥៧.៨៥៤.៨៦៨** | **(៥៩.០១១.៦៨៩)** |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមការិយបរិច្ឆេទ** | **៩៩២.៩៣៦.៨១៥** | **១.០៥១.៩៤៨.៥០៤** |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងការិយបរិច្ឆេទ** | **១.១៥០.៧៩១.៦៨៣** | **៩៩២.៩៣៦.៨១៥** |





# ការអភិវឌ្ឍន៍ ធនធានមនុស្ស របស់អគ្គិសនីកម្ពុជា

*«ចំណេះដឹងថ្មីៗ អាចបង្កើតឱ្យមានការផ្លាស់ប្តូរពេញមួយជីវិត ។ អស់រយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ អគ្គិសនីកម្ពុជា បានរៀបចំនិងផ្តល់ជូននូវកម្មវិធីអប់រំវគ្គបណ្តុះ-បណ្តាលជាច្រើនសម្រាប់បុគ្គលិករបស់យើងទាំងក្នុងប្រទេស និងក្រៅប្រទេស។»*

# ការអភិវឌ្ឍន៍ ធនធានមនុស្ស របស់អគ្គិសនីកម្ពុជា

ខណៈពេលដែលសេដ្ឋកិច្ចកម្ពុជាកំពុងតែរីកចម្រើន តម្រូវការធនធានមនុស្សនៅកម្ពុជា ជាអាទិភាពចម្បង ក្នុងការជម្រុញឲ្យមានការអភិវឌ្ឍន៍លើគ្រប់វិស័យ។ដើម្បីចូលរួមអភិវឌ្ឍន៍វិស័យអគ្គិសនី និងវិស័យដទៃទៀតនៅកម្ពុជា អគ្គិសនីកម្ពុជាបានបន្តរួមចំណែកក្នុងការអភិវឌ្ឍន៍ធនធានមនុស្សនៅក្នុងប្រទេសកម្ពុជា ជាពិសេសនៅអគ្គិសនីកម្ពុជាផ្ទាល់តាមរយៈការផ្តល់ឱកាស និងធនធានដល់និយោជិតរបស់ខ្លួនក្នុងការអភិវឌ្ឍន៍ចំណេះដឹង ទាំងផ្នែកបច្ចេកទេស ជំនាញ និងផ្នែកដឹកនាំ តាមរយៈគម្រោងថវិកាបណ្តុះបណ្តាលធនធានមនុស្សអគ្គិសនី និងជំនួយពីក្រុមហ៊ុនដែលមានកិច្ចសហប្រតិបត្តិការជាមួយអគ្គិសនីកម្ពុជាក៏ដូចជាជំនួយអភិវឌ្ឍន៍ធនធានមនុស្សពីប្រទេសផ្សេងៗលើការផ្តល់អាហារូបករណ៍សិក្សាទៅក្រៅប្រទេស។

## ការអភិវឌ្ឍន៍ធនធានមនុស្ស

ចក្ខុវិស័យរបស់អគ្គិសនីកម្ពុជា សម្រាប់និយោជិតរបស់ខ្លួន គឺមានដូចខាងក្រោម ៖

- ផ្តល់ឲ្យនិយោជិតរបស់ខ្លួន មានឱកាស ដើម្បីពង្រឹងសមត្ថភាពវិជ្ជាជីវៈ ដោយផ្តោតលើសមត្ថភាព ការងារ ភាពសុចរិត និងភាពស្មោះត្រង់ចំពោះអគ្គិសនីកម្ពុជា។
- ផ្តល់ឲ្យនិយោជិតរបស់ខ្លួន នូវស្ថានភាពជីវភាពរស់នៅបានល្អ និងសមរម្យ។
- ធានានូវភាពត្រឹមត្រូវ ស្មើភាព និងផ្តល់ឱកាសដល់និយោជិតទាំងឡាយ ដើម្បីទទួលបាននូវការចូលរួមចំណែកក្នុងការអភិវឌ្ឍន៍អគ្គិសនីកម្ពុជា។
- ផ្តល់ជូននូវលក្ខខណ្ឌការងារល្អសមរម្យ ដោយបើកទូលាយក្នុងការប្រាស្រ័យទាក់ទងព័ត៌មាន ប្រកប ដោយភាពស្មោះត្រង់ក្នុងចំណោមនិយោជិតទាំងអស់ និងជួយជំរុញលើការចូលរួមធ្វើការជាក្រុម ក្នុងគោលបំណងបង្កើនប្រសិទ្ធភាពការងារ ដោយផ្តោតលើទិសដៅស្ថាបនាក្រុមហ៊ុនឲ្យមានការរីកចម្រើន។

ដើម្បីបំពេញការងារឲ្យមានប្រសិទ្ធភាពខ្ពស់ ការជ្រើសរើសធនធានមនុស្សមានតួនាទីយ៉ាងសំខាន់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការធនធានមនុស្ស អគ្គិសនីកម្ពុជា ធ្វើការជ្រើសរើសនិយោជិតរបស់ខ្លួនប្រកបដោយគុណភាព តម្លាភាព និងយុត្តិធម៌។



យ៉ាងណាមិញ ដើម្បីបន្តអភិវឌ្ឍន៍សមត្ថភាពរបស់និយោជិត អគ្គិសនីកម្ពុជាបានបណ្តុះបណ្តាលនិយោជិតរបស់ខ្លួនបន្ថែមតាមរយៈការចូលរួមវគ្គបណ្តុះបណ្តាលរយៈពេលខ្លី-រយៈពេលវែងទាំងក្នុង និងក្រៅប្រទេសដូចខាងក្រោម៖

## ការបណ្តុះបណ្តាលក្នុងប្រទេស

### ១ វិទ្យាស្ថានវិទ្យាសាស្ត្រអគ្គិសនី

វិទ្យាស្ថានវិទ្យាសាស្ត្រអគ្គិសនី ជាថ្នាលបណ្តុះបណ្តាលដ៏សំខាន់សម្រាប់និយោជិតអគ្គិសនីកម្ពុជានៅរាជធានីភ្នំពេញ ក៏ដូចជានៅតាមបណ្តាអង្គភាពអគ្គិសនីខេត្តចំណុះ ឲ្យអគ្គិសនីកម្ពុជា។ ដើម្បីជំរុញ និងលើកកម្ពស់ចំណេះដឹង និយោជិតគ្រប់រូបអាចធ្វើការស្នើសុំសិក្សាបន្ថែមលើជំនាញដើម្បីបន្ថែមលើចំណេះដឹង ដែលខ្លួនមានទៅវិទ្យាស្ថានវិទ្យាសាស្ត្រអគ្គិសនី ដែលបានលើកឡើងជារៀងរាល់ឆ្នាំ។ គោលបំណងចំបងគឺដើម្បីអភិវឌ្ឍន៍ និងស្រូបយកចំណេះដឹងថ្មី ក្នុងការបង្កើនប្រសិទ្ធភាពការងាររបស់ខ្លួនឲ្យអស់លទ្ធភាព។





នៅឆ្នាំ ២០១៧ វិទ្យាស្ថានវិទ្យាសាស្ត្រអគ្គិសនី បានបណ្តុះបណ្តាលដល់សិក្ខាកាមជានិយោជិតមកពីគ្រប់នាយកដ្ឋាន និងអង្គភាព អគ្គិសនីខេត្ត-ក្រុងចំនួន ១.២៦៦ នាក់ លើវគ្គជំនាញចំនួន ១៣៧ វគ្គ និង ៧៩ មុខវិជ្ជា។ សិក្ខាកាមទាំងនោះ ត្រូវបានបណ្តុះបណ្តាលលើជំនាញផ្សេងៗគ្នា ក្នុងនោះរួមមាន៖ សិក្ខាកាម ៣៩២ នាក់ ខាងផ្នែកបណ្តាញចែកចាយអគ្គិសនី សិក្ខាកាម១៦៥ នាក់ ខាងផ្នែកបរិធានការពារ សិក្ខាកាម ២១៧ នាក់ ខាងផ្នែកនាឡិកាស្ទង់ សិក្ខាកាម ២១៥ នាក់ ខាងផ្នែកសុវត្ថិភាពពលកម្ម សិក្ខាកាម ៦៣ នាក់ ខាងផ្នែកផលិតថាមពល សិក្ខាកាម ៩៩ នាក់ ខាងផ្នែកបណ្តាញបញ្ជូន តង់ស្យុងខ្ពស់ សិក្ខាកាម ៤៧ នាក់ ខាងផ្នែកកម្មវិធីកុំព្យូទ័រ និងសិក្ខាកាម ៦៨ នាក់ ខាងផ្នែកភាសាអង់គ្លេសបច្ចេកទេស ។

### ២ មជ្ឈមណ្ឌលអូស្ត្រាលី សម្រាប់ការបណ្តុះបណ្តាល

នៅថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ អគ្គិសនីកម្ពុជា ក៏បានផ្តល់នូវវគ្គភាសាអង់គ្លេសរយៈពេលខ្លី ដោយសហការណ៍ជាមួយមជ្ឈមណ្ឌលអូស្ត្រាលីសម្រាប់ការបណ្តុះបណ្តាលហៅកាត់ ACEដើម្បីផ្តល់ឲ្យនិយោជិតនូវវគ្គសិក្សាបន្ថែមលើភាសាអង់គ្លេសក្រៅម៉ោងការងាររបស់ខ្លួន ដោយមកទល់ពេលនេះ និយោជិតចំនួន ៣៦៣ រូប បានសិក្សាវគ្គភាសាអង់គ្លេសនេះ។ ក្រៅពីវគ្គសិក្សាភាសាអង់គ្លេស អគ្គិសនីកម្ពុជា ក៏លើកទឹកចិត្តឲ្យនិយោជិត ដែលមានបំណងចង់បន្ថែមចំណេះដឹងលើផ្នែកកម្មវិធីកុំព្យូទ័រផ្សេងៗ សម្រាប់ប្រើប្រាស់ក្នុងការងារឲ្យកាន់តែមានប្រសិទ្ធភាព។

## ការបណ្តុះបណ្តាលចំណេះដឹងក្រៅប្រទេស

អគ្គិសនីកម្ពុជា ក៏បានបន្តកិច្ចខិតខំប្រឹងប្រែងក្នុងការសហការជាមួយស្ថាប័នជាតិ និងអន្តរជាតិដទៃទៀត ដើម្បីកៀរគររកអាហារូបករណ៍ និងវគ្គបណ្តុះបណ្តាលរយៈពេលខ្លីនានាលើជំនាញអគ្គិសនី ជំនាញកុំព្យូទ័រ និងភាសាបរទេស ដើម្បីបង្កើនចំណេះដឹងឲ្យទូលំទូលាយ និងស្វែងយល់បន្ថែមពីបច្ចេកវិទ្យាថ្មីៗ ដល់និយោជិតរបស់ខ្លួន ។ គិតត្រឹមឆ្នាំ២០១៧អគ្គិសនីកម្ពុជាបានបង្កើតនូវឱកាសសិក្សាក្រៅប្រទេសដល់និយោជិតគ្រប់លំដាប់ថ្នាក់ក្នុងការស្វែងរកចំណេះដឹងបន្ថែមតាមរយៈអាហារូបករណ៍នានាដូចជា៖

-អាហារូបករណ៍ «អ្នកឯកទេសវ័យក្មេងអគ្គិសនីកម្ពុជា» ជាអាហារូបករណ៍ ដែលអគ្គិសនីកម្ពុជា ជាអ្នករ៉ាប់រងលើរាល់ការចំណាយថ្លៃ សម្រាប់សិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដោយឲ្យនិយោជិតធ្វើការសិក្សានៅបណ្តាប្រទេសជាសមាជិកអាស៊ាន។ អាហារូបករណ៍ «អ្នកឯកទេសវ័យក្មេងអគ្គិសនីកម្ពុជា» បានបង្កើតឡើងនៅថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០១៥ ក្នុងគោលបំណង ដើម្បីជំរុញ និងលើកទឹកចិត្តដល់និយោជិត ដែលមានបំណងចង់បង្កើនចំណេះដឹងខ្លួន ហើយយកចំណេះដឹងនេះ មកអភិវឌ្ឍប្រទេសកម្ពុជា។ មកត្រឹមពេលនេះ អគ្គិសនីកម្ពុជា បានបញ្ជូននិយោជិតចំនួន ០៦ រូប ទៅសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅប្រទេសថៃឡង់ដ៏ និងប្រទេសសឹង្ហបុរី។

-តាមរយៈរាជរដ្ឋាភិបាលកម្ពុជាជំនួយឥតសំណងរបស់ប្រទេសជប៉ុនសម្រាប់អាហារូបករណ៍នៃការអភិវឌ្ឍន៍ធនធានមនុស្ស ហៅកាត់ (JDS) ដែលប្រទេសកម្ពុជា ជាប្រទេសមួយក្នុងចំណោមប្រទេសទាំង ១២ ក្នុងតំបន់ ដែលទទួលបានផ្លែផ្កាពីអាហារូបករណ៍នេះ។ អគ្គិសនីកម្ពុជា បានបញ្ជូននិយោជិតខ្លួនចំនួន ១៨ រូប ទៅសិក្សានៅប្រទេសជប៉ុន ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់លើជំនាញជាច្រើន។



- អគ្គិសនីកម្ពុជា បានចុះអនុស្សរណៈយោគយល់គ្នាជាមួយក្រុមហ៊ុន CHMC (China National Heavy Machinery Corporation) ដែលជាក្រុមហ៊ុនដៃគូអភិវឌ្ឍន៍ ដើម្បីផ្តល់អាហារូបករណ៍ទៅសិក្សា ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅប្រទេសចិន រហូតមកដល់ពេលនេះ អគ្គិសនីកម្ពុជា បានបញ្ជូននិយោជិតចំនួន ២ រូប ទៅសិក្សានៅប្រទេសចិន លើថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកបច្ចេកទេសអគ្គិសនី។

- ក្រសួង រ៉ែ និងថាមពល បានចុះអនុស្សរណៈយោគយល់ជាមួយក្រុមហ៊ុន China Southern Power Grid Co., Ltd (CSG) ដើម្បីផ្តល់អាហារូបករណ៍ដល់មន្ត្រី និងនិយោជិតអគ្គិសនីកម្ពុជា ក្នុងការបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅប្រទេសចិន ដោយបានផ្តល់អាហារូបករណ៍ចំនួន ០៦ កន្លែងមកអគ្គិសនីកម្ពុជា។

ក្រៅពីអាហារូបករណ៍ទាំងនេះ និយោជិតអគ្គិសនីកម្ពុជា ក៏អាចស្វែងរកអាហារូបករណ៍ដោយខ្លួនឯង ដើម្បីទៅបន្តការសិក្សាទាំងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត នៅតាមសកលវិទ្យាល័យនានានៅក្រៅប្រទេស ។ រហូតមកដល់ពេលនេះ មាននិយោជិត ដែលកំពុងសិក្សា និងបញ្ចប់ការសិក្សាចំនួន ០៨ រូប នៅប្រទេសថៃឡង់ដ៍ និងប្រទេសចិន ។



**តារាងទី ១ : កម្រិតវប្បធម៌របស់និយោជិត-កម្មករ អគ្គិសនីកម្ពុជាពីឆ្នាំ ២០១២ - ២០១៧**

| ប្រភេទ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ |
|---|---|---|---|---|---|---|
| បណ្ឌិត | ៣ | ៤ | ៤ | ៤ | ៥ | ៦ |
| អនុបណ្ឌិត | ១៤២ | ១៤១ | ១៥១ | ១៦៥ | ១៧៩ | ១៩៣ |
| វិស្វករ និងបរិញ្ញាប័ត្រផ្សេងៗ | ៨២២ | ៩៣៤ | ១.០៧៨ | ១.២៤០ | ១.៣៨៣ | ១៦៥១ |
| បច្ចេកទេសជំនាញ | ៤៩៣ | ៥៧០ | ៧៣៦ | ៩១៧ | ១.១៧៥ | ១៣៧៣ |
| កម្មករជំនាញ | ១៨៨ | ១៨០ | ១៧៨ | ១៧៣ | ១៦៨ | ១៣៣៦ |
| ទុតិយភូមិ និង គ្មានជំនាញ | ១.២៨៧ | ១.៣៩៨ | ១.៤៣៨ | ១.៥២៧ | ១.៦៨៧ | ៥២៨ |
| **សរុប** | **២.៩៣៥** | **៣.២២៧** | **៣.៥៨៥** | **៤.០២៦** | **៤.៥៩៧** | **៥០៨៧** |

# មធ្យោបាយ ផលិតថាមពល និងការផ្គត់ផ្គង់ ថាមពលអគ្គិសនី

ផលិតកម្ម ថាមពលអគ្គិសនី សម្រាប់បំពេញតម្រូវការប្រើប្រាស់នៅក្នុង ប្រព័ន្ធអគ្គិសនីជាតិទាំងមូល នាពេលបច្ចុប្បន្ន ត្រូវបានផ្តោតសំខាន់ទៅលើប្រភពថាមពលស្អាត។





## ប្រភពផលិតកម្ម



ក្នុងឆ្នាំ២០១៧ អានុភាពតម្លើងសរុបប្រមាណ ២.៥២០ MW ដែលក្នុងនោះរួមមាន វារីអគ្គិសនីប្រមាណ ១.៣៣០ MW ធ្យូងថ្មប្រមាណ ៥៣៥ MW ប្រេងឥន្ធនៈប្រមាណ ២៤៨ MW ជីវម៉ាសប្រមាណ ៦ MW ពន្លឺព្រះអាទិត្យ ១០ MW និងនាំចូលពីប្រទេសជិតខាងដូចជាប្រទេសថៃឡង់ដ៏ ប្រទេសវៀតណាម និងប្រទេសឡាវ សរុបប្រមាណ ៣៨៨ MW ។ ថាមពលផលិតសរុបប្រមាណ ៧.៦៦៥ GWh ក្នុងនោះប្រភពពីវារីអគ្គិសនីមាន ៣៥% ប្រភពធ្យូងថ្ម ៤៦,៥% ប្រភពប្រេងឥន្ធនៈ ៣% ប្រភពជីវម៉ាស់ ០,៥% ថាមពលពន្លឺព្រះអាទិត្យ ០,១% និង ការនាំចូលពីប្រទេសជិតខាង ១៥%។ ជាលទ្ធផលនៃការអភិវឌ្ឍន៍ប្រភពអគ្គិសនីក្នុងស្រុក បានធ្វើឲ្យការនាំចូលថាមពលពីប្រទេសជិតខាង ថយចុះគួរកត់សំគាល់ពី៦២% នៅឆ្នាំ២០១០ មកត្រឹម ១៥% នៅឆ្នាំ២០១៧ និងការប្រើប្រាស់ប្រេងឥន្ធនៈថយចុះយ៉ាងគំហុកពី ៣៤% មកត្រឹម ៣% និងមានកំណើនផលិតកម្មសរុបប្រចាំឆ្នាំប្រមាណ ១៦% បើធៀបនឹងឆ្នាំ២០១៦។

## តម្រូវការថាមពល និងការផ្គត់ផ្គង់អគ្គិសនី នៅក្នុងបណ្ដាញជាតិ

នៅចុងឆ្នាំ២០១៧ នេះ «បណ្ដាញជាតិ» កម្ពុជា ក្រោយពីបានភ្ជាប់ជាមួយប្រព័ន្ធអគ្គិសនីតង់ស្យុងខ្ពស់ប្រទេសវៀតណាម ភ្ជាប់ជាមួយប្រព័ន្ធអគ្គិសនីតង់ស្យុងខ្ពស់ប្រទេសថៃឡង់ដ៏ និងភ្ជាប់ជាមួយប្រភពវារីអគ្គិសនីនៅតំបន់កំពង់ស្ពឺ កោះកុង និងពោធិ៍សាត់ ប្រភពវារីអគ្គិសនីនៅតំបន់ជួរភ្នំគិរីរម្យ និងជួរភ្នំកំចាយ ព្រមទាំងភ្ជាប់ជាមួយប្រភពអគ្គិសនីផលិត ដោយធ្យូងថ្មនាំចូលនៅខេត្តព្រះសីហនុ ការផ្គត់ផ្គង់អគ្គិសនីរបស់ «បណ្ដាញជាតិ»នេះ បានគ្របដណ្ដប់ផ្ទាល់លើរាជធានី / ខេត្តចំនួន ១៤ គឺ៖ ភ្នំពេញ កណ្ដាល កំពង់ស្ពឺ តាកែវ កំពត កែប ព្រះសីហនុ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ចាម និងកោះកុង រួចហើយ និងបានបញ្ជូនទៅផ្គត់ផ្គង់ខេត្តចំនួន ៤ ទៀតគឺ៖ ត្បូងឃ្មុំ ព្រៃវែង កំពង់ធំ និងប៉ៃលិន ដែលមានអានុភាពតម្រូវការអតិបរមាប្រមាណ ១.២៦៩ MW និងថាមពលផលិត ៧.៦៦៥ GWh ហើយតំបន់គ្របដណ្ដប់ទាំងនោះមានដូចខាងក្រោម៖





**អគ្គិសនីភ្នំពេញ (ប្រព័ន្ធភ្នំពេញ)** ភ្នំពេញ គឺជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា។ ប្រព័ន្ធអគ្គិសនីភ្នំពេញ ផ្គត់ផ្គង់ពីបណ្ដាញជាតិ តាមរយៈអនុស្ថានីយតង់ស្យុង ២៣០ kV ដូចជា៖ អនុស្ថានីយទី៤ អនុស្ថានីយទី៦ និង អនុស្ថានីយទី៧ ជាមួយនឹងអានុភាពសរុបប្រមាណ ៩០០ MW ព្រមទាំង ផលិតកម្មដោយប្រេងមានប្រមាណ ១៩៤ MW ដោយបញ្ចូលមកក្នុងប្រព័ន្ធភ្នំពេញ តាមអនុស្ថានីយតង់ស្យុង ១១៥ kV ដែលរួមមាន៖ អនុស្ថានីយទី១ អនុស្ថានីយទី២ អនុស្ថានីយទី៣ អនុស្ថានីយទី៤ អនុស្ថានីយទី៥ អនុស្ថានីយទី៦ និងអនុស្ថានីយទី៧។ តំបន់ស្ថិតក្នុងការគ្រប់គ្រងរបស់អគ្គិសនីភ្នំពេញរួមមាន រាជធានីភ្នំពេញ តំបន់ជាយក្រុងជុំវិញក្រុងភ្នំពេញ និងទីប្រជុំជនក្រុងតាខ្មៅ ខេត្តកណ្ដាល។

នៅឆ្នាំ២០១៧ តម្រូវការអានុភាពអតិបរមារបស់ប្រព័ន្ធភ្នំពេញប្រមាណ ៧៧៧ MW ផ្គត់ផ្គង់ជូនអតិថិជនគ្រប់ប្រភេទចំនួន ៦៥២.៨៥៨ ។ ប្រព័ន្ធភ្នំពេញបានទាញថាមពលពីប្រភពបណ្ដាញជាតិប្រមាណ ៤.៧៥៦ GWh ក្នុងឆ្នាំ២០១៧ និងមានត្រឹម ៤.៥៩៦ GWh ក្នុងឆ្នាំ២០១៦ ។

**អគ្គិសនីសៀមរាប** សៀមរាប គឺជាតំបន់ទាក់ទាញភ្ញៀវទេសចរណ៍ និងមានទីតាំងស្ថិតនៅ ភាគពាយ័ព្យនៃប្រទេសកម្ពុជា។ អគ្គិសនីសៀមរាប ត្រូវបានផ្ទេរមកនៅក្រោម ការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ ១៩៩៥។ ការផ្គត់ផ្គង់អគ្គិសនីនៅខេត្តសៀមរាប បានមកពីការផលិត ដោយរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ខ្លួន និងពីអនុស្ថានីយអគ្គិសនីស្រុកពួក ដែលបាននាំចូលថាមពលពីប្រទេសថៃឡង់ដ៏តាមខ្សែបញ្ជូន ១១៥ kV តាំងពីឆ្នាំ ២០០៧។ ប្រព័ន្ធអគ្គិសនីសៀមរាប បានភ្ជាប់ជាមួយបណ្ដាញជាតិនៅឆ្នាំ ២០១៣។

ចំណុចសំខាន់ៗនៃប្រតិបត្តិការរបស់ប្រព័ន្ធអគ្គិសនីសៀមរាប សម្រាប់ឆ្នាំ២០១៧ មានដូចជា ៖ សមត្ថភាពផ្គត់ផ្គង់ប្រមាណ ៩០ MW បានមកពីបណ្ដាញជាតិ និង ១១ MW បានមកពីផលិតកម្មដោយរោងចក្រផ្ទាល់ខ្លួន។ តម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ៨៩ MW ។ ប្រភពថាមពលផលិតនៅក្នុងប្រព័ន្ធទាំងអស់



សរុបប្រមាណ ៥៣០ GWh ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុប ចំនួន ២.៣៥៦ km ដែលបានផ្គត់ផ្គង់ជូនអតិថិជនគ្រប់ប្រភេទចំនួន ៦១.៧៤៥។

**អគ្គិសនីខេត្តព្រះសីហនុ** ខេត្តព្រះសីហនុ គឺជាតំបន់ទេសចរណ៍ ដែលមានឆ្នេរសមុទ្រស្អាតជាប់ចំណាត់ថ្នាក់លេខ១ ស្ថិតនៅភាគនិរតីនៃប្រទេសកម្ពុជា។ អគ្គិសនីខេត្តព្រះសីហនុ ត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៩៦។ កន្លងមកប្រព័ន្ធអគ្គិសនីក្រុងព្រះសីហនុ ជាប្រព័ន្ធដាច់ដោយឡែកពីគេ និងទទួលការផ្គត់ផ្គង់ពីរោងចក្រផលិតអគ្គិសនីក្នុងខេត្ត ដែលមានអានុភាពតម្លើងសរុប ២០MW។ នៅចុងឆ្នាំ ២០១១ ប្រព័ន្ធនេះ បានតភ្ជាប់ជាមួយប្រព័ន្ធអគ្គិសនីកំពត ដែលទទួលថាមពលពីបណ្តាញជាតិ ព្រមទាំងថាមពលនាំចូលពីប្រទេសវៀតណាម។ ចុងឆ្នាំ ២០១២ និងដើមឆ្នាំ ២០១៣ ប្រព័ន្ធអគ្គិសនីខេត្តព្រះសីហនុ ត្រូវបានផ្គត់ផ្គង់ដោយផ្ទាល់ពីបណ្តាញជាតិតាមរយៈខ្សែបញ្ជូន ២៣០ kV ពីអនុស្ថានីយកំពត ទៅអនុស្ថានីយស្ទឹងហាវ និងខ្សែបញ្ជូន ១១៥ kV ពីអនុស្ថានីយស្ទឹងហាវ ទៅអនុស្ថានីយក្រុងព្រះសីហនុ។ ក្នុងឆ្នាំ២០១៧ អគ្គិសនីខេត្តព្រះសីហនុ បានទទួលការផ្គត់ផ្គង់ពីបណ្តាញជាតិប្រមាណ ៩០ MW និងពីផលិតកម្មដោយរោងចក្រផលិតអគ្គិសនីក្នុងខេត្ត ២០ MW ដែលនាំឲ្យមានការកើនឡើងនូវលទ្ធភាពផ្គត់ផ្គង់របស់ប្រព័ន្ធទៅតំបន់ផ្សេងទៀត និងសេវាករ ជាច្រើននៅក្នុងខេត្តព្រះសីហនុ ។ ចំណុចសំខាន់ៗនៃប្រតិបត្តិការរបស់ប្រព័ន្ធអគ្គិសនីខេត្តព្រះសីហនុ សម្រាប់ឆ្នាំ២០១៧ មានដូចតទៅ ៖ ផលិតកម្មថាមពលប្រចាំឆ្នាំមាន ៣១៧ GWh តម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ៦៨ MW ជាមួយប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៩៨៤ km ដែលបានផ្គត់ផ្គង់ជូនអតិថិជនគ្រប់ប្រភេទចំនួន ២០.១៥៧។

**អគ្គិសនីកំពង់ចាម** កំពង់ចាម ជាខេត្តដែលប្រកបដោយដីមានជីវជាតិសម្រាប់ចម្ការកៅស៊ូ មានទីតាំងស្ថិតនៅភាគខាងកើតនៃប្រទេសកម្ពុជា។ អគ្គិសនីកំពង់ចាម ត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជា នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨។ ក្នុងឆ្នាំ ១៩៩៦ ប្រព័ន្ធអគ្គិសនីកំពង់ចាម ត្រូវបានផ្គត់ផ្គង់ដោយរោងចក្រផលិតអគ្គិសនីក្នុងខេត្ត។ លុះដល់ឆ្នាំ ២០១១ ផ្នែកមួយចំនួននៃប្រព័ន្ធនេះ បានទទួលថាមពល ដែលនាំចូលពីប្រទេសវៀតណាម។ អគ្គិសនីកំពង់ចាម



បានភ្ជាប់មកបណ្តាញជាតិបញ្ជូននៅឆ្នាំ២០១៣។ ចំណុចសំខាន់ៗនៃប្រតិបត្តិការរបស់ប្រព័ន្ធអគ្គិសនីកំពង់ចាម សម្រាប់ឆ្នាំ២០១៧ មានដូចតទៅ៖ សមត្ថភាពផ្គត់ផ្គង់ប្រមាណ ៩០ MW បានមកពីបណ្តាញជាតិ និង ៨ MW បានមកពីផលិតកម្មដោយរោងចក្រផលិតអគ្គិសនីក្នុងខេត្ត។ ផលិតកម្មថាមពលប្រចាំឆ្នាំសរុបប្រមាណ ១០៣ GWh និងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ៣៦ MW ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ១.០២៤ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ២១.៣៤១។

**សាខាមេមត់ និងពញាក្រែក** ប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីសម្រាប់ស្រុកមេមត់ និងពញាក្រែក មានទីតាំងស្ថិតនៅខេត្តកំពង់ចាម និងប្រើប្រាស់ប្រព័ន្ធបណ្តាញតង់ស្យុងមធ្យម ២២ kV ។ ការផ្គត់ផ្គង់ថាមពលអគ្គិសនី ទៅតំបន់ទាំងពីរនេះ ត្រូវបាននាំចូលពីប្រទេសវៀតណាម ចាប់ពីឆ្នាំ២០០២ ដែលមានអានុភាពផ្គត់ផ្គង់តាមកិច្ចសន្យា ១០ MW។ ក្នុងឆ្នាំ ២០១៧ ថាមពលនាំចូលមានចំនួន ៤៩

GWh ព្រមទាំងប្រវែងខ្សែបណ្ដាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្ដាញតង់ស្យុងទាប 0,៤ kV មានប្រវែងសរុបចំនួន ៤២០ km ដែលតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ១៣ MW និងបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ២៣.៥៣៩ ។

**អគ្គិសនីបាត់ដំបង** បាត់ដំបង ជាខេត្តដែលឈានមុខគេ និងមានសក្ដានុពលសេដ្ឋកិច្ចផ្នែកកសិកម្ម ជាពិសេសគឺផលិតកម្មស្រូវអង្ករ ។ ខេត្តនេះមានទីតាំងស្ថិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា ។ អគ្គិសនីបាត់ដំបង ត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០០។ អគ្គិសនីបាត់ដំបង បានគ្របដណ្ដប់លើខ្សែបញ្ជូនរងក្នុងខេត្តពោធិ៍សាត់។ ខ្សែបញ្ជូន ១១៥ kV សម្រាប់នាំចូលថាមពលអគ្គិសនីពីប្រទេសថៃឡង់ដ៏ ត្រូវបានតភ្ជាប់ជាមួយប្រព័ន្ធបញ្ជូនអគ្គិសនីសៀមរាប និងបន្ទាយមានជ័យក្នុងឆ្នាំ ២០០៧ ព្រមទាំងភ្ជាប់បន្តទៅបណ្ដាញជាតិបញ្ជូនក្នុងឆ្នាំ២០១២ ។ ការផ្គត់ផ្គង់ថាមពលអគ្គិសនីក្នុងខេត្តបាត់ដំបង បានពីបណ្ដាញជាតិ តាមរយៈអនុស្ថានីយបាត់ដំបង (CPG) និងអនុស្ថានីយបាត់ដំបង (CPTL) ដោយមានសមត្ថភាពសរុប ១៨៥ MW ពីរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ប្រហែលជិត ២ MW ។ ក្នុងឆ្នាំ ២០១៧ ប្រព័ន្ធអគ្គិសនីបាត់ដំបងមានថាមពលផលិតសរុបប្រមាណ ៣៦៤ GWh ព្រមទាំងតម្រូវការប្រើប្រាស់អានុភាពជា អតិបរមា ៧១ MW ។ ប្រវែងខ្សែបណ្ដាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្ដាញតង់ស្យុងទាប 0,៤ kV មានប្រវែងសរុបចំនួន ២.៤៦៥ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៥០.០៩៣ ។

**អគ្គិសនីបន្ទាយមានជ័យ និងសាខាមង្គលបូរី** បន្ទាយមានជ័យ មានទីតាំងស្ថិតនៅភាគពាយ័ព្យ នៃប្រទេសកម្ពុជា ។ អគ្គិសនីបន្ទាយមានជ័យ ត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៣។ ការផ្គត់ផ្គង់ថាមពលអគ្គិសនីក្នុងខេត្តបន្ទាយមានជ័យ បានពីការនាំចូលពីប្រទេសថៃឡង់ដ៏ និងការផលិតថាមពលពីរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ ក្នុងឆ្នាំ២០០៧។ បន្ទាប់មកប្រព័ន្ធ អគ្គិសនីរបស់ខេត្តនេះ បានតភ្ជាប់ថាមពលពីបណ្ដាញជាតិបញ្ជូននៅឆ្នាំ២០១៣ ។ នៅឆ្នាំ ២០១៧ ការផ្គត់ផ្គង់ ៦៨ MW បានមកពីបណ្ដាញជាតិបញ្ជូន (ពីអនុស្ថានីយបន្ទាយមានជ័យ និងអនុស្ថានីយ IE) និង ៣ MW ទៀតបានពីរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់។ ថាមពលនាំចូលសរុបគឺ ១៣៣ GWh ដែលតម្រូវការប្រើប្រាស់អានុភាព អតិបរមា ២៦ MW ។ ប្រវែងខ្សែបណ្ដាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្ដាញតង់ស្យុងទាប 0,៤ kV មានប្រវែងសរុបចំនួន ៣៤០ km និងបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ២៣.៥៦៨។

**អគ្គិសនីស្ទឹងត្រែង** ស្ទឹងត្រែង គឺជាខេត្តដាច់ស្រយាលមួយ និងមានប្រជាជនរស់នៅរង្វើលៗ ឃ្លាតៗ ពីគ្នាដែលស្ថិតនៅភាគឦសាននៃប្រទេសកម្ពុជា ។ អគ្គិសនីស្ទឹងត្រែង ត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅថ្ងៃទី១៤ ខែសីហា ឆ្នាំ ២០០៣។ ប្រព័ន្ធអគ្គិសនីក្រុងស្ទឹងត្រែង បានតភ្ជាប់ទៅប្រព័ន្ធ អគ្គិសនីប្រទេសឡាវ តាមរយៈតង់ស្យុង ២២ kV តាំងពីឆ្នាំ ២០១០។ ក្នុងឆ្នាំ២០១៧ សមត្ថភាពផ្គត់ផ្គង់សរុបគឺ ៦ MW (ដែលប្រហែលជិត ២ MW ផ្គត់ផ្គង់ដោយរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ និង ៤ MW នាំចូលពីប្រទេសឡាវ)។ តម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ១២ MW និងថាមពលផលិតសរុប ៤៩ GWh។ ប្រវែងខ្សែបណ្ដាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្ដាញតង់ស្យុងទាប 0,៤ kV មានប្រវែងសរុបចំនួន ៧៦៩ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៩.៥០៣។



**អគ្គិសនីរតនគិរី** រតនគិរី ស្ថិតនៅជាប់ព្រំដែនខ្ពង់រាបកណ្ដាល នៃប្រទេសវៀតណាម និងប្រទេសឡាវ។ អគ្គិសនីរតនគិរី ត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅថ្ងៃទី១៤ ខែសីហា ឆ្នាំ ២០០៣។ ក្នុងឆ្នាំ ២០១៧ប្រព័ន្ធអគ្គិសនីរតនគិរីមានអានុភាពតម្លើង ៤ MW ពីរោងចក្រវារីអគ្គិសនីរបស់អគ្គិសនីកម្ពុជាផ្ទាល់ និងរោងចក្រផលិតថាមពលក្នុងខេត្តប្រមាណ ៨ MW បាននាំចូលពីប្រទេសវៀតណាម តាមរយៈខ្សែបញ្ជូនរងតង់ស្យុង ៣៥ kV ។ នៅឆ្នាំ ២០១៧ តម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ១៩ MW ថាមពលផលិត និងនាំចូលសរុបប្រចាំឆ្នាំប្រមាណ ៥០ GWh ។ ប្រវែងខ្សែបណ្ដាញចែកចាយ 0,៤ kV មានប្រវែងសរុបចំនួន

ចំនួន ៥៩២ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៨.០៧៥។

**អគ្គិសនីតាកែវ និងសាខាអង្គតាសោម** តាកែវ មានទីតាំងស្ថិតនៅតំបន់វាលរាបភាគខាងត្បូងនៃប្រទេសកម្ពុជា។អគ្គិសនីតាកែវ ត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ២០០០។ ខ្សែបញ្ជូនតង់ស្យុង ២៣០kV ចេញពីប្រទេសវៀតណាម និងអនុស្ថានីយតាកែវ ត្រូវបានដាក់ឲ្យដំណើរការនៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៩ ដើម្បីនាំចូលថាមពលពីប្រទេសវៀតណាម។ នៅឆ្នាំ២០១៧ ការផ្គត់ផ្គង់ពីបណ្ដាញជាតិមានប្រមាណ ៤៥ MW ហើយពីរោងចក្រផលិតអគ្គិសនីប្រើប្រេងប្រមាណជិត ២ MW ។ នៅឆ្នាំ២០១៧ តម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ២១ MW ដែលប្រវែងខ្សែបណ្ដាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្ដាញតង់ស្យុងទាប 0,៤ kV មានប្រវែងសរុបចំនួន ៧៨៦ km ថាមពលផលិត ដោយរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ ការនាំចូល និងទិញពីបណ្ដាញជាតិបញ្ជូនសរុបប្រចាំឆ្នាំ ៩០ GWh ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ២៣.៧៣២ ។



**អគ្គិសនីកំពត** កំពត មានទីតាំងស្ថិតនៅភាគខាងត្បូង នៃប្រទេសកម្ពុជា ។ អគ្គិសនីកំពត ត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅថ្ងៃទី១៤ ខែសីហា ឆ្នាំ ២០០៣។ ផលិតកម្មពីរោងចក្រប្រើប្រេងរបស់អគ្គិសនីកំពត និងការនាំចូលថាមពលពីប្រទេសវៀតណាម តាមរយៈខ្សែបណ្ដាញតង់ស្យុង២២ kV ឆ្លងកាត់ស្រុកកំពង់ត្រាច ត្រូវបានប្រើសម្រាប់ផ្គត់ផ្គង់ឲ្យក្រុងកំពត ។ក្នុងឆ្នាំ ២០១១ ការផ្គត់ផ្គង់ពីបណ្ដាញជាតិមានប្រមាណ ៤៥ MW។ នៅឆ្នាំ ២០១៧ ថាមពលផលិត ដែលផ្គត់ផ្គង់ដោយរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ ការនាំចូល ការទិញពីបណ្ដាញជាតិបញ្ជូនមានសរុប ១១៦ GWh ហើយតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ១៦ MW ប្រវែងខ្សែបណ្ដាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្ដាញតង់ស្យុងទាប 0,៤ kV មានប្រវែងសរុបចំនួន ៦៧៣ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៤.៨២៩។

**សាខាកំពង់ត្រាច** ប្រព័ន្ធអគ្គិសនីកំពង់ត្រាច ស្ថិតនៅក្នុងខេត្តកំពត និងនាំចូលអគ្គិសនីពីប្រទេសវៀតណាម តាំងពីឆ្នាំ២០០២ ។ ក្នុងឆ្នាំ២០១៤ ប្រព័ន្ធអគ្គិសនីកំពង់ត្រាច ត្រូវបានភ្ជាប់ជាមួយបណ្ដាញជាតិបញ្ជូន។ នៅឆ្នាំ២០១៦ អានុភាពជាវតាមកិច្ចសន្យាគឺ ១០ MW ហើយប្រវែងខ្សែបណ្ដាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្ដាញតង់ស្យុងទាប 0,៤ kV មានប្រវែងសរុបចំនួន ១៤៤ km មានថាមពលផលិតសរុប ១៤ GWh និងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ៣ MW ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៦.៦៩១។

**អគ្គិសនីព្រៃវែង** ព្រៃវែង មានទីតាំងស្ថិតនៅភាគអាគ្នេយ៍ នៃប្រទេសកម្ពុជា ។ អគ្គិសនីព្រៃវែង ត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រង របស់អគ្គិសនីកម្ពុជានៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៣។ ប្រព័ន្ធអគ្គិសនីព្រៃវែង មានប្រភពពីរោងចក្រអគ្គិសនីផ្ទាល់ខ្លួន ដែលមានអានុភាពតម្លើងប្រមាណជិត ១ MW (ក្នុងឆ្នាំ ២០០៣) និងអានុភាពនាំចូលពីវៀតណាម (ក្នុងឆ្នាំ ២០០៩)។ ក្រោយពីដាក់ឲ្យដំណើរការបណ្ដាញអគ្គិសនីក្នុងគម្រោងជនបទ ខេត្តព្រៃវែងទទួលបានការផ្គត់ផ្គង់ពីប្រព័ន្ធអគ្គិសនីកំពង់ចាម (ក្នុងឆ្នាំ ២០១៣) ប្រព័ន្ធអគ្គិសនីភ្នំពេញសម្រាប់ផ្គត់ផ្គង់តំបន់តាមបណ្ដោយផ្លូវជាតិលេខ ៨ (ក្នុងឆ្នាំ ២០១៤) និងរោងចក្រអគ្គិសនីដើរដោយធ្យូងថ្មសុវណ្ណភូមិ (ក្នុងឆ្នាំ ២០១៥)។ ក្នុងឆ្នាំ២០១៧ ប្រវែងខ្សែបណ្ដាញចែកចាយតង់ស្យុងមធ្យម ២២kV និងប្រវែងបណ្ដាញតង់ស្យុងទាប 0,៤ kV មានប្រវែងសរុបចំនួន ៨៦៧ km និងតម្រូវការអានុភាពអតិបរមា ២១ MW ព្រមទាំងថាមពលផលិត និងនាំចូលប្រមាណ ៨៨ GWh ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៧.១២៩ ។

**អគ្គិសនីស្វាយរៀង** ស្វាយរៀង មានទីតាំងស្ថិតនៅភាគអាគ្នេយ៍នៃប្រទេសកម្ពុជា។ អគ្គិសនីស្វាយរៀង ត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅថ្ងៃទី១៤ ខែសីហា ឆ្នាំ ២០០៣។ អគ្គិសនីស្វាយរៀង ត្រូវបានផ្គត់ផ្គង់ដោយការនាំចូលថាមពលពីប្រទេសវៀតណាម (ក្នុងឆ្នាំ២០០៣) ពីរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់អានុភាពផលិតសរុបប្រមាណ ៨ MW (ក្នុងឆ្នាំ ២០០៦) និង ពីរោងចក្រអគ្គិសនីដើរដោយធ្យូងថ្ម សុវណ្ណភូមិ (ក្នុងឆ្នាំ ២០១៥) ។ នៅឆ្នាំ ២០១៧ ថាមពលនាំចូល និងផលិតដោយរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់គឺ ១៩៤ GWh ដែលមានតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ១៩ MW ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៦៦៣ km ព្រមទាំងបានផ្គត់ផ្គង់ដល់អតិថិជន គ្រប់ប្រភេទចំនួន ២៧.៨១១។

**សាខាបាវិត** ប្រព័ន្ធអគ្គិសនីបាវិត ស្ថិតនៅខេត្តស្វាយរៀង និងទទួលការផ្គត់ផ្គង់ថាមពលតាមរយៈ ការនាំចូលពីប្រទេសវៀត-ណាម។ នៅឆ្នាំ២០១៧ អានុភាពនាំចូលពីប្រទេសវៀតណាមប្រមាណ ១៦ MW និងមានតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ២៧ MW ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៥.០៤៣ ។

**អគ្គិសនីមណ្ឌលគិរី** អគ្គិសនីមណ្ឌលគិរី ត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅថ្ងៃទី១០ ខែឧសភា ឆ្នាំ ២០១០។ អានុភាពតម្លើង ៣៧០ kW ផលិតដោយរោងចក្រវារីអគ្គិសនីអានុភាពផលិត ដោយម៉ាស៊ីនឌីយ៉ែសែល ៣០០ kW និងអានុភាពនាំចូលពីប្រទេសវៀតណាមប្រមាណ ១ MW ។ ក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅឆ្នាំ២០១៧ ថាមពលផលិត និងនាំចូលសរុប ១១ GWh និងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមាជាង ៣ MW ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែង បណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ២៩៥ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៣.៧៣៥។

**សាខាកែវសីមា** អគ្គិសនីកែវសីមា ជាសាខាអគ្គិសនីស្ថិតនៅក្នុងស្រុកកែវសីមា ខេត្តមណ្ឌលគិរី។ ការផ្គត់ផ្គង់ថាមពល គឺតាមរយៈការនាំចូលពីប្រទេសវៀតណាម ដែលអានុភាពបញ្ចេញតាមកិច្ចសន្យា ០,៤ MW ។ ថាមពលនាំចូលគឺ ៦ GWh និងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមាជិត ១ MW ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ១៣១ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៣.៨២៥។

**អគ្គិសនីក្រចេះ** អគ្គិសនីក្រចេះ ត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០១១។ ប្រព័ន្ធអគ្គិសនីក្រចេះ ជាប្រព័ន្ធនៅដាច់ដោយឡែក ដែលផ្គត់ផ្គង់ដោយរោងចក្រ ផលិតថាមពលអគ្គិសនីផ្ទាល់ខ្លួន ដែលមាន អានុភាពតម្លើងជិត ១ MW (ក្នុងឆ្នាំ ២០១១) និងពីប្រព័ន្ធអគ្គិសនីកំពង់ចាម (ក្នុងឆ្នាំ ២០១៥)។ ក្រោមការគ្រប់គ្រងដោយអគ្គិសនីកម្ពុជានៅឆ្នាំ២០១៧ ថាមពលទិញ និងនាំចូលប្រចាំឆ្នាំប្រមាណ ៣៦ GWh និងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមាប្រហែល ៩ MW ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៥៥២km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ១០.១១៥។

**សាខាស្នួល** ប្រព័ន្ធអគ្គិសនីស្នួល ស្ថិតនៅស្រុកស្នួល ខេត្តក្រចេះ ។ ប្រព័ន្ធនេះ បានផ្គត់ផ្គង់ដោយការនាំចូលថាមពលពីប្រទេសវៀតណាមប្រមាណ ៥ MW ដោយមានថាមពលផលិតប្រចាំឆ្នាំ ១២ GWh និងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ២ MW ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ១០១ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ២.៥៧៦។

**អគ្គិសនីកំពង់ស្ពឺ** នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១២ សាខាកំពង់ស្ពឺ ត្រូវបានបង្កើតជាអង្គភាពខេត្ត ខណៈដែលសាខានេះ កាលពីពេលកន្លងមក ស្ថិតក្រោមប្រព័ន្ធគ្រប់គ្រងអគ្គិសនីភ្នំពេញ ។ អង្គភាពនេះទទួលបន្ទុកគ្រប់គ្រងប្រព័ន្ធអគ្គិសនីក្នុងខេត្តកំពង់ស្ពឺ និងតំបន់តាមបណ្តោយផ្លូវជាតិលេខ៤ ដែលចែកចាយថាមពល ដល់អនុស្ថានីយកំពង់ស្ពឺ។ ក្នុងឆ្នាំ២០១៧ សមត្ថភាពផ្គត់ផ្គង់ប្រមាណ ៤៥ MW បានមកពីបណ្តាញជាតិ ដែលថាមពលផលិតប្រចាំឆ្នាំគឺ ១២០ GWh និងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ៤៦ MW ជាមួយប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៧៧៥km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ១៦.៤១០។

## តារាងទី ២ : អានុភាពតម្លើង និងអានុភាពបញ្ចេញពីប្រភពរោងចក្រ និងការនាំចូល (MW)

| ឆ្នាំ / ទីតាំង | | | អានុភាព | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ |
|---|---|---|---|---|---|---|---|---|---|
| បណ្ដាញជាតិ | | | តម្លើង | ៨៣៩ | ១.៤២៦ | ១.៩៧២ | ១.៩៥៩ | ២.០៩៤ | ២.៥០៩ |
| | | | បញ្ចេញ | ៧៦៨ | ១.១៦៨ | ១.៧៦៨ | ១.៨៨៨ | ២.០១៤ | ២.០៨០ |
| ភ្នំពេញ | | | តម្លើង | ៦៣៤ | ១.២២០ | ១.៧២៨ | ១.៨៤២ | ១.៩៧៧ | ២.៣៨៧ |
| | | | បញ្ចេញ | ៥៧១ | ៩៦៨ | ១.៥៣១ | ១.៧៧៨ | ១.៩០៥ | ១.៩៦៥ |
| អគ្គិសនីកម្ពុជា | ឯកជន | ប្រេង | តម្លើង | ៤៤ | ៤៤ | ៤៤ | ៨១ | ៨១ | ៨១ |
| | | | បញ្ចេញ | ៤១ | ៤១ | ៤១ | ៧៥ | ៧៥ | ៧៥ |
| CUPL | ឯកជន | ប្រេង | តម្លើង | ៣៧ | ៣៧ | ៣៧ | - | - | - |
| | | | បញ្ចេញ | ៣២ | ៣២ | ៣២ | - | - | - |
| KEP | ឯកជន | ប្រេង | តម្លើង | ៤៩ | ៤៩ | ៤៩ | ៤៩ | ៤៩ | ៤៩ |
| | | | បញ្ចេញ | ៤៣ | ៤៣ | ៤៣ | ៤៣ | ៤៣ | ៤៣ |
| CITY Power | ឯកជន | ប្រេង | តម្លើង | - | ៨ | - | - | - | - |
| | | | បញ្ចេញ | - | ៧ | - | - | - | - |
| CEP | ឯកជន | ប្រេង | តម្លើង | ៤៩ | ៤៩ | ៤៩ | ៤៩ | ៤៩ | ៤៩ |
| | | | បញ្ចេញ | ៤៥ | ៤៥ | ៤៥ | ៤៥ | ៤៥ | ៤៥ |
| COLBEN | ឯកជន | ប្រេង | តម្លើង | ២០ | ២០ | ២០ | ១៤ | ១៤ | ១៤ |
| | | | បញ្ចេញ | ១០ | ១០ | ១០ | ១០ | ១០ | ១០ |
| គិរីរម្យ ១ | ឯកជន | វារី | តម្លើង | ១២ | ១២ | ១២ | ១២ | ១២ | ១២ |
| | | | បញ្ចេញ | ១១ | ១១ | ១១ | ១១ | ១១ | ១១ |
| គិរីរម្យ ៣ | ឯកជន | វារី | តម្លើង | ១៨ | ១៨ | ១៨ | ១៨ | ១៨ | ១៨ |
| | | | បញ្ចេញ | ១៨ | ១៨ | ១៨ | ១៨ | ១៨ | ១៨ |
| កំចាយ | ឯកជន | វារី | តម្លើង | ១៩៤ | ១៩៤ | ១៩៤ | ១៩៤ | ១៩៤ | ១៩៤ |
| | | | បញ្ចេញ | ១៩៤ | ១៩៤ | ១៩៤ | ១៩៤ | ១៩៤ | ១៩៤ |
| អាតៃ | ឯកជន | វារី | តម្លើង | - | ១២០ | ១២០ | ១២០ | ១២០ | ១២០ |
| | | | បញ្ចេញ | - | ១២០ | ១២០ | ១២០ | ១២០ | ១២០ |
| ឫស្សីជ្រុំក្រោម | ឯកជន | វារី | តម្លើង | - | ៣៣៨ | ៣៣៨ | ៣៣៨ | ៣៣៨ | ៣៣៨ |
| | | | បញ្ចេញ | - | ១៦៩ | ៣៣៨ | ៣៣៨ | ៣៣៨ | ៣៣៨ |
| តាតៃ | ឯកជន | វារី | តម្លើង | - | - | ២៤៦ | ២៤៦ | ២៤៦ | ២៤៦ |
| | | | បញ្ចេញ | - | - | ២៤៦ | ២៤៦ | ២៤៦ | ២៤៦ |
| CEL | ឯកជន | ធ្យូងថ្ម | តម្លើង | - | ១២០ | ១២០ | ១២០ | ១២០ | ១២០ |
| | | | បញ្ចេញ | - | ១០០ | ១០០ | ១០០ | ១០០ | ១០០ |
| សេសាន២ | ឯកជន | វារី | តម្លើង | - | - | - | - | - | ៤០០ |
| | | | បញ្ចេញ | - | - | - | - | - | ៥០ |
| Sunseap | ឯកជន | ព្រះអាទិត្យ | តម្លើង | - | - | - | - | - | ១០ |
| | | | បញ្ចេញ | - | - | - | - | - | ១០ |
| CIIDG | ឯកជន | ធ្យូងថ្ម | តម្លើង | - | - | ២៧០ | ២៧០ | ៤០៥ | ៤០៥ |
| | | | បញ្ចេញ | - | - | ១២៥ | ២៥១ | ៣៧៧ | ៣៧៧ |

## តារាងទី ២ : អានុភាពតម្លើង និងអានុភាពបញ្ចេញពីប្រភពរោងចក្រ និងការនាំចូល (MW)

| ឆ្នាំ | | | | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ |
|---|---|---|---|---|---|---|---|---|---|
| ទីតាំង | | | អានុភាព | | | | | | |
| សុវណ្ណភូមិ | ឯកជន | ធ្យូងថ្ម | តម្លើង | ១០ | ១០ | ១០ | ១០ | ១០ | ១០ |
| | | | បញ្ចេញ | ៧ | ៨ | ៨ | ៨ | ៨ | ៨ |
| ថៃឡង់ដ៍ | នាំចូល | | ព្រមព្រៀង | - | - | ១២០ | ១២០ | ១២០ | ១២០ |
| | | | បញ្ចេញ | - | - | ១២០ | ១២០ | ១២០ | ១២០ |
| វៀតណាម | នាំចូល | | ព្រមព្រៀង | ២០០ | ២០០ | ២០០ | ២០០ | ២០០ | ២០០ |
| | | | បញ្ចេញ | ១៧០ | ១៧០ | ២០០ | ២០០ | ២០០ | ២០០ |
| **អគ្គិសនី ខេត្ត-ក្រុង** | | | **តម្លើង** | **២០៥** | **២០៧** | **២៤៤** | **១១៧** | **១១៧** | **១២៣** |
| | | | **បញ្ចេញ** | **១៩៧** | **១៩៩** | **២៣៦** | **១០៩** | **១០៩** | **១១៥** |
| អគ្គិសនីសៀមរាប | អ.ក | ប្រេង | តម្លើង | ១១ | ១១ | ១១ | ១១ | ១១ | ១១ |
| | | | បញ្ចេញ | ១១ | ១១ | ១១ | ១១ | ១១ | ១១ |
| | នាំចូល | | ព្រមព្រៀង | ៤០ | ៤០ | ៨០ | - | - | - |
| | | | បញ្ចេញ | ៤០ | ៤០ | ៨០ | - | - | - |
| អគ្គិសនីកំពង់ចាម | ឯកជន | ប្រេង | តម្លើង | ៨ | ៨ | ៨ | ៨ | ៨ | ៨ |
| | | | បញ្ចេញ | ៧ | ៧ | ៥ | ៥ | ៥ | ៥ |
| | បណ្តាញជាតិ | | តម្លើង | ២ | ២ | ២ | ២ | ២ | ២ |
| | | | បញ្ចេញ | ២ | ២ | ២ | ២ | ២ | ២ |
| អគ្គិសនីខេត្តព្រះសីហនុ | អ.ក | ប្រេង | តម្លើង | ៦ | ៦ | ៦ | ៦ | ៦ | ៦ |
| | | | បញ្ចេញ | ៥ | ៥ | ៥ | ៥ | ៥ | ៥ |
| | ឯកជន | ប្រេង | តម្លើង | ១៤ | ១៤ | ១៤ | ១៤ | ១៤ | ១៤ |
| | | | បញ្ចេញ | ១០ | ១០ | ១០ | ១០ | ១០ | ១០ |
| អគ្គិសនីតាកែវ | អ.ក | ប្រេង | តម្លើង | ២ | ២ | ២ | ២ | ២ | ២ |
| | | | បញ្ចេញ | ២ | ២ | ២ | ២ | ២ | ២ |
| | បណ្តាញជាតិ | | តម្លើង | ១៦ | ១៦ | ១៦ | - | - | - |
| | | | បញ្ចេញ | ១៦ | ១៦ | ១៦ | - | - | - |
| អគ្គិសនីបាត់ដំបង | អ.ក | ប្រេង | តម្លើង | ៣ | ២ | ២ | ២ | ២ | ២ |
| | | | បញ្ចេញ | ២ | ២ | ២ | ២ | ២ | ២ |
| | បណ្តាញជាតិ | | តម្លើង | ២០ | ២០ | ២០ | - | - | - |
| | | | បញ្ចេញ | ២០ | ២០ | ២០ | - | - | - |
| អគ្គិសនីបន្ទាយមានជ័យ | អ.ក | ប្រេង | តម្លើង | ៣ | ៣ | ៣ | ៣ | ៣ | ៣ |
| | | | បញ្ចេញ | ៣ | ៣ | ៣ | ៣ | ៣ | ៣ |
| | នាំចូល | | ព្រមព្រៀង | ២០ | ២០ | ២០ | - | - | - |
| | | | បញ្ចេញ | ២០ | ២០ | ២០ | - | - | - |
| អគ្គិសនីកំពត | អ.ក | ប្រេង | តម្លើង | ៣ | ៣ | ៣ | ៣ | ៣ | ៣ |
| | | | បញ្ចេញ | ៣ | ៣ | ៣ | ៣ | ៣ | ៣ |
| កំពង់ស្ពឺ | ឯកជន | ជីវម៉ាស់ | តម្លើង | - | - | - | ៦ | ៦ | ៦ |
| | | | បញ្ចេញ | - | - | - | ៦ | ៦ | ៦ |

## តារាងទី ២ : អានុភាពតម្លើង និងអានុភាពបញ្ចេញពីប្រភពរោងចក្រ និងការនាំចូល (MW)

| ឆ្នាំ | | | | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ |
|---|---|---|---|---|---|---|---|---|---|
| ទីតាំង | | | អានុភាព | | | | | | |
| សាខាពញាក្រែក | នាំចូល | | ព្រមព្រៀង | ៥ | ៥ | ៥ | ៥ | ៥ | ៥ |
| | | | បញ្ចេញ | ៥ | ៥ | ៥ | ៥ | ៥ | ៥ |
| សាខាមេមត់ | នាំចូល | | ព្រមព្រៀង | ៥ | ៥ | ៥ | ៥ | ៥ | ៥ |
| | | | បញ្ចេញ | ៥ | ៥ | ៥ | ៥ | ៥ | ៥ |
| សាខាកំពង់ត្រាច | នាំចូល | | ព្រមព្រៀង | ១០ | ១០ | ១០ | ១០ | ១០ | ១០ |
| | | | បញ្ចេញ | ១០ | ១០ | ១០ | ១០ | ១០ | ១០ |
| អគ្គិសនីព្រៃវែង | អ.ក | ប្រេង | តម្លើង | ២ | ២ | ២ | ២ | ២ | ២ |
| | | | បញ្ចេញ | ២ | ២ | ២ | ២ | ២ | ២ |
| | នាំចូល | | ព្រមព្រៀង | ១ | ៣ | ៣ | ៣ | ៣ | ៣ |
| | | | បញ្ចេញ | ១ | ៣ | ៣ | ៣ | ៣ | ៣ |
| អគ្គិសនីស្ទឹងត្រែង | អ.ក | ប្រេង | តម្លើង | ២ | ២ | ២ | ២ | ២ | ២ |
| | | | បញ្ចេញ | ២ | ២ | ២ | ២ | ២ | ២ |
| | នាំចូល | | ព្រមព្រៀង | ៤ | ៤ | ៤ | ៦ | ៦ | ១១,៦៤ |
| | | | បញ្ចេញ | ៤ | ៤ | ៤ | ៦ | ៦ | ១១,៥០ |
| អគ្គិសនីស្វាយរៀង | អ.ក | ប្រេង | តម្លើង | ១ | ១ | ១ | ១ | ១ | ១ |
| | | | បញ្ចេញ | ១ | ១ | ១ | ១ | ១ | ១ |
| | នាំចូល | | ព្រមព្រៀង | ៧ | ៨ | ៨ | ៨ | ៨ | ៨ |
| | | | បញ្ចេញ | ៧ | ៨ | ៨ | ៨ | ៨ | ៨ |
| សាខាបាវិត | នាំចូល | | ព្រមព្រៀង | ១៦ | ១៦ | ១៦ | ១៦ | ១៦ | ១៦ |
| | | | បញ្ចេញ | ១៦ | ១៦ | ១៦ | ១៦ | ១៦ | ១៦ |
| អគ្គិសនីក្រចេះ | អ.ក | ប្រេង | តម្លើង | - | ១ | ១ | ១ | ១ | ១ |
| | | | បញ្ចេញ | - | ១ | ១ | ១ | ១ | ១ |
| | ឯកជន | ប្រេង | តម្លើង | ៣ | ៣ | - | - | - | - |
| | | | បញ្ចេញ | ១ | ១ | - | - | - | - |
| សាខាស្នួល | នាំចូល | | ព្រមព្រៀង | ៤ | ៤ | ៤ | ៥ | ៥ | ៥ |
| | | | បញ្ចេញ | ៤ | ៤ | ៤ | ៥ | ៥ | ៥ |
| **ក្រៅបណ្ដាញជាតិ** | | | **តម្លើង** | **១០** | **១០** | **១៣** | **១៣** | **១៣** | **១១** |
| | | | **បញ្ចេញ** | **១០** | **១០** | **១២** | **១២** | **១២** | **១១** |
| អគ្គិសនីរតនគិរី | ឯកជន | ប្រេង | ព្រមព្រៀង | - | - | ៣ | ៣ | ៣ | ០ |
| | | | បញ្ចេញ | - | - | ១ | ១ | ១ | ០ |
| | អ.ក | វារី | តម្លើង | ១ | ១ | ១ | ១ | ១ | ១ |
| | | | បញ្ចេញ | ១ | ១ | ១ | ១ | ១ | ១ |
| | នាំចូល | | ព្រមព្រៀង | ៧ | ៨ | ៨ | ៨ | ៨ | ៨ |
| | | | បញ្ចេញ | ៧ | ៨ | ៨ | ៨ | ៨ | ៨ |

## តារាងទី ២ : អានុភាពតម្លើង និងអានុភាពបញ្ចេញពីប្រភពរោងចក្រ និងការនាំចូល (MW)

| ឆ្នាំ | | | | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ |
|---|---|---|---|---|---|---|---|---|---|
| **ទីតាំង** | | | **អានុភាព** | | | | | | |
| អគ្គិសនីមណ្ឌលគិរី | អ.ក | ប្រេង/វារី | តម្លើង | ១ | ១ | ១ | ១ | ១ | ១ |
| | | | បញ្ចេញ | ១ | ១ | ១ | ១ | ១ | ១ |
| | នាំចូល | | ព្រមព្រៀង | ១ | ១ | ១ | ១ | ១ | ១ |
| | | | បញ្ចេញ | ១ | ១ | ១ | ១ | ១ | ១ |
| សាខាកែវសីមា | នាំចូល | | ព្រមព្រៀង | 0.៤ | 0.៤ | 0.៤ | 0.៤ | 0.៤ | 0.៤ |
| | | | បញ្ចេញ | 0.៤ | 0.៤ | 0.៤ | 0.៤ | 0.៤ | 0.៤ |
| **សរុប** | | | **តម្លើង** | ៨៤៩ | ១.៤៣៧ | ១.៩៨៥ | ១.៩៧២ | ២.១០៧ | ២.៥២០ |
| | | | **បញ្ចេញ** | ៧៧៨ | ១.១៧៨ | ១.៧៧៩ | ១.៨៩៩ | ២.០២៦ | ២.០៩០ |
| **ជាភាគរយ** , % | | | | ៩២% | ៨២% | ៩០% | ៩៦% | ៩៦% | ៨៣% |




**រូបភាពទី ១ : អានុភាពតម្លើងតាមប្រភេទនៅឆ្នាំ ២០១២ - ២០១៧**

## តារាងទី ៣ : ថាមពលផលិតពីប្រភពរោងចក្រ និងការនាំចូល (GWh)

| ឆ្នាំ / ទីតាំង | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ |
|---|---|---|---|---|---|---|
| **បណ្តាញជាតិ** | **៣.២៨៥** | **៣.៦៦០** | **៤.៤៧៧** | **៥.៦៥៨** | **៦.៥៦៦** | **៧៦០៣** |
| អគ្គិសនីកម្ពុជា | ៥៨ | ៣៦ | ២៦ | ៩ | ៧២ | ៣៥ |
| CUPL | ១៣២ | ៧៣ | ៣៥ | ៥ | - | - |
| គិរីរម្យ ១ | ២៩ | ៤៥ | ៣៩ | ៣៥ | ៤២ | ៤៣ |
| កំចាយ | ៣៩៦ | ៤៦៣ | ៤២៤ | ៣៦៣ | ៤៣៨ | ៤០៦ |
| គិរីរម្យ ៣ | ៨៦ | ៩០ | ៨០ | ៧៩ | ៨២ | ៨៧ |
| អាតៃ | - | ២៦៧ | ៣២៧ | ១០៦ | ២១៤ | ២៤៣ |
| ឫស្សីជ្រុំក្រោម | - | ១៣៨ | ៨៦៦ | ៨៣១ | ៩២៣ | ៩៩៤ |
| តាតៃ | - | - | ១០៤ | ៧៣៦ | ៨៥៩ | ៨៩៩ |
| KEP | ១៩៧ | ១៤០ | ៨០ | ៥១ | ១១៥ | ១១៤ |
| CITY POWER | ១៦ | ១៣ | - | - | - | - |
| CEP | ២០៩ | ១៤៤ | ៩៦ | ៦៦ | ១៦០ | ១០៣ |
| COLBEN | ៣១ | ១៩ | ១១ | ៤ | ១៦ | ៨ |
| S.L Garment | ១០ | ៦ | ១ | ៤ | ៧ | ៥ |
| Sunseap | - | - | - | - | - | ៥ |
| សុវណ្ណភូមិ | ៣៧ | ៣០ | ៤៣ | ៣៤ | ៥២ | ៣៨ |
| CEL | - | ១៣៩ | ៦៥៤ | ៦២០ | ៥៧៤ | ៦៥៥ |
| CIIDG | - | - | ១៦៧ | ១.៤៧៤ | ១.៧៦៦ | ២.៨៧៧ |
| ថៃឡង់ដ៏ | ៧៦ | ៤១៧ | ៣៥០ | ១៣៩ | ១៤៧ | ៨៧ |
| វៀតណាម | ១.១៩៩ | ១.៣២៩ | ៨៧៩ | ៨០៤ | ៧៣៧ | ៧១០ |
| PP Sugar | ១ | ១ | ១០ | ២៣ | ២៣ | ៣៨ |
| សៀមរាប | ២៦៨ | ៤ | ៥ | ៤ | ៨ | ២ |
| ព្រះសីហនុ | ៩០ | ២៥ | ៩ | ៣ | ១១ | ០ |
| កំពង់ចាម | ៥៧ | ៣២ | ៨ | ០,២ | ២ | ០ |
| តាកែវ | ២៦ | ០,០៣ | ០,០២ | ០,០២ | ០,០១ | ០,០១ |
| បាត់ដំបង | ១០៦ | ០,០១ | ០,០១ | ០,០១ | ០,០១ | ០,០១ |
| កំពត | ១៤ | ១២ | ១៥ | ១២ | ២៣ | ០,០៨ |
| បន្ទាយមានជ័យ | ៤០ | ០,១៦ | ០,០៤ | ០,០៤ | ០,១ | ០,០៨ |
| ពញាក្រែក | ៤០ | ៣៩ | ៣០ | ២២ | ២៣ | ២៦ |
| មេមត់ | ១៤ | ១៦ | ១៦ | ១៩ | ២២ | ២៥ |
| កំពង់ត្រាច | ១៧ | ១៧ | ១៣ | ៧ | ១៤ | ១៧ |
| ព្រៃវែង | ១២ | ១៥ | ១៣ | ៩ | ៥ | ២ |
| ស្ទឹងត្រែង | ៩ | ១១ | ១៤ | ១៨ | ៣៥ | ៥៤ |
| ស្វាយរៀង | ២៧ | ៣៣ | ១៣៧ | ១៥៥ | ១៦៤ | ១១០ |
| បាវិត | ៧៤ | ៨៧ | - | - | - | ០ |
| ក្រចេះ | ៧ | ១០ | ១៥ | ១៥ | ២០ | ១៣,៨ |
| ស្នួល | ៧ | ៩ | ១០ | ១១ | ១២ | ៧ |

## តារាងទី ៣ : ថាមពលផលិតពីប្រភពរោងចក្រ និងការនាំចូល ( GWh ) ( ត )

| ឆ្នាំ / ទីតាំង | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ |
|---|---|---|---|---|---|---|
| **ក្រៅបណ្ដាញជាតិ** | **២១** | **២៨** | **៣៥** | **៤២** | **៤៧** | **៦២** |
| មណ្ឌលគិរី | ៣ | ៣ | ៤ | ៥ | ៦ | ៧ |
| កែវសីមា | ១ | ២ | ៣ | ៤ | ៤ | ៤,២ |
| រតនគិរី | ១៧ | ២៣ | ២៨ | ៣៣ | ៣៧ | ៥១ |
| **សរុប** | **៣.៣០៦** | **៣.៦៨៨** | **៤.៥១២** | **៥.៧០០** | **៦.៦១៣** | **៧.៦៦៥** |

## តារាងទី ៤ : ការផលិតថាមពលតាមប្រភេទក្នុងឆ្នាំ ២០១៧ ( GWh )

| ទីតាំង | | ប្រេងឥន្ធនៈ | វារីអគ្គិសនី | ជីវម៉ាស់ | ធ្យូងថ្ម | ពន្លឺព្រះអាទិត្យ | នាំចូល | សរុប |
|---|---|---|---|---|---|---|---|---|
| **បណ្ដាញជាតិ** | | **២៣៩** | **២.៦៩៨** | **៤២** | **៣.៥៦៩** | **៥** | **១.០៥០** | **៧.៦០៣** |
| ភ្នំពេញ | អ.ក | ៣៥ | - | - | - | - | - | ៣៥ |
| | ផ.ឯ | ២០២ | ២.៦៩៨ | ៤២ | ៣.៥៦៩ | ៥ | ៧៩៦ | ៧.៣១២ |
| កំពង់ស្ពឺ | | - | - | - | - | - | - | - |
| សៀមរាប | | ២ | - | - | - | - | - | ២ |
| ព្រះសីហនុ | | ០ | - | - | - | - | - | ០ |
| កំពង់ចាម | | - | - | - | - | - | - | - |
| តាកែវ | | ០,០១ | - | - | - | - | - | ០,០១ |
| បាត់ដំបង | | ០,០១ | - | - | - | - | - | ០,០១ |
| កំពត | | ០,០៨ | - | - | - | - | ១៧ | ១៧,០៨ |
| បន្ទាយមានជ័យ | | ០,០៨ | - | - | - | - | - | ០,០៨ |
| ពញាក្រែក | | - | - | - | - | - | ២៦ | ២៦ |
| មេមត់ | | - | - | - | - | - | ២៤,៣ | ២៤,៣ |
| កំពង់ត្រាច | | - | - | - | - | - | ១៧ | ១៧ |
| ព្រៃវែង | | ០,០៥ | - | - | - | - | ០,០៥ | ២,០៥ |
| ស្វឹងត្រែង | | ០,០៥ | - | - | - | - | ៥៤ | ៥៤,០៥ |
| ស្វាយរៀង | | ០,០២ | - | - | - | - | ១១០ | ១១០,០២ |
| ក្រចេះ | | ០,០១ | - | - | - | - | ១៣,៨២ | ១៣,៨៣ |
| ស្ទួល | | - | - | - | - | - | ៧ | ៧ |
| **ក្រៅបណ្ដាញ** | | **០,០៦** | **៦** | - | - | - | **៥៦,១៧** | **៦២,២៣** |
| មណ្ឌលគិរី | | ០,០៦ | ២ | - | - | - | ៥ | ៧,០៦ |
| កែវសីមា | | - | - | - | - | - | ៤,១៧ | ៤,១៧ |
| រតនគិរី | | - | ៤ | - | - | - | ៤៧ | ៥១ |
| **សរុប** | | **២៣៩** | **២.៧០៤** | **៤២** | **៣.៥៦៩** | **៥** | **១.១០៦** | **៧.៦៦៥** |




រូបភាពទី២ : ការផលិតថាមពលតាមប្រភេទ នៅឆ្នាំ២០១៧

## តារាងទី ៥ : អានុភាពអតិបរមាតាមខេត្ត-ក្រុង (MW)

| ទីតាំង | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ |
|---|---|---|---|---|---|---|
| បណ្តាញជាតិ | ៥០៨ | ៦២៥ | ៧៨៤ | ៩៥១ | ១.០៦៨ | ១.២៦៩ |
| ភ្នំពេញ | ៤១០ | ៤៩៣ | ៥៦៣ | ៦៧៤ | ៧៥៧ | ៧៧៧ |
| សៀមរាប | ៤៧ | ៥៧ | ៥៩ | ៦៨ | ៨៣ | ៨៩ |
| ព្រះសីហនុ | ១៩ | ២៥ | ៣០ | ៤០ | ៤៦ | ៦៨ |
| កំពង់ចាម | ១០ | ១៧ | ១៤ | ២២ | ៣២ | ៣៦ |
| ពញាក្រែក | ៧ | ៧ | ៦ | ៤ | ៤ | ៧ |
| មេមត់ | ៤ | ៥ | ៤ | ៧ | ៧ | ៦ |
| តាកែវ | ៧ | ៩ | ១៨ | ២០ | ២៣ | ២១ |
| បាត់ដំបង | ២១ | ២៣ | ២៦ | ៤៧ | ៦៥ | ៧១ |
| កំពត | ៥ | ៦ | ១៣ | ១៨ | ១៦ | ១៥ |
| កំពង់ត្រាច | ៣ | ៣ | ៣ | ៥ | ៣ | ៣ |
| ព្រៃវែង | ៣ | ៣ | ៨ | ១៤ | ១៥ | ២១ |
| បន្ទាយមានជ័យ | ៩ | ១១ | ១៩ | ២៣ | ២៤ | ២៦ |
| ស្ទឹងត្រែង | ៣ | ៤ | ៥ | ៣ | ៨ | ១២ |
| រតនគិរី | ៤ | ៤ | ៥ | ៦ | ៧ | ១៣ |
| ស្វាយរៀង | ៥ | ៧ | ៨ | ១២ | ៣០ | ១៩ |
| បារិត | ១៥ | ១៦ | ១៧ | ១៧ | ១៦ | ២៧ |
| មណ្ឌលគិរី | ១ | ១ | ១ | ១ | ២ | ៤ |
| កែវសីមា | 0,៤ | 0,៥ | ១ | ១ | ១ | ១ |
| ក្រចេះ | ១ | ២ | ៣ | ៣ | ៨ | ៩ |
| ស្នួល | ១ | ១ | ២ | ២ | ៣ | ២ |
| កំពង់ស្ពឺ | - | - | - | ៣៨ | ៤២ | ៤៦ |

## តារាងទី ៦ : ថាមពលលក់តាមខេត្ត-ក្រុង ( GWh )

| ទីតាំង | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ |
|---|---|---|---|---|---|---|
| ភ្នំពេញ | ២.២៦៦ | ២.៥៣១ | ២.៩៥៦ | ៣.៧៤៨ | ៤.២៨៩ | ៤.៨០៧ |
| សៀមរាប | ២៣៧ | ២៧០ | ៣១៩ | ៣៧៦ | ៤៤៧ | ៥១១ |
| ព្រះសីហនុ | ៨០ | ៩៦ | ១៤១ | ១៨៦ | ២៣២ | ៣០៩ |
| កំពង់ចាម | ៥២ | ៤៤ | ៤៣ | ៦៨ | ៧៥ | ៩៤ |
| ពញាក្រែក | ៣៨ | ៣៧ | ២៩ | ២៣ | ២៣ | ២៦ |
| មេមត់ | ១៣ | ១៥ | ១៥ | ១៩ | ២៣ | ២៣ |
| តាកែវ | ២៤ | ៣៧ | ៥៤ | ៩០ | ៩៤ | ៨៨ |
| បាត់ដំបង | ៩៩ | ១២៧ | ១៦១ | ២២២ | ២៧៨ | ៣៤៦ |
| កំពត | ៤៩ | ២៩ | ៤៤ | ៨១ | ៩៧ | ១១០ |
| កំពង់ត្រាច | ១៧ | ១៦ | ១៣ | - | - | - |
| ព្រៃវែង | ១១ | ១៤ | ២០ | ៤២ | ៤៥ | ៧៤ |
| បន្ទាយមានជ័យ | ៣៦ | ៤៧ | ៧១ | ១០៦ | ១១០ | ១១៨ |
| ស្ទឹងត្រែង | ៨ | ១០ | ១២ | ១៦ | ៣៥ | ៤៤ |
| រតនគិរី | ១៦ | ២១ | ២៦ | ៣១ | ៣៥ | ៤៥ |
| ស្វាយរៀង | ២៤ | ២៦ | ១២៩ | ១៥៩ | ១៨៦ | ២២៩ |
| បាវិត | ៧១ | ៨៧ | - | - | - | - |
| មណ្ឌលគិរី | ៣ | ៣ | ៤ | ៥ | ៦ | ៨ |
| កែវសីមា | ១ | ២ | ៣ | ៣ | ៤ | ៤ |
| ក្រចេះ | ៦ | ១០ | ១៥ | ១៨ | ២៨ | ៣៦ |
| ស្នួល | ៦ | ៨ | ១១ | ១០ | ៩ | ១០ |
| កំពង់ស្ពឺ | ៤២ | ៥២ | ៨៤ | ១៣៧ | ៩៤ | ១១១ |
| **សរុប** | **៣.០៩៨** | **៣.៤៨៤** | **៤.១៥២** | **៥.៣៤១** | **៦.១១០** | **៦.៩៩៤** |




រូបភាពទី៣ : ថាមពលលក់តាមប្រភេទអតិថិជនសម្រាប់ប្រព័ន្ធអគ្គិសនីកម្ពុជានៅឆ្នាំ ២០១៧

# មធ្យោបាយផលិតថាមពល និងការផ្គត់ផ្គង់ថាមពលអគ្គិសនី




រូបភាពទី៤ : ខ្សែកោងបន្ទុកប្រើប្រាស់អតិបរមាពីឆ្នាំ ២០១២-២០១៧ ក្នុងបណ្តាញជាតិ




រូបភាពទី៥ : ថាមពលបាត់បង់លើប្រព័ន្ធបណ្តាញចែកចាយពីឆ្នាំ ២០១២-២០១៧

## តារាងទី ៧ : ចំនួនអតិថិជនតាមខេត្ត-ក្រុងពីឆ្នាំ ២០១២ - ២០១៧

| ទីតាំង | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ |
|---|---|---|---|---|---|---|
| ភ្នំពេញ | ២៧៦.៣០៧ | ២៩៩.៧៧៤ | ៣១៩.៤២៣ | ៥២២.៥១៧ | ៦១០.៥៨២ | ៦៥២.៨៥៨ |
| សៀមរាប | ២៨.៧៩១ | ៣២.៧២៥ | ៣៦.៦៩៤ | ៤០.៩៤៩ | ៤៨.៤៨២ | ៦១.៧៤៥ |
| ព្រះសីហនុ | ១២.២៤៦ | ១៣.១៤៦ | ១៤.២៣៨ | ១៥.៩៧៥ | ១៧.៩៣០ | ២០.១៥៧ |
| កំពង់ចាម | ១២.២៣៩ | ១៣.០០៣ | ១៤.៨៧៦ | ១៦.៩៩៩ | ១៩.៤៣៦ | ២១.៣៤១ |
| ពញាក្រែក | ២.៦៩៤ | ២.៨៤៩ | ២.៩៩៦ | ៣.៩៥៨ | ៦.៦៤៤ | ៧.៤០១ |
| មេមត់ | ៤.៩៩២ | ៥.៣២១ | ៥.៥៩១ | ៧.៦០៨ | ៨.៦៥២ | ១១.៣២៩ |
| តាកែវ | ១១.២០១ | ១៣.០៨១ | ១៥.៦៣៦ | ២០.២០៣ | ២១.៨៩៩ | ២៣.៧៣២ |
| បាត់ដំបង | ៣៨.៤៩៨ | ៤០.៧៣៥ | ៤២.៣៣៦ | ៤៥.២១៦ | ៤៧.៨៩៩ | ៥០.០៩៣ |
| កំពត | ៩.៣៣២ | ១០.៥៥៩ | ១១.២៣៤ | ១១.៩៨៩ | ១៣.១២៨ | ១៤.២៤៩ |
| កំពង់ត្រាច | ២.៨៣១ | ៣.៤៩៩ | ៣.៦៧០ | ៤.១៧៦ | ៥.៧៥៩ | ៦.៦៥១ |
| ព្រៃវែង | ៥.៥៣៨ | ៥.៧៩០ | ៦.១១០ | ៦.៤៩៧ | ៦.៧៤២ | ៧.១២៩ |
| បន្ទាយមានជ័យ | ១៧.២១៣ | ១៨.០២២ | ១៩.២១៧ | ២១.១៨៦ | ២២.៣៤៨ | ២៣.៥៦៨ |
| ស្ទឹងត្រែង | ៣.៥៦៣ | ៤.៦៦៨ | ៥.៧៨២ | ៦.២៨០ | ៧.៤៤៨ | ៩.៥០៣ |
| រតនគិរី | ៣.៥៣៨ | ៤.២៣៣ | ៤.៧២២ | ៥.២៣៥ | ៦.៥០៣ | ៨.០៧៥ |
| ស្វាយរៀង | ១០.២៩៨ | ១២.៤៧៤ | ១៣.៨៩២ | ១៣.៩៦៨ | ១៩.៩៦២ | ២៧.៨១១ |
| បារិត | ៤.៥១៨ | ៣.១៧៤ | ៣.៨០២ | ៦.៧៤២ | ៤.៤៦៥ | ៥.០៤៣ |
| មណ្ឌលគិរី | ១.៧១៩ | ២.០៧០ | ២.១៩៥ | ២.៣៤៨ | ២.៦៩២ | ៣.៧៣៥ |
| កែវសីមា | ១.២០២ | ១.៣៣៧ | ១.៥៥៤ | ១.៧៥៣ | ១.៩២៦ | ៣.៨២៥ |
| ក្រចេះ | ៣.៦៣២ | ៤.៤០៤ | ៤.៧៧៦ | ៦.៧០៧ | ៨.៤៤២ | ១០.១១៥ |
| ស្ទួល | ១.០៩៤ | ១.១៦៧ | ១.២៣៨ | ១.៣១១ | ១.៨២៧ | ២.៥៧៦ |
| កំពង់ស្ពឺ | ៩.៥៤៧ | ១០.៨២៨ | ១១.១៥៩ | ១២.៩៩៦ | ១៤.៤០៩ | ១៦.៤១០ |
| **សរុប** | **៤៦០.៩៩៣** | **៥០២.៨៥៩** | **៥៤១.១៤១** | **៧៧៤.៦១៣** | **៨៩៧.១៧៥** | **៩៨៧.៣៤៦** |




## រូបភាពទី ៦ : ប្រភេទអតិថិជននៅឆ្នាំ ២០១៧

# ខ្សែបណ្តាញបញ្ជូន

ខ្សែបណ្តាញបញ្ជូន គឺជាសរសៃឈាម ដែលមានតួនាទីយ៉ាងសំខាន់ ក្នុងការបញ្ជូនថាមពលពីរោងចក្រអគ្គិសនី ទៅកាន់អនុស្ថានីយនានា។ ខ្សែបណ្តាញបញ្ជូនរបស់អគ្គិសនីកម្ពុជា ត្រូវបានបែងចែកជាពីរប្រភេទគឺ ៖ ២៣០ គីឡូវ៉ុល និង ១១៥ គីឡូវ៉ុល។





## ខ្សែបណ្តាញបញ្ជូន



ខ្សែបញ្ជូន ១១៥kV លើកទីមួយមានប្រវែង ២៣ km ដែលតភ្ជាប់ពីអនុស្ថានីយចំនួនបី (អនុស្ថានីយទី១ អនុស្ថានីយទី២ និងអនុស្ថានីយទី៣) នៅក្នុងប្រព័ន្ធបណ្តាញរាជធានីភ្នំពេញ បានផ្គត់ផ្គង់ថាមពលក្នុងឆ្នាំ ១៩៩៩។ នៅឆ្នាំ២០០២ មានខ្សែបញ្ជូន ១១៥ kV បន្ថែមមួយទៀត ដែលមានប្រវែង ១១១ km ត្រូវបានសាងសង់ ដើម្បីតភ្ជាប់ពីរោងចក្រវារីអគ្គិសនីគិរីរម្យ ១ មកកាន់អនុស្ថានីយទី១។ គោលបំណងដ៏ចម្បងនៃខ្សែបញ្ជូនដែលមានតង់ស្យុង ១១៥ kV ព័ទ្ធជុំវិញរាជធានីភ្នំពេញ គឺដើម្បីផ្គត់ផ្គង់អគ្គិសនីឲ្យតំបន់រាជធានីភ្នំពេញ និងបង្កើនស្ថិរភាពលើប្រព័ន្ធផ្គត់ផ្គង់ថាមពលក្នុងរាជធានីភ្នំពេញនេះ ដោយតភ្ជាប់ទៅវិញទៅមករវាងអនុស្ថានីយចំនួនបី។

ខេត្តចំនួនបី ស្ថិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា មានខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប បានផ្គត់ផ្គង់ថាមពលដោយខ្សែបញ្ជូន ១១៥ kV មានប្រវែង ១៨៥ km ដោយនាំចូលថាមពលពីប្រទេសថៃឡង់ដ៏ និងបានដាក់ឲ្យដំណើរការនៅចុងឆ្នាំ២០០៧។

នៅឆ្នាំ ២០០៩ ខ្សែបញ្ជូនតង់ស្យុង ២៣០ kV ជាលើកដំបូងក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ដែលមានប្រវែង ៩៧ km បានដាក់ឲ្យបម្រើសេវាកម្មផ្គត់ផ្គង់ ដែលនាំថាមពលពីប្រទេសវៀតណាម ដើម្បីផ្គត់ផ្គង់ថាមពលទៅអនុស្ថានីយតាកែវ និងអនុស្ថានីយខាងលិចភ្នំពេញ (អនុស្ថានីយទី៤)។ ប្រព័ន្ធខ្សែបញ្ជូន ១១៥ kV ដែលតភ្ជាប់អនុស្ថានីយខាងលិចភ្នំពេញ (អនុស្ថានីយទី៤) ទៅភ្ជាប់អនុស្ថានីយទី១ និងអនុស្ថានីយទី២ នៅរាជធានីភ្នំពេញ ត្រូវបានសាងសង់រួច និងដាក់ឲ្យដំណើរការក្នុងឆ្នាំ២០០៩។

នៅឆ្នាំ២០១១ ខ្សែបញ្ជូនតង់ស្យុង ២៣០ kV ដែលមានប្រវែង ៧៣ km ត្រូវបានពង្រីកចេញពីអនុស្ថានីយតាកែវទៅអនុស្ថានីយកំពត និងតភ្ជាប់ទៅរោងចក្រវារីអគ្គិសនីកំចាយ តាមខ្សែបញ្ជូន ២៣០ kV មួយទៀត ដែលមានប្រវែង ១១ km ក៏ត្រូវបានដាក់ឲ្យដំណើរការផងដែរនៅចុងឆ្នាំ ២០១១។



ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០ kV ពីរាជធានីភ្នំពេញទៅខេត្តបាត់ដំបងត្រូវបានចាប់ផ្តើមដាក់ឲ្យដំណើរការក្នុងខែមេសា ឆ្នាំ ២០១២ ដែលមានប្រវែង ៣០០ km និងខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០ kV មួយខ្សែទៀត ពីអនុស្ថានីយអូរសោម (ខេត្តកោះកុង) ទៅអនុស្ថានីយខេត្តពោធិ៍សាត់ ស្ថិតក្រោមគម្រោងសាងសង់ដំណើរការ និងផ្ទេរ (BOT) ដែលមានប្រវែង ១៣០ km កំពុងសាងសង់ ។ ការសាងសង់ខ្សែបណ្តាញ ១១៥ kV ចេញពីអនុស្ថានីយ ២៣០/១១៥/២២ kV របស់ក្រុមហ៊ុន CPG ទៅភ្ជាប់ជាមួយអនុស្ថានីយ ១១៥ kV របស់ក្រុមហ៊ុន CPTL បានដាក់ឲ្យប្រើប្រាស់នៅថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១២ ដែលផ្តល់លទ្ធភាពឲ្យបណ្តាញជាតិបញ្ជូនមានសមត្ថភាពពង្រីក





វិសាលភាព គ្របដណ្តប់ពីផ្នែកមួយនៃបណ្តាញភាគខាងត្បូង (រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តកំពត និងខេត្តកែប) ទៅកាន់បណ្តាញភាគខាងជើងឆៀងខាងលិច ( ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប) កាត់តាមខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់។

នៅឆ្នាំ ២០១៣ ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០ kV ពីខេត្តកំពតទៅខេត្តព្រះសីហនុ ស្ថិតក្រោមប្រាក់កម្ចីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន(JICA) មានប្រវែង ៨៨ km និងខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០ kV មួយខ្សែទៀតពីភ្នំពេញទៅខេត្តកំពង់ចាម ដែលមានប្រវែង ១១០ km ត្រូវបានដាក់ឲ្យដំណើរការ។ គម្រោងទាំងនេះ បានធ្វើឲ្យបណ្តាញជាតិគ្របដណ្តប់លើខេត្តចំនួន ២ បន្ថែមទៀតរួមមាន ខេត្តព្រះសីហនុ និងខេត្តកំពង់ចាម។

នៅឆ្នាំ ២០១៤ ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ១១៥ kV ពីអនុស្ថានីយស្ទឹងហាវ ទៅអនុស្ថានីយខេត្តព្រះសីហនុ ស្ថិតក្រោមប្រាក់កម្ចី

របស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) មានប្រវែង ១១ km និងខ្សែបញ្ជូនតង់ស្យុងខ្ពស់ ១១៥ kV ពីអនុស្ថានីយឈូកទៅអនុស្ថានីយបន្ទាយមាស ក្រោមថវិការបស់អគ្គិសនីកម្ពុជា ដែលមានប្រវែង ១២ km ព្រមទាំងខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០ kV ក្នុងគម្រោងខ្សែបញ្ជូនកងជុំវិញរាជធានីភ្នំពេញ ដែលភ្ជាប់ពីអនុស្ថានីយទី៦ ទៅអនុស្ថានីយទី៥ ដែលមានប្រវែង ៤៨ km ស្ថិតក្រោមប្រាក់កម្ចីរបស់ធនាគារចិនអាហរ័ណនីហរ័ណ ត្រូវបានដាក់ឲ្យដំណើរការជាស្ថាពរ។

នៅឆ្នាំ២០១៥ ខ្សែបញ្ជូន ១១៥ kV ពីអនុស្ថានីយទី៧ មកអនុស្ថានីយទី២ ក្នុងគម្រោងខ្សែបញ្ជូនកងតង់ស្យុងខ្ពស់ជុំវិញរាជធានីភ្នំពេញស្ថិតក្រោមប្រាក់កម្ចីធនាគារចិនអាហរ័ណនីហរ័ណ ត្រូវបានបញ្ចប់ការសាងសង់ និងដាក់ឲ្យដំណើរការ ដើម្បីធានាឲ្យបាននូវការបង្កើនភាពជឿជាក់ខ្ពស់លើប្រភពថាមពលនៅតំបន់ភាគខាងត្បូងនៃរាជធានីភ្នំពេញ ។ខ្សែបញ្ជូនតភ្ជាប់ថ្មីពីអនុស្ថានីយបានហាត ខេត្តចម្ប៉ាសាក់ ប្រទេសឡាវ ទៅស្រុកកំពង់ស្រឡៅ ខេត្តព្រះវិហារ ប្រទេសកម្ពុជា ត្រូវបានរៀបចំ និងសាងសង់សម្រាប់ខ្សែបញ្ជូនតង់ស្យុង ១១៥ kV ប៉ុន្តែបញ្ជូនថាមពលអគ្គិសនីនៅកម្រិតតង់ស្យុង ២២ kV សម្រាប់ដំណាក់កាលដំបូង រហូតដល់ខ្សែបញ្ជូនពីព្រំប្រទល់ឡាវ ទៅអនុស្ថានីយជ័យសែន សាងសង់រួចរាល់។

នៅឆ្នាំ២០១៦ ខ្សែបញ្ជូនតង់ស្យុងខ្ពស់ពីរាជធានីភ្នំពេញ ទៅក្រុងបាវិត ខេត្តស្វាយរៀង និងពីខេត្តកំពង់ចាម ទៅខេត្តក្រចេះ ខេត្តស្ទឹងត្រែង និងភ្ជាប់បន្តទៅរោងចក្រវារីអគ្គិសនីសេសានក្រោម២ ដែលមានប្រវែងសរុបប្រមាណ ៤២៦ km បាននឹងកំពុងស្ថិតក្រោមការសាងសង់។ គម្រោងទាំងនោះ រំពឹងថានឹងត្រូវបានសាងសង់រួចរាល់ជាស្ថាពរនៅចុងឆ្នាំ ២០១៧។

គម្រោងខ្សែបញ្ជូនជុំវិញបឹងទន្លេសាប ដែលតភ្ជាប់ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តកំពង់ធំ កំពង់ចាមនិងគម្រោងខ្សែបញ្ជូនកងជុំវិញរាជធានីភ្នំពេញដំហានទី២(ខាងជើងភ្នំពេញ-ជ្រោយចង្វារ-ខាងកើតភ្នំពេញ-ខាងត្បូងភ្នំពេញ )និងគម្រោងខ្សែបញ្ជូនមួយទៀត ដែលតភ្ជាប់ខេត្តកំពង់ធំ ខេត្តព្រះវិហារ និងព្រំប្រទល់ប្រទេសឡាវ កំពុងស្ថិតក្រោមការសិក្សា។ គម្រោងទាំងនេះ ទទួលបានមូលនិធិពីធនាគារចិនអាហរ័ណនីហរ័ណ ។

គម្រោងពង្រីកខ្សែបណ្ដាញបញ្ជូន ក្នុងខេត្តកោះកុង និងពីខេត្តកំពង់ចាម និងខេត្តក្រចេះ ដែលផ្ដល់ហិរញ្ញប្បទានឥណទានដោយទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ហៅកាត់ថា AFD ត្រូវបានធ្វើការសិក្សាសមិទ្ធលទ្ធភាព និងរៀបចំដេញថ្លៃ ។ ការចាប់ផ្ដើមសិក្សាគម្រោង និងចរចាលើខ្សែបញ្ជូនតង់ស្យុងខ្ពស់ ១១៥ kV ពីអនុស្ថានីយកំពង់សឺង្ហ ទៅអនុស្ថានីយថ្មីស្វាយអន្ទរ និងពីអនុស្ថានីយព្រះសីហនុ ទៅអនុស្ថានីយថ្មីរាម ដែលមានប្រវែងសរុបប្រមាណ ៦២ km និងគម្រោងខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ២៣០ kV ជាកង នៅភាគខាងកើតនៃប្រព័ន្ធបណ្ដាញជាតិ ផ្នែកទី១ ដែលគ្រោងនឹងសាងសង់ពីខេត្តស្ទឹងត្រែងទៅខេត្តរតនគិរី និងពីខេត្តក្រចេះទៅខេត្តមណ្ឌលគិរី មានប្រវែងសរុបប្រមាណ ២៧៥ km។

នៅឆ្នាំ២០១៧ ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០ kV ដែលភ្ជាប់ពីរោងចក្រផលិតអគ្គិសនីសេសានក្រោម២ មកអនុស្ថានីយស្ទឹងត្រែង និងភ្ជាប់បន្តទៅអនុស្ថានីយក្រចេះ និងអនុស្ថានីយកំពង់ចាម ត្រូវបានដាក់ឲ្យដំណើរការ ដើម្បីបញ្ជូនថាមពលអោយអស់ពីលទ្ធភាពទៅកាន់ប្រព័ន្ធបណ្ដាញជាតិ ដែលអនុញ្ញាតឲ្យខេត្តក្រចេះ និងស្ទឹងត្រែងមានលទ្ធភាពគ្រប់គ្រាន់ក្នុងការស្រូបយកថាមពលដោយផ្ទាល់ពីប្រព័ន្ធបណ្ដាញជាតិ ជាពិសេសតាមរយៈខ្សែបញ្ជូននេះ ក៏បានបញ្ជូនថាមពលមួយភាគធំមកកាន់រាជធានីភ្នំពេញ ដែលជាទីតាំងសំខាន់នៃបណ្ដុំពាណិជ្ជកម្ម ឧស្សាហកម្ម និងការអភិវឌ្ឍន៍ ដែលកំពុងត្រូវការថាមពលអគ្គិសនីដ៏ច្រើនលើសលប់នាពេលបច្ចុប្បន្នក៏ដូចជានៅពេលអនាគត។

ការដាក់ឲ្យដំណើរការខ្សែបញ្ជូនតង់ស្យុងខ្ពស់ ១១៥ kV ប្រវែងជាង ១៤៥ km ដែលភ្ជាប់ពីអនុស្ថានីយទី៧ ទៅអនុស្ថា-នីយកំពង់សឺង្ហ រួចបន្តភ្ជាប់ទៅអនុស្ថានីយប្រេកម្ទេស បានធ្វើឲ្យខេត្តព្រៃវែង និងខេត្តស្វាយរៀង អាចស្រូបយកថាមពលដោយផ្ទាល់ពីប្រព័ន្ធបណ្ដាញជាតិ ដែលធ្វើឲ្យខេត្តទាំងពីរមានឯករាជ្យភាពក្នុងការផ្គត់ផ្គង់អគ្គិសនី ព្រមទាំអាចកាត់បន្ថយការនាំចូលប្រភពថាម-ពលពីប្រទេសវៀតណាមបានមួយភាគធំ ។

## តារាងទី ៨ : ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ១១៥ kV

| I | ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ១១៥ kV | ចំនួនសៀគ្វី | មុខកាត់ខ្សែ (mm2) | ប្រវែងខ្សែ (km) | ឆ្នាំដំណើរការ | ប្រភពទុន |
|---|---|---|---|---|---|---|
| ១ | អនុស្ថានីយទី ១ - អនុស្ថានីយទី ៣ | ១ | ២x២៥០ | ១២ | ១៩៩៩ | ធនាគារពិភពលោក |
| ២ | អនុស្ថានីយទី ៣ - អនុស្ថានីយទី ២ | ១ | ២x២៥០ | ១២ | ១៩៩៩ | ធនាគារពិភពលោក |
| ៣ | អនុស្ថានីយទី១ - អនុស្ថានីយកំពង់ស្ពឺ | ១ | ១៥០ | ៤១ | ២០០២ | BOT |
| ៤ | អនុស្ថានីយកំពង់ស្ពឺ - គិរីរម្យ ១ | ១ | ១៥០ | ៦៥ | ២០០២ | BOT |
| ៥ | ព្រំដែនថៃ - អនុស្ថានីយ IE | ២ | ៤០០ | ៤ | ២០០៧ | BOT |
| ៦ | អនុស្ថានីយ IE - អនុស្ថានីយបន្ទាយមានជ័យ | ២ | ៤០០ | ៤៣ | ២០០៧ | BOT |
| ៧ | អនុស្ថានីយបន្ទាយមានជ័យ-អនុស្ថានីយសៀមរាប | ១ | ៤០០ | ៨៥ | ២០០៧ | BOT |
| ៨ | អនុស្ថានីយបន្ទាយមានជ័យ - អនុស្ថានីយ បាត់ដំបង | ១ | ៤០០ | ៥៣ | ២០០៧ | BOT |
| ៩ | អនុស្ថានីយទី៤ - អនុស្ថានីយទី១ | ១ | ២x២៥០ | ៣០ | ២០០៩ | ធនាគារពិភពលោក |
| ១០ | អនុស្ថានីយទី៤ - KEP | ១ | ២x២៥០ | ២៣ | ២០០៩ | ធនាគារពិភពលោក |
| ១១ | KEP - អនុស្ថានីយទី ២ | ១ | ២x២៥០ | ៧ | ២០០៩ | ធនាគារពិភពលោក |
| ១២ | គិរីរម្យ ១ - គិរីរម្យ ៣ | ១ | ១៥០ | ៣២ | ២០១២ | BOT |
| ១៣ | រោងចក្រវារីអគ្គិសនីស្ទឹងអាតៃ - អនុស្ថានីយអូរសោម | ២ | ៦៣០ | ១៨ | ២០១៣ | BOT |
| ១៤ | អនុស្ថានីយស្ទឹងហាវ - អនុស្ថានីយខេត្តព្រះសីហនុ | ២ | ៤០០ | ១១ | ២០១៤ | JICA |
| ១៥ | អនុស្ថានីយឈូក - អនុស្ថានីយបន្ទាយមាស | ១ | ៤០០ | ១២ | ២០១៤ | អគ្គិសនីកម្ពុជា |
| ១៦ | ខ្សែបញ្ជូនកងជុំវិញរាជធានីភ្នំពេញ | ២ | ២ x ២៥០ | ៤៥ | ២០១៥ | ធនាគារចិន អាហរណ៍នីហរណ៍ |
| ១៧ | អនុស្ថានីយសៀមរាប - អនុស្ថានីយសៀមរាបថ្មីខាងកើត | ១ | ៤០០ | ២៥ | ២០១៦ | BOT |
| ១៨ | ព្រំប្រទល់ឡាវ - អនុស្ថានីយព្រះវិហារទី១ | ២ | ២៤០ | ៦០ | ២០១៧ | ADB |
| ១៩ | អនុស្ថានីយទី៧ (ខាងត្បូងភ្នំពេញ) - អនុស្ថានីយកំពង់សឹង - អនុស្ថានីយប្រកម្មេស | ២ | ២ x ២៤០ | ១៦០ | ២០១៧ | ធនាគារចិន អាហរណ៍នីហរណ៍ |
| ២០ | អនុស្ថានីយបាត់ដំបង-អនុស្ថានីយតេនមណ្ឌល | ២ | ៤០០ | ៣៥ | ២០១៧ | អគ្គិសនីកម្ពុជា |

## តារាងទី ៩ : ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០ kV

| II | ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០kV | ចំនួនសៀគ្វី | មុខកាត់ខ្សែ (mm2) | ប្រវែងខ្សែ (km) | ឆ្នាំដំណើរការ | ប្រភពទុន |
|---|---|---|---|---|---|---|
| ១ | ព្រំដែនវៀតណាម - អនុស្ថានីយតាកែវ | ២ | ៤០០ | ៥០ | ២០០៩ | ADB - NDF |
| ២ | អនុស្ថានីយតាកែវ - អនុស្ថានីយទី៤ | ២ | ៦៣០ | ៤៧ | ២០០៩ | ADB - NDF |
| ៣ | អនុស្ថានីយតាកែវ - អនុស្ថានីយកំពត | ២ | ៤៥០ | ៧៣ | ២០១១ | KFW |
| ៤ | អនុស្ថានីយកំពត - រោងចក្រវារីអគ្គិសនីកំចាយ | ២ | ៤០០ | ១១ | ២០១២ | BOT |
| ៥ | អនុស្ថានីយទី៤ - អនុស្ថានីយទី៦ - អនុស្ថានីយកំពង់ឆ្នាំង - អនុស្ថានីយពោធិ៍សាត់ អនុស្ថានីយបាត់ដំបង | ២ | ២x៦៣០ | ២៩៧ | ២០១២ | BOT |
| ៦ | អនុស្ថានីយពោធិ៍សាត់ - អនុស្ថានីយអូរសោម | ២ | ២x៦៣០ | ១៣២ | ២០១២ | BOT |
| ៧ | អនុស្ថានីយកំពត - អនុស្ថានីយស្ទឹងហាវ | ២ | ៦៣០ | ៨២ | ២០១៣ | ADB - JICA |
| ៨ | អនុស្ថានីយទី៦(ខាងជើងភ្នំពេញ) - អនុស្ថានីយកំពង់ចាម | ២ | ២x៤០០ | ៩៧ | ២០១៣ | BOT |
| ៩ | អនុស្ថានីយអូរសោម - រោងចក្រវារីអគ្គិសនីស្ទឹង ឫស្សីជ្រុំក្រោម | ២ | ២x៤០០ | ៤២ | ២០១៣ | BOT |

## តារាងទី ៩ : ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០kV (ត)

| ll | ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០kV | ចំនួនសៀគ្វី | មុខកាត់ខ្សែ (mm2) | ប្រវែងខ្សែ (km) | ឆ្នាំដំណើរការ | ប្រភពទុន |
|---|---|---|---|---|---|---|
| ១០ | ជុំវិញរាជធានីភ្នំពេញ (ខាងលិច -ខាងត្បូងភ្នំពេញ) | ២ | ២X៦៣០ | ២៤ | ២០១៤ | ធនាគារចិន អាហារណេនីហារណេ |
| ១១ | រោងចក្រវារីអគ្គិសនីស្ទឹងឫស្សីជុំព្រលើក្រោម - រោងចក្រវារីអគ្គិសនីស្ទឹងតាតៃ | ២ | ២X៤០០ | ៣៨ | ២០១៤ | BOT |
| ១២ | អនុស្ថានីយកំពង់ចាម - អនុស្ថានីយក្រចេះ | ១ | ២X៦៣០ | ១២៥ | ២០១៧ | BOT |
| ១៣ | អនុស្ថានីយក្រចេះ - អនុស្ថានីយស្ទឹងត្រែង | ១ | ២X៦៣០ | ១១៧ | ២០១៧ | BOT |
| ១៤ | អនុស្ថានីយស្ទឹងត្រែង - រោងចក្រវារីអគ្គិសនីសេសានក្រោម២ | ២ | ២X៤០០ | ៦០ | ២០១៧ | BOT |
| ប្រវែងខ្សែសរុប | | | | ១.១៩៥ KM | | |



## តារាងទី ១០ : អនុស្ថានីយអគ្គិសនីតង់ស្យុងខ្ពស់

| ល.រ | អនុស្ថានីយ | តង់ស្យុង(kV) | ចំនួនត្រង់ស្វូម៉ាទ័រ | អានុភាពសរុប (MVA) | ឆ្នាំដំណើរការ |
|---|---|---|---|---|---|
| ១ | អនុស្ថានីយទី១ | ១១៥/២២ | ២ x ៧៥ | ១៥០ | ១៩៩៩ |
| ២ | អនុស្ថានីយទី២ | ១១៥/២២ | ៣ x ៥០ | ១៥០ | ១៩៩៩ (បន្ថែម ១គ្រឿងឆ្នាំ ២០១៣) |
| ៣ | អនុស្ថានីយទី៣ | ១១៥/២២ | ២ x ៥០ | ១០០ | ១៩៩៩ |
| | | ១១៥/២២/១៥ | ១ x ៥០ | ៥០ | (បន្ថែម ១គ្រឿងឆ្នាំ ២០១៣) |
| ៤ | អនុស្ថានីយកំពង់ស្ពឺ | ១១៥/២២ | ១ x ៥០ | ៥០ | ២០០២ |
| ៥ | អនុស្ថានីយបាត់ដំបង(CPTL) | ១១៥/២២ | ១ x ២៥ | ២៥ | ២០០៧ |
| ៦ | អនុស្ថានីយបន្ទាយមានជ័យ | ១១៥/២២ | ១ x ២៥ | ២៥ | ២០០៧ |
| ៧ | អនុស្ថានីយសៀមរាប | ១១៥/២២ | ២ x ៥០ | ១០០ | ២០០៧ (បន្ថែម ១គ្រឿងឆ្នាំ ២០១៤) |
| ៨ | អនុស្ថានីយទី៤ (ខាងលិចភ្នំពេញ) | ២៣០/១១៥ | ២ x ២០០ | ៤០០ | ២០០៩ |
| | | ១១៥/២២ | ២ x ៥០ | ១០០ | |
| ៩ | អនុស្ថានីយតាកែវ | ២៣០/២២ | ១ x ៥០ | ៥០ | ២០០៩ |
| ១០ | អនុស្ថានីយកំពត | ២៣០/២២ | ១ x ៥០ | ៥០ | ២០១១ |
| ១១ | អនុស្ថានីយកំពង់ឆ្នាំង | ២៣០/២២ | ១ x ២៥ | ២៥ | ២០១២ |
| ១២ | អនុស្ថានីយពោធិ៍សាត់ | ២៣០/២២ | ១ x ២៥ | ២៥ | ២០១២ |
| ១៣ | អនុស្ថានីយបាត់ដំបង(CPG) | ២៣០/១១៥/២២ | ២ x ៩០ | ១៨០ | ២០១២ (បន្ថែម ១គ្រឿងឆ្នាំ ២០១៥) |
| ១៤ | អនុស្ថានីយទី៥ | ១១៥/២២ | ២ x ៥០ | ១០០ | ២០១៣ |
| ១៥ | អនុស្ថានីយស្ទឹងហាវ | ២៣០/២២ | ១ x ៥០ | ៥០ | ២០១៣ |
| ១៦ | អនុស្ថានីយទី៦ (ខាងជើងភ្នំពេញ) | ១១៥/២២ | ១ x ៥០ | ៥០ | ២០១៣ |
| | | ២៣០/១១៥ | ២ x ២០០ | ៤០០ | |
| ១៧ | អនុស្ថានីយអូរសោម | ២៣០/១១៥/២២ | ១ x ១៥០ | ១៥០ | ២០១៣ |
| ១៨ | អនុស្ថានីយកំពង់ចាម | ១១៥/២២ | ២ x ៥០ | ១០០ | ២០១៣ (បន្ថែម ១គ្រឿងឆ្នាំ ២០១៥) |
| | | ២៣០/១១៥ | ១ x ២០០ | ២០០ | (បន្ថែម ១គ្រឿងឆ្នាំ ២០១៧) |
| ១៩ | អនុស្ថានីយឈូក | ២៣០/១១៥ | ១ x ១០០ | ១០០ | ២០១៤ |
| ២០ | អនុស្ថានីយខេត្តព្រះសីហនុ | ១១៥/២២ | ១ x ៥០ | ៥០ | ២០១៤ |
| ២១ | អនុស្ថានីយបន្ទាយមាស (SWS) | ១១៥ | - | - | ២០១៤ |
| ២២ | អនុស្ថានីយទី៧ (ខាងត្បូងភ្នំពេញ) | ២៣០/១១៥ | ១ x ២០០ | ២០០ | ២០១៥ |
| | | ១១៥/២២ | ១ x ៥០ | ៥០ | |
| ២៣ | អនុស្ថានីយស្ទឹងតាតៃ | ២៣០/៣៥/២២ | ១ x ៦០ | ៦០/៦០/៤០ | ២០១៥ |
| ២៤ | អនុស្ថានីយ IE | ១១៥/២២ | ១ x ៥០ | ៥០ | ២០១៥ |
| ២៥ | អនុស្ថានីយថ្មីខាងកើតសៀមរាប | ១១៥/២២ | ១ x ៥០ | ៥០ | ២០១៦ |
| ២៦ | អនុស្ថានីយកំពង់សីលា | ១១៥/២២ | ១ x ៥០ | ៥០ | ២០១៧ |
| ២៧ | អនុស្ថានីយទី៨ | ១១៥/២២ | ១ x ៧៥ | ៧៥ | ២០១៧ |
| ២៨ | អនុស្ថានីយច្រកម្ទេស | ១១៥/២២ | ១ x ៥០ | ៥០ | ២០១៧ |
| ២៩ | អនុស្ថានីយក្រចេះ | ២៣០/២២ | ១ x ៥០ | ៥០ | ២០១៧ |

# ខ្សែបណ្តាញ ចែកចាយ

ខ្សែបណ្តាញចែកចាយ មានតួនាទីយ៉ាងសំខាន់ ក្នុងការផ្គត់ផ្គង់ថាមពលប្រើប្រាស់ទៅកាន់អ្នកប្រើប្រាស់ថាមពលអគ្គិសនីចុងក្រោយដែលគ្របដណ្តប់ស្ទើរគ្រប់ខេត្ត ក្រុង។ ខ្សែបណ្តាញចែកចាយ និងបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ត្រូវបានបែងចែកជាពីរប្រភេទគឺ ៖

១. បណ្តាញតង់ស្យុងមធ្យម ៣៥ គីឡូវ៉ុល និង ២២ គីឡូវ៉ុល។

២. បណ្តាញតង់ស្យុងទាប ០,៤ គីឡូវ៉ុល និង ០,២៣ គីឡូវ៉ុល។





បណ្តាញចែកចាយ និងបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ជាទូទៅ គឺមានតង់ស្យុង ២២ kV និងតង់ស្យុង ទាប ០,៤/០,២៣ kV ។ អំឡុងឆ្នាំ២០០៩ និង ២០១០ បណ្តាញចែកចាយនៅរាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ ខេត្តព្រៃវែង ស្រុកបានលុង (ខេត្តរតនគិរី) ខេត្តស្ទឹងត្រែង និងខេត្តព្រះសីហនុ ត្រូវបានសាងសង់បន្ថែម ដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្គត់ផ្គង់ ។ ចំពោះទិន្នន័យលម្អិតរបស់ខ្សែបណ្តាញប្រភេទតង់ស្យុងខុសៗគ្នាដូចមានបង្ហាញក្នុងតារាងបន្ទាប់។

## តារាងទី ១១ : ទិន្នន័យសង្ខេបនៃប្រព័ន្ធចែកចាយ និងបញ្ជូនរង

| ទីតាំង | ប្រភេទ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ |
|---|---|---|---|---|---|---|---|
| ភ្នំពេញ និង កណ្តាល | ប្រវែងខ្សែ,cct-km | ២.៥៧៣ | ៣.៥៨៦ | ៣.៧៧៩ | ៤.១៨៧ | ៤.៤២១ | ៤.៦៤៧ |
| | តង់ស្យុងមធ្យម | ១.២៨៧ | ២.២០៤ | ២.៣២៥ | ២.៦៤១ | ២.៧៥៩ | ២.៨៩៧ |
| | តង់ស្យុងទាប | ១.២៨៥ | ១.៣៨២ | ១.៤៥៣ | ១.៥៤៦ | ១.៦៦២ | ១.៧៥០ |
| | បន្ទប់ភ្លើងសរុប | ២.១៧០ | ២.៣៨៥ | ២.៦៦៥ | ២.៩៩៤ | ៣.៣៦៧ | ៣.៨៧៩ |
| | បន្ទប់ភ្លើង | - | - | ១.០៧៦ | ១.២១៨ | ១.៣៥៦ | ១.៥៤៩ |
| | ប៉ុស្តិ៍លើបង្គោល | - | - | ១.៥៨៩ | ១.៧៧៦ | ២.០១១ | ២.៣៣០ |
| កំពង់ស្ពឺ | ប្រវែងខ្សែ,cct-km | ១៥២ | ៨០៦ | ៨២៥ | ៤០១ | ៦១៤ | ៧៧៥ |
| | តង់ស្យុងមធ្យម | ៩៦ | ៦៧៣ | ៦៨៣ | ២៤២ | ៤០៩ | ៥៤០ |
| | តង់ស្យុងទាប | ៥៦ | ១៣២ | ១៤២ | ១៦០ | ២០៥ | ២៣៥ |
| | បន្ទប់ភ្លើងសរុប | ៧១ | ៨៧ | ៩៥ | ១០២ | ២៣១ | ២៦៣ |
| | បន្ទប់ភ្លើង | - | - | - | ៣ | ៣ | ៣ |
| | ប៉ុស្តិ៍លើបង្គោល | - | - | ៩៥ | ៩៩ | ២២៨ | ២៦០ |
| សៀមរាប | ប្រវែងខ្សែ,cct-km | ៦៥៨ | ៧៣៦ | ៨០៨ | ១.១២៩ | ១.៣០៩ | ២.៣៥៦ |
| | តង់ស្យុងមធ្យម | ៣៦៨ | ៤១៤ | ៤៦២ | ៧៤៩ | ៨៦១ | ១.២៧៩ |
| | តង់ស្យុងទាប | ២៩០ | ៣២២ | ៣៤៦ | ៣៨០ | ៤៤៨ | ១.០៧៧ |
| | បន្ទប់ភ្លើងសរុប | ១៨៤ | ១៩៦ | ២៣០ | ៣០៨ | ៣៨០ | ៣៨៣ |
| | បន្ទប់ភ្លើង | - | - | ១៣២ | ១៤១ | ១៤៧ | ៩៤ |
| | ប៉ុស្តិ៍លើបង្គោល | - | - | ៩៨ | ១៦៧ | ២៣៣ | ២៨៩ |
| ព្រះសីហនុ | ប្រវែងខ្សែ,cct-km | ២៩៨ | ៣០៤ | ៣៦២ | ៥០៣ | ៨៨៩ | ៩៨៤ |
| | តង់ស្យុងមធ្យម | ២០៤ | ២០៨ | ២៦៦ | ៤០១ | ៧៧៣ | ៨៦៤ |
| | តង់ស្យុងទាប | ៩៤ | ៩៦ | ៩៦ | ១០៣ | ១១៦ | ១២០ |
| | បន្ទប់ភ្លើងសរុប | ១៧៨ | ១៨៧ | ២៨១ | ៣១២ | ៣៥៥ | ៤៧៩ |
| | បន្ទប់ភ្លើង | - | - | ៥១ | ៥៤ | ៦២ | ៨៧ |
| | ប៉ុស្តិ៍លើបង្គោល | - | - | ២៣០ | ២៥៨ | ២៩៣ | ៣៩២ |
| កំពង់ចាម | ប្រវែងខ្សែ,cct-km | ១៤៥ | ១៥០ | ៦៦៧ | ៧៣២ | ៨៤៥ | ១.០២៤ |
| | តង់ស្យុងមធ្យម | ៥១ | ៥២ | ៥៤៨ | ៦០៧ | ៦៧៩ | ៨២៣ |
| | តង់ស្យុងទាប | ៩៤ | ៩៨ | ១១៩ | ១២៥ | ១៦៥ | ២០១ |
| | បន្ទប់ភ្លើងសរុប | ៥៩ | ៦៤ | ១៤១ | ២០១ | ២២១ | ២៤៥ |
| | បន្ទប់ភ្លើង | - | - | ៦ | ៦ | ៦ | ៨ |
| | ប៉ុស្តិ៍លើបង្គោល | - | - | ១៣៥ | ១៩៥ | ២១៥ | ២៣៧ |
| ពញាក្រែក | ប្រវែងខ្សែ,cct-km | ៤៥ | ៤៥ | ៦៤ | ៧៥ | ១២២ | ១៣៧ |
| | តង់ស្យុងមធ្យម | ២៧ | ២៧ | ៤៦ | ៥០ | ៧១ | ៦៩ |
| | តង់ស្យុងទាប | ១៨ | ១៨ | ១៨ | ២៥ | ៥១ | ៦៨ |
| | បន្ទប់ភ្លើងសរុប | ៣១ | ២១ | ៣៣ | ៤៣ | ៤៧ | ៤៣ |
| | បន្ទប់ភ្លើង | - | - | - | - | - | - |
| | ប៉ុស្តិ៍លើបង្គោល | - | - | ៣៣ | ៤៣ | ៤៧ | ៤៣ |

| ទីតាំង | ប្រភេទ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ |
|---|---|---|---|---|---|---|---|
| **មេមត់** | ប្រវែងខ្សែ,cct-km | ៤៦ | ៤៨ | ២១៦ | ២៤៦ | ២៨១ | ២៨៣ |
| | តង់ស្យុងមធ្យម | ២៣ | ២៣ | ១៨៩ | ១៨៩ | ២០៦ | ២០៦ |
| | តង់ស្យុងទាប | ២៣ | ២៥ | ២៦ | ៥៦ | ៧៥ | ៧៧ |
| | បន្ទប់ភ្លើងសរុប | ៣៧ | ២៤ | ២៥ | ៧៧ | ៨៧ | ៩៣ |
| | បន្ទប់ភ្លើង | - | - | - | - | - | - |
| | ប៉ុស្តិ៍លើបង្គោល | - | - | ២៥ | ៧៧ | ៨៧ | ៩៣ |
| **តាកែវ** | ប្រវែងខ្សែ,cct-km | ២៨០ | ៣៦៨ | ៥៦៧ | ៧៤៦ | ៧៨៦ | ៧៨៣ |
| | តង់ស្យុងមធ្យម | ១៥៨ | ១៥៨ | ៣១៦ | ៣៥៣ | ៣៥៦ | ៣៤៥ |
| | តង់ស្យុងទាប | ១២២ | ២១០ | ២៥១ | ៣៩៤ | ៤៣១ | ៤៣៧ |
| | បន្ទប់ភ្លើងសរុប | ១០៤ | ១១៣ | ១៦៧ | ១៨៨ | ១៨៨ | ១៦៩ |
| | បន្ទប់ភ្លើង | - | - | ១៧ | ២៥ | ២៦ | ៦ |
| | ប៉ុស្តិ៍លើបង្គោល | - | - | ១៥០ | ១៦៣ | ១៦២ | ១៦៣ |
| **បាត់ដំបង** | ប្រវែងខ្សែ,cct-km | ៦៤៣ | ៦៩២ | ៦៩១ | ៦៩៦ | ២.២៧៦ | ២.៤៦៥ |
| | តង់ស្យុងមធ្យម | ៤០១ | ៤៤៤ | ៤៤៤ | ៤៤៧ | ១.៩៧៧ | ២.១១០ |
| | តង់ស្យុងទាប | ២៤២ | ២៤៧ | ២៤៧ | ២៤៩ | ២៩៩ | ៣៥៥ |
| | បន្ទប់ភ្លើងសរុប | ២២៨ | ២៤០ | ២៤០ | ២៥២ | ៦៩៦ | ៧៤៣ |
| | បន្ទប់ភ្លើង | - | - | - | ១ | ៧ | ៨ |
| | ប៉ុស្តិ៍លើបង្គោល | - | - | ២៤០ | ២៥១ | ៦៨៩ | ៧៣៥ |
| **កំពត** | ប្រវែងខ្សែ,cct-km | ៣៣៩ | ៣៣៩ | ៣៣៩ | ៤៣៦ | ៦៥៨ | ៦៧៣ |
| | តង់ស្យុងមធ្យម | ២២៧ | ២២៧ | ២២៧ | ៣១១ | ៥៣៤ | ៥៤៥ |
| | តង់ស្យុងទាប | ១១២ | ១១២ | ១១២ | ១២៥ | ១២៥ | ១២៧ |
| | បន្ទប់ភ្លើងសរុប | ៩០ | ១០៥ | ១០៥ | ១៨៧ | ២២៩ | ២៤៥ |
| | បន្ទប់ភ្លើង | - | - | - | - | ៧ | ៧ |
| | ប៉ុស្តិ៍លើបង្គោល | - | - | ១០៥ | ១៨៧ | ២២២ | ២៣៨ |
| **កំពង់ត្រាច** | ប្រវែងខ្សែ,cct-km | ៦០ | ៧៦ | ៧៦ | ១០០ | ១២១ | ១៤៤ |
| | តង់ស្យុងមធ្យម | ៣៩ | ៤៧ | ៤៧ | ៤៨ | ៥៦ | ៦៥ |
| | តង់ស្យុងទាប | ២១ | ២៩ | ២៩ | ៥២ | ៦៥ | ៧៨ |
| | បន្ទប់ភ្លើងសរុប | ៣៦ | ៤៤ | ៤៤ | ៤៧ | ៥៣ | ៦៣ |
| | បន្ទប់ភ្លើង | - | - | ១ | ១ | ២ | ២ |
| | ប៉ុស្តិ៍លើបង្គោល | - | - | ៤៣ | ៤៦ | ៥១ | ៦១ |
| **ព្រៃវែង** | ប្រវែងខ្សែ,cct-km | ១១២ | ៤៧៤ | ៧៩០ | ៧៩៤ | ៨២៤ | ៨៦៧ |
| | តង់ស្យុងមធ្យម | ៥៦ | ៤១៧ | ៧៣១ | ៧៣១ | ៧៦០ | ៨០៤ |
| | តង់ស្យុងទាប | ៥៧ | ៥៧ | ៥៩ | ៦៣ | ៦៥ | ៦៣ |
| | បន្ទប់ភ្លើងសរុប | ២០ | ២១ | ១៩៤ | ២០២ | ២៤៧ | ២៩០ |
| | បន្ទប់ភ្លើង | - | - | - | ៤ | ៨ | ៨ |
| | ប៉ុស្តិ៍លើបង្គោល | - | - | ១៩៤ | ១៩៨ | ២៣៩ | ២៨២ |
| **បន្ទាយមានជ័យ** | ប្រវែងខ្សែ,cct-km | ១៧១ | ១៧៤ | ១៨១ | ២២៩ | ២២៩ | ២៤៧ |
| | តង់ស្យុងមធ្យម | ៤៦ | ៤៩ | ៥១ | ៦៥ | ៦៥ | ៦៥ |
| | តង់ស្យុងទាប | ១២៥ | ១២៥ | ១៣០ | ១៦៤ | ១៦៤ | ១៨២ |
| | បន្ទប់ភ្លើងសរុប | ៥០ | ៥៥ | ៦០ | ៨៦ | ៥៦ | ៦៦ |
| | បន្ទប់ភ្លើង | - | - | - | ៨ | ៨ | ៨ |
| | ប៉ុស្តិ៍លើបង្គោល | - | - | ៦០ | ៧៨ | ៤៨ | ៥៨ |

## ខ្សែបណ្ដាញចែកចាយ

| ទីតាំង | ប្រភេទ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ |
|---|---|---|---|---|---|---|---|
| មណ្ឌលប៉ូរី | ប្រវែងខ្សែ,cct-km | ៨២ | ៨២ | ៨២ | ៨៩ | ៨៩ | ៩៣ |
| | តង់ស្យុងមធ្យម | ៤៥ | ៤៥ | ៤៥ | ៤៦ | ៤៦ | ៤៧ |
| | តង់ស្យុងទាប | ៣៧ | ៣៧ | ៣៧ | ៤៤ | ៤៤ | ៤៦ |
| | បន្ទប់ភ្លើងសរុប | ៣៥ | ៣៥ | ៣៩ | ៤២ | ២២ | ២៣ |
| | បន្ទប់ភ្លើង | - | - | - | - | - | - |
| | ប៉ុស្ដិ៍លើបង្គោល | - | - | ៣៩ | ៤២ | ២២ | ២៣ |
| ស្ទឹងត្រែង | ប្រវែងខ្សែ,cct-km | ១៣៣ | ២០២ | ២៤០ | ២៤០ | ៣២៧ | ៧៦៩ |
| | តង់ស្យុងមធ្យម | ៩២ | ១៣២ | ១៥១ | ១៥១ | ២២៧ | ៦០០ |
| | តង់ស្យុងទាប | ៤១ | ៧០ | ៨៩ | ៨៩ | ១០០ | ១៦៩ |
| | បន្ទប់ភ្លើងសរុប | ២៣ | ៣៧ | ៤៨ | ៥៣ | ៦៣ | ៧៩ |
| | បន្ទប់ភ្លើង | - | - | - | ៤ | ៩ | ៥ |
| | ប៉ុស្ដិ៍លើបង្គោល | - | - | ៤៨ | ៤៩ | ៥៤ | ៧៤ |
| រតនគិរី | ប្រវែងខ្សែ,cct-km | ១៣០ | ១៣៩ | ១៤១ | ១៦៧ | ៥៩២ | ៧៣០ |
| | តង់ស្យុងមធ្យម | ៩០ | ៩២ | ៩២ | ១០៣ | ៤៩២ | ៥៨៦ |
| | តង់ស្យុងទាប | ៤០ | ៤៧ | ៤៩ | ៦៣ | ១០០ | ១៤៥ |
| | បន្ទប់ភ្លើងសរុប | ៥០ | ៧២ | ៨៥ | ១០៣ | ៧២ | ១៤៥ |
| | បន្ទប់ភ្លើង | - | - | ១ | ៥ | ៤ | ៤ |
| | ប៉ុស្ដិ៍លើបង្គោល | - | - | ៨៤ | ៩៨ | ៦៨ | ១៤១ |
| ស្វាយរៀង | ប្រវែងខ្សែ,cct-km | ៤១៨ | ៤១៩ | ៦០៥ | ៣៦៩ | ៨៨៧ | ៦៦៣ |
| | តង់ស្យុងមធ្យម | ៣២៥ | ៣២៥ | ៤៦៦ | ១៥៤ | ៦៧០ | ៤៣៣ |
| | តង់ស្យុងទាប | ៩២ | ៩៤ | ១៣៩ | ២១៥ | ២១៧ | ២៣០ |
| | បន្ទប់ភ្លើងសរុប | ៧១ | ៥៤ | ៧៦ | ១១៤ | ២៨៤ | ១៦៨ |
| | បន្ទប់ភ្លើង | - | - | - | ៥ | ៥ | ៥ |
| | ប៉ុស្ដិ៍លើបង្គោល | - | - | ៧៦ | ១០៩ | ២៧៩ | ១៦៣ |
| បាវិត | ប្រវែងខ្សែ,cct-km | ១៧៤ | ១៨៦ | - | - | - | ១២០ |
| | តង់ស្យុងមធ្យម | ១៤១ | ១៤១ | - | - | - | ៧៧ |
| | តង់ស្យុងទាប | ៣៣ | ៤៤ | - | - | - | ៤៣ |
| | បន្ទប់ភ្លើងសរុប | ៥០ | ២១ | - | - | - | ៤១ |
| | បន្ទប់ភ្លើង | - | - | - | - | - | - |
| | ប៉ុស្ដិ៍លើបង្គោល | - | - | - | - | - | ៤១ |
| មណ្ឌលគិរី | ប្រវែងខ្សែ,cct-km | ១០៩ | ១២០ | ១២៥ | ១៣៣ | ៣០០ | ២៩៥ |
| | តង់ស្យុងមធ្យម | ៦៩ | ៧៣ | ៧៧ | ៨៥ | ២៤៣ | ២២៥ |
| | តង់ស្យុងទាប | ៤០ | ៤៧ | ៤៧ | ៤៨ | ៥៦ | ៧០ |
| | បន្ទប់ភ្លើងសរុប | ៤៩ | ៥៤ | ៥៥ | ៧៦ | ១០៧ | ១០០ |
| | បន្ទប់ភ្លើង | - | - | - | - | - | - |
| | ប៉ុស្ដិ៍លើបង្គោល | - | - | ៥៥ | ៧៦ | ១០៧ | ១០០ |

*គម្រោងអគ្គិសនីភាវូបនីយកម្មជនបទ ដែលស្ថិតក្រោមប្រាក់កម្ចីរបស់ធនាគារចិនអាហារណែនីហរណៃ (China Exim Bank) កំពុងដំណើរការសាងសង់ប្រព័ន្ធចែកចាយតង់ស្យុងមធ្យម ដែលគ្របដណ្ដប់ខេត្តចំនួន ០៤ រួមមាន ខេត្តកំពង់ចាម ខេត្តព្រៃវែង ខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ ដែលមានប្រវែងសរុប ២.០០០ km ។ បន្ថែមពីនេះ គម្រោងអគ្គិសនីភាវូបនីយកម្មជនបទដំណាក់កាលទី២ ស្ថិតក្រោមមូលនិធិរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលគ្របដណ្ដប់ ខេត្តចំនួន ៦ រួមមាន ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តឧត្តរមានជ័យ និងខេត្តសៀមរាប ដែលមានប្រវែងសរុបប្រមាណ ១.២០០ km ត្រូវបានសាងសង់*

| ទីតាំង | ប្រភេទ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ |
|---|---|---|---|---|---|---|---|
| កែវសីមា | ប្រវែងខ្សែ,cct-km | ៦៤ | ៧៨ | ៨៩ | ៩០ | ៩០ | ១៣១ |
| | តង់ស្យុងមធ្យម | ៣៣ | ៤៦ | ៤៨ | ៤៨ | ៤៨ | ៨៣ |
| | តង់ស្យុងទាប | ៣១ | ៣២ | ៤១ | ៤២ | ៤៣ | ៤៨ |
| | បន្ទប់ភ្លើងសរុប | ២២ | ២២ | ២៦ | ៣០ | ៣០ | ៣០ |
| | បន្ទប់ភ្លើង | - | - | - | - | - | - |
| | ប៉ុស្តិ៍លើបង្គោល | - | - | ២៦ | ៣០ | ៣០ | ៣០ |
| ក្រចេះ | ប្រវែងខ្សែ,cct-km | ១៣៦ | ១៦០ | ១៦០ | ២២៥ | ៣៨០ | ៥៥២ |
| | តង់ស្យុងមធ្យម | ១១៧ | ១២៣ | ១២៣ | ១៣៩ | ២៧៩ | ៤៣៤ |
| | តង់ស្យុងទាប | ១៩ | ៣៨ | ៣៨ | ៨៥ | ១០១ | ១១៨ |
| | បន្ទប់ភ្លើងសរុប | ៤៤ | ៤៩ | ៥៣ | ៧១ | ១០១ | ១២៣ |
| | បន្ទប់ភ្លើង | - | - | - | - | - | - |
| | ប៉ុស្តិ៍លើបង្គោល | - | - | ៥៣ | ៧១ | ១០១ | ១២៣ |
| ស្នួល | ប្រវែងខ្សែ,cct-km | ៣៣ | ៣៣ | ៣៣ | ៣៧ | ៨៤ | ១០១ |
| | តង់ស្យុងមធ្យម | ១៩ | ១៩ | ២០ | ២៤ | ២៥ | ៤០ |
| | តង់ស្យុងទាប | ១៤ | ១៤ | ១៤ | ១៤ | ៦០ | ៦១ |
| | បន្ទប់ភ្លើងសរុប | ២៥ | ២៨ | ៣២ | ៤០ | ៥១ | ៣៣ |
| | បន្ទប់ភ្លើង | - | - | - | - | - | - |
| | ប៉ុស្តិ៍លើបង្គោល | - | - | ៣២ | ៤០ | ៥១ | ៣៣ |
| សរុប | ប្រវែងខ្សែ,cct-km | ៦.៨០០ | ៩.២១៦ | ១០.៨៣៨ | ១១.៦២២ | ១៦.១២៧ | ១៩.៥៥០ |
| | តង់ស្យុងមធ្យម | ៣.៩១៥ | ៥.៩៣៩ | ៧.៣៥៦ | ៧.៥៨៣ | ១១.៥៣៦ | ១៣.៦២៤ |
| | តង់ស្យុងទាប | ២.៨៨៥ | ៣.២៧៧ | ៣.៤៨២ | ៤.០៤០ | ៤.៥៩១ | ៥.៩២៦ |
| | បន្ទប់ភ្លើងសរុប | ៣.៦២៧ | ៣.៩១៤ | ៤.៦៩៤ | ៥.៥២៨ | ៦.៨៨៧ | ៧.៨៤៩ |
| | បន្ទប់ភ្លើង | - | - | ១.២៨៤ | ១.៤៧៥ | ១.៦៥០ | ១.៧៩៤ |
| | ប៉ុស្តិ៍លើបង្គោល | - | - | ៣.៤១០ | ៤.០៥៣ | ៥.២៣៧ | ៦.០៥៥ |

*រួចរាល់ជាស្ថាពរ និងដាក់ឲ្យដំណើរការនៅឆ្នាំ ២០១៦។*



*គម្រោងពង្រីកខ្សែបញ្ជូនរងអគ្គិសនីតង់ស្យុងមធ្យម ក្រោមគម្រោងហិរញ្ញប្បទានឥណទាន របស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដែលកំពុងធ្វើការសាងសង់ក្នុងខេត្តចំនួន ៥ រួមមាន ៖ ខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តកំពង់ចាម ខេត្តកណ្តាល ខេត្តបន្ទាយមានជ័យ ដែលមានប្រវែងសរុបប្រមាណ ២.១៥៨ km ។ បន្ទាប់មកគម្រោងអគ្គិសនីការូបនីយកម្មជនបទ ខេត្តស្វាយរៀង ដែលប្រើប្រាស់ថវិកាហិរញ្ញប្បទានឥតសំណងរបស់ទីភ្នាក់ងារអន្តរជាតិ (AusAid) តាមរយៈធនាគារអភិវឌ្ឍន៍អាស៊ី(ADB) ជាមួយថវិកាក្នុងស្រុក ដែលមានប្រវែងខ្សែបណ្តាញ MV និង LV ប្រមាណ៦២០ km ។ គម្រោងពង្រីកខ្សែបណ្តាញចែកចាយក្នុង ខេត្តកោះកុង កំពង់ចាម និងក្រចេះ ដែលផ្តល់ហិរញ្ញប្បទានឥណទាន ដោយទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ហៅកាត់ថា AFD ត្រូវបានធ្វើការសិក្សាសមិទ្ធលទ្ធភាព និងរៀបចំដេញថ្លៃ។*

*គម្រោងពង្រីកបណ្តាញអគ្គិសនីការូបនីយកម្មជនបទ ជំហានទី៥ និងទី៦បានចាប់ផ្តើម សិក្សា និងធ្វើការចរចា ដើម្បីពង្រីកបន្ថែមនូវបណ្តាញអគ្គិសនីការូបនីយកម្មជនបទក្នុងខេត្តចំនួន ១៣ ដែលមានប្រវែងសរុបប្រមាណ ២.៥២៥ km។*





# មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ នៃអគ្គិសនីកម្ពុជា (ម.អ.ជ)

នាយកដ្ឋានមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ(ម.អ.ជ.) ជានាយកដ្ឋានមួយរបស់អគ្គិសនីកម្ពុជា ដែលបានបង្កើតឡើងនៅឆ្នាំ២០១២ ដើម្បីរុញផ្លែផ្កានៃការអភិវឌ្ឍន៍អគ្គិសនីឆ្ពោះទៅប្រជាពលរដ្ឋនៅជនបទនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

# មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ នៃអគ្គិសនីកម្ពុជា ( ម.អ.ជ )

## ការបង្កើតអគ្គិសនីភាវូបនីយកម្មជនបទ

រាជរដ្ឋាភិបាលបានចេញព្រះរាជក្រឹត្យលេខ នស/រកត/១២០៤/០៤៨ ចុះថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០០៤ ស្តីពីការបង្កើតស្ថាប័នមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីជំរុញការអភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មជនបទ។ បន្ទាប់មកនៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១២ រាជរដ្ឋាភិបាលកម្ពុជា បានចេញព្រះរាជក្រឹត្យថ្មីមួយទៀតលេខ នស/រកត/០៨១២/៧៣៤ ដោយធ្វើវិសោធនកម្មមាត្រាខ្លះនៃព្រះរាជក្រឹត្យចាស់ ដោយផ្ទេរស្ថាប័នមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជាវិញ ដើម្បីឲ្យកម្ពុជាខ្លួនឯងអាចម្ចាស់ការបន្តប្រតិបត្តិការការងាររបស់មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទផង និងក៏នៅតែអាចទទួលនូវអំណោយ និងជំនួយនានាពីខាងក្រៅមកជួយអភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មជនបទកម្ពុជាបានផង។

## សកម្មភាពការងារដែល ម.អ.ជ សម្រេចបានក្នុងឆ្នាំ២០១៧

ក្នុងឆ្នាំ២០១៧ ថវិការបស់ ម.អ.ជ ទទួលបានពីអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ (KfW)។ ក្នុងឆ្នាំនេះ ម.អ.ជ ទទួលបានថវិកាពីអគ្គិសនីកម្ពុជា ៥២ លានដុល្លារអាមេរិក និងពីធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់បានផ្តល់ថវិកាចំនួន ២,៦ លានដុល្លារអាមេរិក ដែលថវិកាសរុបទាំងអស់មានចំនួន ៥៤,៦ លានដុល្លារអាមេរិកសម្រាប់យកទៅអនុវត្តកម្មវិធីរុញផ្លែផ្កានៃការអភិវឌ្ឍន៍អគ្គិសនីឆ្ពោះទៅប្រជាពលរដ្ឋនៅជនបទ។ ថវិកាទាំងនេះសម្រាប់ចំណាយប្រតិបត្តិការរបស់ ម.អ.ជ ដែលកម្មវិធីទាំង៦នេះរួមមាន៖

### ១ កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ

គោលបំណងនៃកម្មវិធីនេះ គឺជួយដល់គ្រួសារក្រីក្ររស់នៅតំបន់ជនបទ ដើម្បីឲ្យពួកគាត់អាចទទួលបានការតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ដោយការផ្តល់ប្រាក់កម្ចីអនុគ្រោះគ្មានការប្រាក់ឲ្យពួកគាត់ខ្ចីយកទៅ ៖ ១-បង់ថ្លៃភ្ជាប់ចរន្តឲ្យអ្នកផ្គត់ផ្គង់ ២-បង់ថ្លៃប្រាក់កក់ឲ្យអ្នកផ្គត់ផ្គង់ ៣-ចំណាយលើការទិញ និងរាយខ្សែពីចំណុចភ្ជាប់ចរន្តមកដល់ផ្ទះរបស់ខ្លួន ៤-ចំណាយលើការរៀបចំខ្សែបណ្តាញ និងឧបករណ៍អគ្គិសនីក្នុងផ្ទះ ដើម្បីតភ្ជាប់ចរន្តអគ្គិសនីចូលផ្ទះ។ ក្នុងឆ្នាំ២០១៧ នេះ មានគ្រួសារជនបទចំនួន ១៣៤ គ្រួសារ ស្មើនឹង ៦១៦ នាក់ ដែលបានទទួលផលដោយផ្ទាល់ក្រោមកម្មវិធីនេះ។

### ២ កម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ

គោលបំណងនៃកម្មវិធីនេះ គឺជួយសម្រួលឲ្យគ្រួសារជនបទរស់នៅតំបន់ដាច់ស្រយាល ដែលខ្សែបណ្តាញអគ្គិសនី មិនទាន់អាចពង្រីកទៅដល់ក្នុងរយៈពេលយូរ អាចទទួលបានអគ្គិសនីប្រើប្រាស់ តាមរយៈប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ ។ ម.អ.ជ.ជួយផ្តល់ប្រាក់ឧបត្ថម្ភធនចំនួន ១០០ដុល្លារអាមេរិកក្នុង ១ ប្រព័ន្ធ ដល់គ្រួសារជនបទ ដើម្បីជួយកាត់បន្ថយការទូទាត់ថ្លៃទិញប្រព័ន្ធ ហើយអ្នកទិញត្រូវបង់ថ្លៃសល់ពីការឧបត្ថម្ភធននេះ រំលស់ប្រចាំខែដោយគ្មានការប្រាក់មក ម.អ.ជ. វិញក្នុងរយៈពេល ៤ឆ្នាំ។ ក្រោយពេលបង់រំលស់អស់ជាស្ថាពរ ប្រព័ន្ធនេះនឹងក្លាយជាកម្មសិទ្ធិរបស់អ្នកទិញ ។ ក្នុងឆ្នាំ ២០១៧ មានគ្រួសារជនបទចំនួន ២០.៣០០ គ្រួសារ ស្មើនឹង ៩៣.៣៨០នាក់ បានទទួលផលដោយផ្ទាល់ក្រោមកម្មវិធីនេះ។



## ៣ កម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនី នៅតំបន់ជនបទ

គោលបំណងនៃកម្មវិធីនេះ គឺជួយសម្រួលឲ្យអ្នកផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ដែលមានអាជ្ញាប័ណ្ណស្របច្បាប់ អាចមានទុនសម្រាប់វិនិយោគពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនី ឲ្យពេញដែនអាជ្ញាប័ណ្ណចែកចាយរបស់ខ្លួន ដើម្បីឲ្យប្រជាពលរដ្ឋគ្រប់គ្រួសារអាចភ្ជាប់ចរន្តប្រើប្រាស់តាមលទ្ធភាពរបស់ខ្លួន ។ ក្នុងឆ្នាំ២០១៧ ម.អ.ជ បានផ្តល់ថវិកាជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីដល់សេវាករផ្គត់ផ្គង់អគ្គិសនីសាងសង់ខ្សែបណ្តាញ MV និង LV សរុបចំនួន ១.២៤២ km។

## ៤ កម្មវិធីផ្តល់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្រ្គប់ថ្លៃលក់អគ្គិសនី ដល់អ្នកកាន់អាជ្ញាបណ្ណធ្វើអាជីវកម្មអគ្គិសនី ដែលបានភ្ជាប់ប្រភពអគ្គិសនីជាមួយបណ្តាញជាតិ ដើម្បីបន្ថយថ្លៃលក់អគ្គិសនីដល់គ្រួសារក្រីក្រនៅតំបន់ជនបទក្នុងក្របខណ្ឌនៃផែនការយុទ្ធសាស្ត្របន្ថយអត្រាថ្លៃលក់អគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់ឆ្នាំ២០១៥ ដល់ឆ្នាំ២០២០ តាមបណ្តាខេត្ត និងរាជធានី

គោលបំណងនៃកម្មវិធីនេះ គឺផ្តល់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនី ដល់អ្នកកាន់អាជ្ញាបណ្ណធ្វើអាជីវកម្មអគ្គិសនី ដែលបានភ្ជាប់ប្រភពអគ្គិសនីជាមួយប្រព័ន្ធបណ្តាញជាតិ ដើម្បីបន្ថយថ្លៃលក់អគ្គិសនីដល់គ្រួសារក្រីក្រនៅតំបន់ជនបទក្នុងក្របខណ្ឌនៃផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់ឆ្នាំ ២០១៥ ដល់ឆ្នាំ ២០២០ តាមបណ្តាខេត្ត និងរាជធានី។ នៅឆ្នាំ ២០១៧ ម.អ.ជ បានផ្តល់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនីដល់អ្នកកាន់អាជ្ញាបណ្ណចំនួន ២៨៥ អាជ្ញាបណ្ណ ដែលក្នុងនោះ ២៨១អាជ្ញាបណ្ណ បានទទួលថវិកាឧបត្ថម្ភធន និង ០៤ អាជ្ញាបណ្ណពុំទាន់ស្នើសុំថវិកានៅឡើយ។

## ៥ កម្មវិធីផ្តល់ការផ្គត់ផ្គង់អគ្គិសនីសម្រាប់បូមទឹកធ្វើកសិកម្ម

គោលបំណងនៃកម្មវិធីនេះ គឺជួយសម្រួលដល់គ្រួសារក្រីក្រ រស់នៅតំបន់ជនបទទទួលបានការផ្គត់ផ្គង់អគ្គិសនីពីប្រព័ន្ធបណ្តាញជាតិផ្ទាល់ សម្រាប់ការបូមទឹកធ្វើកសិកម្ម នៅតម្លៃអនុគ្រោះ សម្រាប់ការប្រើប្រាស់អគ្គិសនីនៅពេលយប់ចាប់ពីម៉ោង ៩:០០ យប់ ដល់ម៉ោង ៧:០០ ព្រឹក និងនៅតម្លៃធម្មតាសម្រាប់ការប្រើប្រាស់អគ្គិសនីនៅពេលថ្ងៃចាប់ពីម៉ោង ៧:០០ ព្រឹក ដល់ម៉ោង ៩:០០ យប់។ ក្នុងឆ្នាំ២០១៧ អគ្គិសនីកម្ពុជាកំពុងដំណើរការលទ្ធកម្ម ១)-ជ្រើសរើសក្រុមហ៊ុនផ្គត់ផ្គង់ និងសាងសង់ហេដ្ឋារចនាសម្ព័នផ្គត់ផ្គង់អគ្គិសនី និង ២)-ជ្រើសរើសក្រុមហ៊ុនផ្គត់ផ្គង់នាឡិកាស្ទង់ Prepaid TOU Meter ។



## ៦ កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រមានបណ្ណសមធម៌ ក្រោមជំនួយផ្អែកលើលទ្ធផល

គោលបំណងនៃកម្មវិធីនេះ គឺជួយសម្រួលដល់គ្រួសារក្រីក្រមានបណ្ណសមធម៌នៅតំបន់ជនបទដោយជួយគ្រួសារមានចំណូលទាបនិងងាយរងផលប៉ះពាល់ អាចទទួលបានការតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ដោយការផ្តល់ថវិកាឧបត្ថម្ភធនចំនួន ១០០ដុល្លារអាមេរិក ក្នុងមួយគ្រួសារក្រីក្រ តាមរយៈអ្នកកាន់អាជ្ញាបណ្ណសម្រាប់ ១-ចំណាយលើសម្ភារ និងពលកម្មរាយខ្សែបណ្តាញសេវាកម្មពីចំណុចភ្ជាប់ចរន្តមកដល់ផ្ទះ (នាឡិកាស្ទង់លើបង្គោល)និង ២-ចំណាយលើសម្ភារ និងពលកម្មតម្លើងសម្ភារអគ្គិសនីក្នុងផ្ទះ ដើម្បីតភ្ជាប់ចរន្តអគ្គិសនីចូលផ្ទះ។

កម្មវិធីនេះទទួលបានថវិកាជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ចំនួន ១លានដុល្លា សម្រាប់អនុវត្តន៍ក្នុងខេត្តគោលដៅចំនួន៦ រួមមានខេត្តបន្ទាយមានជ័យ កំពង់ចាម កំពង់ធំ កណ្តាល សៀមរាប និងខេត្តត្បូងឃ្មុំ ហើយចំនួនគោលដៅគ្រួសារក្រីក្រមានបណ្ណសមធម៌ គ្រោងទទួលផលក្រោមកម្មវិធីនេះមានចំនួន ១០.០០០ គ្រួសារ។

# ផែនការអភិវឌ្ឍន៍វិស័យថាមពលអគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជា

*ផែនការសម្រាប់វិស័យថាមពលអគ្គិសនី ត្រូវបានយកចិត្តទុកដាក់ ជាវិស័យអាទិភាពក្នុងការ សម្របខ្លួនទៅនឹងកំណើននៃការប្រើប្រាស់ថាមពល យ៉ាងឆាប់រហ័សនាពេលអនាគត។*





## ១ គោលនយោបាយអភិវឌ្ឍន៍វិស័យថាមពល

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវគោលនយោបាយអភិវឌ្ឍន៍វិស័យថាមពលអគ្គិសនីនៅ ខែតុលា ឆ្នាំ១៩៩៤ ដែលមានទិសដៅដូចខាងក្រោម៖

- ផ្តល់នូវការផ្គត់ផ្គង់ថាមពលអគ្គិសនីឲ្យបានគ្រប់គ្រាន់ទូទាំងប្រទេសកម្ពុជា ក្នុងតម្លៃសមរម្យ។
- ធានានូវការផ្គត់ផ្គង់ថាមពលអគ្គិសនីឲ្យមាននិរន្តរភាព និងសុវត្ថិភាព ដែលធ្វើឲ្យមានភាពងាយស្រួលដល់ការវិនិយោគក្នុងប្រទេសកម្ពុជា និងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។
- ជួយជំរុញនូវបេកគំហើញថ្មីៗ និងការអភិវឌ្ឍន៍នៃប្រភពផលិតថាមពលដែលមិនប៉ះពាល់ដល់បរិស្ថាន និងសង្គម ដែលជាតម្រូវការចាំបាច់សម្រាប់ផ្គត់ផ្គង់ថាមពលដល់គ្រប់វិស័យទាំងអស់នៃសេដ្ឋកិច្ចជាតិ។
- លើកទឹកចិត្តនូវការប្រើប្រាស់ថាមពលអគ្គិសនីឲ្យមានប្រសិទ្ធភាព និងកាត់បន្ថយផលប៉ះពាល់បរិស្ថាននូវកម្រិតអប្បបរមាពីប្រភពផ្គត់ផ្គង់ និងការប្រើប្រាស់ ។

## ២ ការព្យាករណ៍តម្រូវការថាមពល

ដោយផ្អែកទៅលើឯកសារស្តីពីផែនការមេ នៃការអភិវឌ្ឍន៍វិស័យថាមពលអគ្គិសនី នៅព្រះរាជាណាចក្រកម្ពុជា ដែលបានរៀបចំឡើងនៅឆ្នាំ ២០១៥ បានកត់សម្គាល់ថា តម្រូវការថាមពលអគ្គិសនី នឹងមានកំណើនដ៏គួរឲ្យកត់សម្គាល់មួយក្នុងរយៈពេល ១៥ ឆ្នាំខាងមុខនេះ។ តម្រូវការសម្រាប់ផលិតថាមពលនៅព្រះរាជាណាចក្រកម្ពុជា នឹងមានកំណើនពី ២.២៤២ GWh និង ៤០៩ MW នៅឆ្នាំ ២០១០ ទៅ ១៤.៩៥១ GWh និង ២.៦៧៨ MW នៅឆ្នាំ ២០២៥។ ដើម្បីបំពេញតម្រូវការនាពេលអនាគត រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតផែនការអភិវឌ្ឍន៍ថាមពលរហូតដល់ឆ្នាំ២០៣០ ។

មួយភាគធំនៃកំណើនតម្រូវការប្រើប្រាស់ថាមពលស្ថិតនៅភាគខាងត្បូងនៃប្រទេស ដែលរួមបញ្ចូលទាំងរាជធានីភ្នំពេញផងដែរ ។ តារាងខាងក្រោមពណ៌នាពីការព្យាករណ៍អានុភាពអតិបរមា និងថាមពលបញ្ចេញ សម្រាប់ព្រះរាជាណាចក្រកម្ពុជា។

**តារាងទី ១២ : ការព្យាករណ៍តម្រូវការថាមពលអគ្គិសនី នៅព្រះរាជាណាចក្រកម្ពុជា**

| ករណីមូលដ្ឋាន | ខ្នាត | ២០១៧ | ២០២០ | ២០២៥ |
|---|---|---|---|---|
| អានុភាពអតិបរមាក្នុងបណ្តាញជាតិ (MW) | MW | ១.៣៥៦ * | ១.៦៨១ | ២.៦៧៨ |
| អានុភាពអតិបរមាក្នុងប្រទេស (MW) | MW | ១.៥៣០ | | |
| ថាមពលក្នុងបណ្តាញជាតិ (GWh) | GWh | ៧.៥៨៦ * | ៩.៤០៦ | ១៤.៩៥១ |
| ថាមពលក្នុងប្រទេស (GWh) | GWh | ៨.៥៦៦ * * | | |

* ថាមពល និងអានុភាពអតិបរមាក្នុងបណ្តាញជាតិ គឺជាទិន្នន័យជាក់ស្តែងក្នុងឆ្នាំ ២០១៧។
* * ថាមពលក្នុងប្រទេស គឺជាទិន្នន័យរបស់អាជ្ញាធរអគ្គិសនីកម្ពុជា។

## ៣ ផែនការមេនៃការផលិតថាមពល

ផែនការមេនៃការផលិតថាមពល ត្រូវបានអភិវឌ្ឍដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោម ៖

- ការផលិតថាមពលដើរដោយរោងចក្រអគ្គិសនីដែលមានស្រាប់ សម្រាប់ប្រព័ន្ធភ្នំពេញនៅពេលបន្ទុក អតិបរមា។
- ប្រើប្រាស់ម៉ាស៊ីនឌីយ៉េស៊ែលធុនតូច និងមធ្យម ដើម្បីជួយក្នុងការផលិតថាមពល សម្រាប់ចែករំលែកក្នុងបន្ទុកធម្មតា និងមានបន្ទុកអតិបរមានៅតាមបណ្តាខេត្ត-ក្រុង (សម្រាប់រយៈពេលខ្លី)។
- ពង្រីកការអភិវឌ្ឍន៍ផ្នែកវារីអគ្គិសនី ដោយមូលដ្ឋាននៃការអភិវឌ្ឍន៍លើរោងចក្រវារីអគ្គិសនីធុនតូច ដែល មានភាពងាយស្រួលក្នុងការចូលអភិវឌ្ឍដូចជាៈ រោងចក្រវារីអគ្គិសនីគិរីរម្យ១ និង ៣ និងគម្រោងរោងចក្រវារីអគ្គិសនីធុនមធ្យម និងធំ ជាបន្តបន្ទាប់ដូចជាៈ រោងចក្រវារីអគ្គិសនីសេសានក្រោម២ រោងចក្រវារីអគ្គិសនីបាត់ដំបង រោងចក្រវារីអគ្គិសនីស្រែពកក្រោម២ ។

## តារាងទី ១៣ : ផែនការអភិវឌ្ឍន៍ផ្នែកផលិតកម្មសម្រាប់ឆ្នាំ ២០១៨ - ២០២៥

| ល.រ | ឈ្មោះគម្រោង | ប្រភេទ | អានុភាព (MW) | ឆ្នាំដំណើរការ |
|---|---|---|---|---|
| ១ | រោងចក្រវារីអគ្គិសនីសេសានក្រោម២(ម៉ាស៊ីនទី២-ម៉ាស៊ីនទី៨) | វារីអគ្គិសនី | ៣៥០ | ២០១៨ |
| ២ | រោងចក្រអគ្គិសនីដុតធ្យូងថ្ម CEL II | ធ្យូងថ្ម | ១៣៥ | ២០១៩ |
| ៣ | រោងចក្រអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ | ពន្លឺព្រះអាទិត្យ | ៦០ | ២០២០ |
| ៤ | រោងចក្រអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ | ពន្លឺព្រះអាទិត្យ | ៦០ | |
| ៥ | រោងចក្រអគ្គិសនីដុតធ្យូងថ្ម CIIDG | ធ្យូងថ្ម | ៣៥០ | ២០២៣ |
| ៦ | រោងចក្រវារីអគ្គិសនីស្ទឹងពោធិ៍សាត់១ | វារីអគ្គិសនី | ៨០ | |
| ៧ | រោងចក្រអគ្គិសនីដុតធ្យូងថ្ម CIIDG | ធ្យូងថ្ម | ៣៥០ | ២០២៤ |
| ៨ | រោងចក្រវារីអគ្គិសនីសេសានក្រោម៣ | វារីអគ្គិសនី | ២៦០ | ២០២៥ |
| ៩ | រោងចក្រអគ្គិសនីដុតធ្យូងថ្មទី១ | ធ្យូងថ្ម | ២០០ | ២០២៧ |
| ១០ | រោងចក្រអគ្គិសនីដុតធ្យូងថ្មទី២ | ធ្យូងថ្ម | ៣៥០ | ២០២៨ |
| ១១ | រោងចក្រអគ្គិសនីដុតធ្យូងថ្មទី៣ | ធ្យូងថ្ម | ៣៥០ | ២០២៩ |
| ១២ | រោងចក្រអគ្គិសនីដុតធ្យូងថ្មទី៤ | ធ្យូងថ្ម | ៣៥០ | ២០៣០ |
| សរុប | | | ២.៨៩៥ MW | |

## តារាងទី ១៤ : ផែនការមេនៃប្រព័ន្ធខ្សែបញ្ជូន 115kV

| ល.រ | ខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ១១៥ KV | ប្រវែងខ្សែ | ឆ្នាំដំណើរការ | ដៃគូអភិវឌ្ឍន៍ |
|---|---|---|---|---|
| ១ | អនុស្ថានីយទី២ - អនុស្ថានីយ សួនច្បារសម្ដេច ហ៊ុន សែន | ៥ | ២០១៩ | សាងសង់ ផ្ទេរ (BT) |
| ២ | អនុស្ថានីយរតនៈមណ្ឌល - អនុស្ថានីយប៉ៃលិន | ៤៥ | | អគ្គិសនីកម្ពុជា |
| ៣ | អនុស្ថានីយទី៣ - អនុស្ថានីយទួលគោក | ៥ | | អគ្គិសនីកម្ពុជា |
| ៤ | អនុស្ថានីយទី៥ - អនុស្ថានីយជ្រោយចង្វារ | ១៨ | | សល់ពីគម្រោងជុំវិញរាជធានីភ្នំពេញ(ធនាគារចិន) |
| ៥ | អនុស្ថានីយកំពង់ចាម - អនុស្ថានីយព្រែកប្រសប់(ក្រចេះ) | ៩១ | | ទីភ្នាក់ងារ អភិវឌ្ឍន៍បារាំង |
| ៦ | អនុស្ថានីយស្វាយអន្ទរ - អនុស្ថានីយកំពង់សឹង្គ | ៤៦ | | ធនាគារចិនអាហរ័ណនីហរ័ណ |
| ៧ | អនុស្ថានីយខេត្តព្រះសីហនុ - អនុស្ថានីយរាម | ១២ | | ធនាគារចិនអាហរ័ណនីហរ័ណ |
| ៨ | អនុស្ថានីយរាម - អនុស្ថានីយចំការលួង | ៦០ | | ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង |
| ៩ | អនុស្ថានីយកំពង់ធំ - អនុស្ថានីយព្រះវិហារ | ១៤០ | | ធនាគារចិនអាហរ័ណនីហរ័ណ |
| ១០ | អនុស្ថានីយព្រែកប្រសប់ - អនុស្ថានីយក្រចេះ | ៣០ | ២០២១ | ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង |
| ១១ | ខ្សែបញ្ជូនកប់ដីពីអនុស្ថានីយទី១ - អគ្គិសនីកម្ពុជា(វត្តភ្នំ) - សួនច្បារ សម្ដេច ហ៊ុន សែន - អនុស្ថានីយអូឡាំពិក - អង្គភាពមជ្ឈមណ្ឌលជាតិបញ្ជូន - អនុស្ថានីយទី៣ | ១៤ | ២០២០ | JICA ជំហានទី១ |
| ១២ | អនុស្ថានីយក្រឡាញ់ - អនុស្ថានីយឧត្តរមានជ័យ | ៨០ | ២០២២ | BOT |
| ១៣ | អនុស្ថានីយចំការលួង - រោងចក្រវារីអគ្គិសនីគិរីរម្យ៣ | ៣០ | ២០២៤ | ធនាគារចិនអាហរ័ណនីហរ័ណ |
| ១៤ | អនុស្ថានីយកំពត - អនុស្ថានីយជីបម៉ុង | ៤៦ | | ធនាគារចិនអាហរ័ណនីហរ័ណ |
| ១៥ | អនុស្ថានីយច្រកម្ទេស - អនុស្ថានីយពញាក្រែក | ៧៥ | ២០២៥ | ធនាគារចិនអាហរ័ណនីហរ័ណ |
| ១៦ | អនុស្ថានីយសួង - អនុស្ថានីយពញាក្រែក | ៤៥ | | ធនាគារឥណ្ឌា អាហរ័ណនីហរ័ណ |
| ១៧ | អនុស្ថានីយទី៧ - អនុស្ថានីយកោះធំ | ៤០ | | ធនាគារចិនអាហរ័ណនីហរ័ណ |
| ១៨ | អនុស្ថានីយតាកែវ - អនុស្ថានីយកោះធំ | ៤៥ | | ធនាគារចិនអាហរ័ណនីហរ័ណ |
| ប្រវែងខ្សែសរុប | | ៨២៧ km | | |

## តារាងទី ១៥ : ផែនការមេនៃប្រព័ន្ធខ្សែបញ្ជូន 230kV សម្រាប់ឆ្នាំ ២០១៨ - ២០២៥

| ល.រ | ខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ២៣០ | ប្រវែងខ្សែ | ឆ្នាំដំណើរការ | ដៃគូអភិវឌ្ឍន៍ |
|---|---|---|---|---|
| ១ | អនុស្ថានីយបាត់ដំបង - សៀមរាប - កំពង់ធំ - កំពង់ចាម | ៣៥០ | ២០១៩ | ធនាគារចិនអាហារណ៍នីហារណ៍ |
| ២ | ជុំវិញរាជធានីភ្នំពេញដំណាក់កាលទី២ (ខាងជើង - ជ្រោយចង្វារ - ខាងកើត - ខាងជើង) | ៩៦ | ២០១៩ | ធនាគារចិនអាហារណ៍នីហារណ៍ |
| ៣ | រោងចក្រវារីអគ្គិសនីតាតៃ - ភ្នំពេញ | ១៨២ | ២០១៩ | BOT |
| ៤ | អនុស្ថានីយកោះកុង - អនុស្ថានីយក្រុងកោះកុង | ២០ | ២០១៩ | ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង |
| ៥ | អនុស្ថានីយចំការល្ហុង - អនុស្ថានីយបុទុមសាគរ | ៥៤ | ២០១៩ | ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង |
| ៦ | អនុស្ថានីយបុទុមសាគរ - រោងចក្រវារីអគ្គិសនីតាតៃ | ៧០ | ២០១៩ | BOT |
| ៧ | អនុស្ថានីយក្រចេះ - អនុស្ថានីមណ្ឌលគិរី | ១៧០ | ២០១៩ | ធនាគារចិនអាហារណ៍នីហារណ៍ |
| ៨ | អនុស្ថានីយរតនគិរី - អនុស្ថានីយស្ទឹងត្រែង | ១២០ | ២០១៩ | ធនាគារចិនអាហារណ៍នីហារណ៍ |
| ៩ | អនុស្ថានីយបែកចាន - អនុស្ថានីយទី៥ - អង្គភាពមជ្ឈមណ្ឌល ជាតិបញ្ជូន | ២០ | ២០២១ | JICA ដំណាក់ទី២ |
| ១០ | អនុស្ថានីយទី៤ - អនុស្ថានីយកំពង់ស្ពឺថ្មី - អនុស្ថានីយកំពង់ស្ពឺ | ៤៨ | ២០២១ | ធនាគារចិនអាហារណ៍នីហារណ៍ |
| ១១ | អនុស្ថានីយស្ទឹងហាវ - អនុស្ថានីយអូរត្រេះ | ១៦ | ២០២១ | អគ្គិសនីកម្ពុជា |
| ១២ | អនុស្ថានីយសួង - អនុស្ថានីយស្វាយអន្ទរ | ៤៥ | ២០២១ | ធនាគារចិនអាហារណ៍នីហារណ៍ |
| ១៣ | អនុស្ថានីយទំនើបទី២ - អនុស្ថានីយព្រែកហូរ | ១៥ | ២០២១ | ធនាគារចិនអាហារណ៍នីហារណ៍ |
| ១៤ | អនុស្ថានីយទំនើបទី៥ - អនុស្ថានីយសែនសុខ | ៦ | ២០២២ | អគ្គិសនីកម្ពុជា |
| ១៥ | អនុស្ថានីយស្ទឹងត្រែង - អនុស្ថានីយខាងជើងសៀមរាប | ២០០ | ២០២៥ | ធនាគារចិនអាហារណ៍នីហារណ៍ |
| ១៦ | អនុស្ថានីយខាងជើងសៀមរាប - អនុស្ថានីយខាងកើតសៀមរាប | ៤៤ | ២០២៥ | ធនាគារចិនអាហារណ៍នីហារណ៍ |
| **ប្រវែងខ្សែសរុប** | | **១.៤៥៦** km | | |

## តារាងទី ១៦ : ផែនការមេនៃប្រព័ន្ធខ្សែបញ្ជូន ៥០០kV សម្រាប់ឆ្នាំ ២០១៨ - ២០២៥

| ល.រ | ខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ៥០០KV | ប្រវែងខ្សែ | ឆ្នាំដំណើរការ | ដៃគូអភិវឌ្ឍន៍ |
|---|---|---|---|---|
| ១ | អនុស្ថានីយចំការល្ហុង - អនុស្ថានីយបែកចាន | ១៩៨ | ២០១៩ | BOT |
| ២ | អនុស្ថានីយស្ទឹងត្រែង - ព្រំប្រទល់ឡាវ | ៥៥ | ២០២១ | ធនាគារចិនអាហារណ៍នីហារណ៍ |
| ៣ | អនុស្ថានីយបែកចាន - អនុស្ថានីយខាងកើតភ្នំពេញ | ៤៥ | ២០២១ | ធនាគារចិនអាហារណ៍នីហារណ៍ |
| ៤ | អនុស្ថានីយខាងកើតភ្នំពេញ - អនុស្ថានីយសួង | ៩០ | ២០២២ | ធនាគារចិនអាហារណ៍នីហារណ៍ |
| **ប្រវែងខ្សែសរុប** | | **៣៨៨** km | | |







200000
300000
400000
500000
1600000
1500000
1400000
1300000
1200000
Laos
Thailand
GS_ODMC
ឧត្តរមានជ័យ
ព្រះវិហារ
បន្ទាយមានជ័យ
GS_IE Border S/S
GS BTC
សៀមរាប
GS SRP
E SRP S/S
BTB
GS BTB(CPTL) S/S
បាត់ដំបង
ប៉ៃលិន
Pailin S/S
Ratanak Mondul S/S
កំពង់ធំ
KPT S/S
Krokor 60MW
GS_Krokor
GS_Chethom
ពោធិ៍សាត់
កំពង់ឆ្នាំង
KGN 60MW
KGN S/S
O Som S/S
ADB 60MW
GS_KK City
កោះកុង
GS KPS
កំពង់ចាម
WPP
SRP
GS_Samrong
TKO S/S
តាកែវ
កំពត
ព្រះសីហនុ
GS_SHV
KPT S/S
BTC S/S
GS_CMIC
GS_KCC
កែប
Chau Doc


600000
700000
800000
1600000
1500000
1400000
1300000
1200000
N
W
E
S
0 5 10 20 30 40 Kilometer
Legend
Grid Substation 115kV
Grid Substation 230kV
Solar Park
ExSbBa¢Ún 115K>v
In service
In service
Under_Construction
Under_Construction
Under_Study
Under_Study
In service and Under Study
Under Construction and Study
ExSbBa¢Ún 230 K>v
ExSbBa¢Ún 500 K>v
RTK S/S
KTE S/S
GS_Preak Prasab
Suong S/S
Memot S/S
Chrak Mtes S/S
Thaig Seng 10MW
SunSeap 10MW
Vietnam
1:2,000,000

## ១ ការភ្ជាប់បណ្តាញអគ្គិសនីជាមួយប្រទេសថៃឡង់ដ៏

កិច្ចព្រមព្រៀងសហប្រតិបត្តិការថាមពលជាមួយប្រទេសថៃឡង់ដ៏ ត្រូវបានចុះហត្ថលេខានៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០០។ កិច្ចព្រមព្រៀងនេះ បានផ្តល់នូវក្របខណ្ឌការងារសម្រាប់ការធ្វើពាណិជ្ជកម្មថាមពល និងជំនួយបច្ចេកទេសរវាងប្រទេសទាំងពីរនេះ និងបើកឲ្យថាមពលអគ្គិសនីចូលទៅប្រទេសទីបី។ កិច្ចព្រមព្រៀងទិញ-លក់ថាមពល បានចុះហត្ថលេខានៅឆ្នាំ ២០០២ និងបានកែសម្រួលនៅឆ្នាំ២០០៧ ។ កិច្ចព្រមព្រៀងនេះ បានជំរុញឲ្យប្រើប្រាស់រួមគ្នា នូវធនធានធម្មជាតិដែលមានស្រាប់របស់ប្រទេសទាំងពីរ។ នៅពេលដែលប្រភពបញ្ចូលគ្នានឹងត្រូវបង្កើតឡើងប្រទេសទាំងពីរ អាចចូលរួមដោយទូលាយលើការផ្គត់ផ្គង់ថាមពល និងការទទួលថាមពល ។

ខ្សែបញ្ជូន ១១៥ kV ចេញពីអនុស្ថានីយអារញ្ញប្រាថេត ប្រទេសថៃឡង់ដ៏ ភ្ជាប់ទៅខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង និងខេត្តសៀមរាប បានដាក់ឲ្យដំណើរការក្នុងឆ្នាំ ២០០៧។ ថាមពលអគ្គិសនីរវាងប្រទេសកម្ពុជា និងប្រទេសថៃឡង់ដ៏ត្រូវបានបញ្ជូនដោយតង់ស្យុង ២២ kV និង ១១៥ kV ។ កិច្ចព្រមព្រៀងមួយ បានចុះហត្ថលេខាជាមួយខេត្តត្រាតនៃប្រទេសថៃឡង់ដ៏ ដើម្បីផ្គត់ផ្គង់ថាមពលឲ្យខេត្តកោះកុង និងក្រុងប៉ោយប៉ែត នៃប្រទេសកម្ពុជាដោយប្រើបណ្តាញ ២២ kV ។ តំបន់ខាងលើបានភ្ជាប់ថាមពលតាំងពីឆ្នាំ ២០០១ ។

## ២ ការភ្ជាប់បណ្តាញអគ្គិសនីជាមួយប្រទេសឡាវ

កិច្ចសហប្រតិបត្តិការថាមពល ជាមួយប្រទេសឡាវ ត្រូវបានចុះហត្ថលេខានៅថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៩៩។ កិច្ចព្រមព្រៀងនេះមានគោលបំណងសហប្រតិបត្តិការ ក្នុងវិស័យថាមពលរវាងប្រទេសទាំងពីរ។ ការផ្គត់ផ្គង់ថាមពលដល់តំបន់តាមបណ្តោយព្រំដែនដោយបណ្តាញតង់ស្យុងមធ្យម ២២ kV និងការតភ្ជាប់បណ្តាញជាមួយបណ្តាញតង់ស្យុងខ្ពស់ ត្រូវបានជំរុញ ។ការតភ្ជាប់បណ្តាញតង់ស្យុង ២២ kV ពីខេត្តចម្ប៉ាសាក់ ប្រទេសឡាវ មកខេត្តស្ទឹងត្រែង ត្រូវបានដាក់ឲ្យដំណើរការនៅឆ្នាំ២០១០។ នៅឆ្នាំ២០១៥ ខ្សែបញ្ជូនតភ្ជាប់ថ្មីពីអនុស្ថានីយបានហាត ខេត្តចម្ប៉ាសាក់ ប្រទេសឡាវ ទៅស្រុកកំពង់ស្រឡៅ ខេត្តព្រះវិហារ ប្រទេសកម្ពុជា ត្រូវបានរៀបចំ និងសាងសង់សម្រាប់ខ្សែបញ្ជូនតង់ស្យុង ១១៥kV ប៉ុន្តែបញ្ជូនថាមពលអគ្គិសនីនៅកម្រិតតង់ស្យុង ២២ kV សម្រាប់ដំណាក់កាលដំបូង ហេតុដល់ខ្សែបញ្ជូនពីព្រំប្រទល់ឡាវ ទៅអនុស្ថានីយជ័យសែន សាងសង់រួចរាល់។



## ៣ ការភ្ជាប់បណ្តាញអគ្គិសនីជាមួយប្រទេសវៀតណាម

កិច្ចសហប្រតិបត្តិការថាមពលជាមួយប្រទេសវៀតណាម បានចុះហត្ថលេខានៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៩។ កិច្ចព្រមព្រៀងនេះ មានបំណងសហប្រតិបត្តិការក្នុងវិស័យថាមពល រវាងប្រទេសទាំងពីរ។ ការផ្គត់ផ្គង់ថាមពលឲ្យតំបន់តាមបណ្តោយព្រំដែន ដោយខ្សែបណ្តាញតង់ស្យុងមធ្យម និងការតភ្ជាប់ទៅវិញទៅមករវាងខ្សែបញ្ជូនតង់ស្យុងខ្ពស់ត្រូវបានជំរុញ។

អគ្គិសនីកម្ពុជាបាននាំចូលថាមពលពីប្រទេសវៀតណាមតាមខ្សែបញ្ជូន ២៣០ kV ផ្គត់ផ្គង់នៅភ្នំជិនក្នុងខេត្តតាកែវ ក្នុងឆ្នាំ២០០៩។ អគ្គិសនីកម្ពុជាបានភ្ជាប់ខ្សែបញ្ជូន ២៣០ kV សម្រាប់នាំចូលថាមពលពីប្រទេសវៀតណាម មកភ្នំពេញនិងបានដាក់ឲ្យដំណើរការនៅខែមីនា ឆ្នាំ២០០៩ ។ អគ្គិសនីកម្ពុជា បាននាំថាមពលពី PC2 ដើម្បីផ្គត់ផ្គង់នៅស្រុកមេមត់ និងស្រុកពញាក្រែក ខេត្តកំពង់ចាម បាវិត នៅខេត្តស្វាយរៀង កំពង់ត្រាច នៅខេត្តកំពត កោះធំ និងជ្រៃធំនៅខេត្តកណ្តាល ស្រុកស្នួលនៅខេត្តក្រចេះ ស្រុកកែវសីមា នៅខេត្តមណ្ឌលគិរី ស្រុកកំពង់រោទិ៍ នៅខេត្តស្វាយរៀងនៅឆ្នាំ២០០២។

## ៤ ការតភ្ជាប់បណ្តាញអនុតំបន់

ការសិក្សាតភ្ជាប់រវាងបណ្តាញ ដែលនៅដាច់ដោយឡែកពីប្រទេសមួយទៅប្រទេសមួយនៅក្នុងអនុតំបន់អាងទន្លេមេគង្គ (កម្ពុជា ឡាវ ថៃឡង់ដ៏ វៀតណាម យូណាន - ប្រទេសចិន និងប្រទេសភូមា) និងសូម្បីតែបណ្តាញប្រទេសម៉ាឡេស៊ី និងសឹង្ហបុរីក៏ត្រូវបានយកមកធ្វើការសិក្សាផងដែរ ដោយមានគោលបំណងធ្វើឲ្យប្រសើរឡើងនូវការប្រើប្រាស់ប្រភពថាមពល។ របាយការណ៍ស្តីពីផែនការមេ នៃការតភ្ជាប់បណ្តាញរបស់អាស៊ានត្រូវបានសិក្សាបញ្ចប់នៅឆ្នាំ ២០០២ ដែលបង្ហាញពីការសិក្សាមួយយ៉ាងច្បាស់ ស្តីពីការតភ្ជាប់បណ្តាញរបស់អាស៊ាន។ បច្ចុប្បន្នមានការពិនិត្យឡើងវិញ អំពីផែនការមេនៃការតភ្ជាប់បណ្តាញរបស់អាស៊ាននេះ ដោយក្រុមសិក្សានៃបណ្តាប្រទេសអាស៊ាន។

ការសិក្សាផ្តល់ភាគច្រើន លើការវាយតម្លៃលើអាទិភាព និងលទ្ធភាពជោគជ័យនៃការតភ្ជាប់ខ្សែបណ្តាញទៅវិញទៅមកនៅក្នុងតំបន់ ដោយផ្អែកលើការសិក្សាបុរេសមិទ្ធលទ្ធភាព។ ការសិក្សាបានស្នើឲ្យមានការអភិវឌ្ឍន៍បណ្តាញថាមពលអាស៊ាន (APG) ដោយបានបង្កើតគណៈកម្មាធិការទីប្រឹក្សាបណ្តាញថាមពលអាស៊ាន។ យ៉ាងណា ក៏ដោយ ក្នុងចំណោមការសិក្សាតភ្ជាប់បណ្តាញចំនួន ១០ របស់អាស៊ាន ការតភ្ជាប់បណ្តាញរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម ជាប់លំដាប់ទី៤ និងបានចាត់ថ្នាក់ថាជាគម្រោង ដែលមានសក្តានុពលពីរយៈពេលខ្លីទៅរយៈពេលមធ្យម ដែលគួរបញ្ចប់គម្រោងនេះមុនឆ្នាំ២០១០ ។



# ទំនួលខុសត្រូវរបស់អគ្គិសនីកម្ពុជាចំពោះសង្គម

ក្រៅពីការប្រកបសកម្មភាពអាជីវកម្មស្នូល អគ្គិសនីកម្ពុជា បានចូលរួមចំណែកក្នុងការងារសង្គម មនុស្សធម៌ បណ្តុះបណ្តាលធនធានមនុស្ស និងការការពារបរិស្ថានជាច្រើនតាមរយៈការផ្តល់ជាសម្ភារ ថវិកា និងការចូលរួមជាសកម្មភាពផ្សេងៗដូចខាងក្រោម៖

## ១-ការចុះជួយឧបត្ថម្ភកងទ័ព



អគ្គិសនីកម្ពុជា បានចុះអនុស្សរណៈជាមួយកងពលតូចថ្មើរជើងលេខ៤២ និងនគរបាលវរៈសេនាតូចលេខ៧០២ កងទ័ពនៃកងពលតូចអន្តរាគមន៍លេខ១៤ ចាប់តាំងពីឆ្នាំ២០០៥មក។ ប៉ុន្តែចាប់ពីឆ្នាំ២០១០ ជារៀងរាល់២ខែម្តង ថ្នាក់ដឹកនាំអគ្គិសនីកម្ពុជារួមទាំងសហការី តែងតែចុះសួរសុខទុក្ខកងទ័ពដែលបានលះបង់កំលាំងកាយចិត្តការពារបូរណភាពទឹកដីនៅប្រកព្រំដែន ដោយពាំនាំជាមួយនូវសម្ភារប្រើប្រាស់ផ្សេងៗ ក្នុងនោះដែររួមមានផ្ទាំងសូឡាសម្រាប់ផលិតថាមពលអគ្គិសនី ស្បៀងអាហារ រួមទាំងរៀបចំពិធីជប់លៀង អមជាមួយថវិកាមួយចំនួនផងដែរក្នុងការសាងសង់លេណដ្ឋាន និងផ្ទះជូនកងទ័ព។



## ២-ការងារមនុស្សធម៌

ដើម្បីចូលរួមចំណែកក្នុងការជួយដល់ប្រជាជនក្រីក្រជួបទុក្ខលំបាកនានាអគ្គិសនីកម្ពុជា បានឧបត្ថម្ភថវិកាដល់កាកបាទក្រហមកម្ពុជាស្នាក់ការកណ្តាល និងតាមបណ្តាខេត្តជារៀងរាល់ឆ្នាំ។ បន្ថែមពីនេះ ក្នុងឆ្នាំ២០១៧ អគ្គិសនីកម្ពុជាបានចុះជួយប្រជាពលរដ្ឋ ដែលរងគ្រោះដោយទឹកជំនន់នៅខេត្តក្រចេះ ដោយបានពាំនាំនូវស្បៀងអាហារ និងសម្ភារចាំបាច់មួយចំនួន និងបានចូលរួមឧបត្ថម្ភថវិកាសម្រាប់ការសាងសង់ផ្សារ ដែលត្រូវឆាបឆេះដោយអគ្គីភ័យនៅខេត្តស្ទឹងត្រែងផងដែរ។ ជំនួយទាំងនេះជាជំនួយសម្រាប់ការសង្គ្រោះបន្ទាន់ទៅកាន់ក្រុមជនងាយរងគ្រោះ។ លើសពីនេះ អគ្គិសនីកម្ពុជាបានចូលរួមចំណែកសាងសង់ផ្លូវថ្នល់ដើម្បីជួយសម្រួលដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋនៅតាមទីជនបទទៀតផង។



ចាប់តាំងពីឆ្នាំ២០១៦មក អគ្គិសនីកម្ពុជាបាននាំយកថវិកាឧបត្ថម្ភដល់មន្ទីរពេទ្យគន្ធបុប្ផា ដែលជាទឹកចិត្តបរិសុទ្ធរបស់និយោជិតអគ្គិសនីកម្ពុជា ដើម្បីសង្គ្រោះកុមារកម្ពុជា និងថវិកាមួយចំណែកតូចជាថវិការបស់អតិថិជនអគ្គិសនីកម្ពុជាផងដែរ។ក្នុងឆ្នាំ២០១៧ អគ្គិសនីកម្ពុជា ឧបត្ថម្ភថវិកាសរុបចំនួន ៣២,៥៥០ ដុល្លារអាមេរិកផងដែរ។

## ៣-ការចូលរួមលើកកម្ពស់វិស័យអប់រំ និងបណ្តុះបណ្តាលធនធានមនុស្ស

អគ្គិសនីកម្ពុជា យកចិត្តទុកដាក់លើការចូលរួមចំណែកអភិវឌ្ឍន៍វិស័យធនធានមនុស្សនៅកម្ពុជា ជាពិសេសយុវជន ដែលជាសសរទ្រូងរបស់ប្រទេសជាតិ។ ជាក់ស្តែង ក្នុងឆ្នាំ២០១៧នេះ អគ្គិសនីកម្ពុជា បានចុះអនុស្សរណៈជាមួយសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដើម្បីផ្តល់អាហារូបករណ៍ដល់សិស្សនិស្សិត ដែលមានជីវភាពលំបាក ដើម្បីមានលទ្ធភាពចូលរៀនថ្នាក់ឧត្តមសិក្សាបន្តលើជំនាញជាច្រើន ដែលជំនាញទាំងនោះជាជំនាញសំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមជាតិ។លើសពីនេះសិស្សនិស្សិតរាប់រយនាក់នៅវិទ្យាស្ថានវិទ្យាសាស្ត្រអគ្គិសនី ក៏បានទទួលអាហារូបករណ៍ក្រោមការឧបត្ថម្ភរបស់អគ្គិសនីកម្ពុជា លើជំនាញអគ្គិសនីដែលជាតម្រូវការចាំបាច់ដើម្បី ចូលរួមចំណែកអភិវឌ្ឍន៍វិស័យអគ្គិសនីនាពេលបច្ចុប្បន្ន និងទៅអនាគត។ ជាមួយគ្នានេះដែរ អគ្គិសនីកម្ពុជា បានឧបត្ថម្ភថវិកាសម្រាប់បោះពុម្ពសៀវភៅភិរម្យអ៊ូហៅង៉ុយចំនួន ៦,០០០ ក្បាល និងកែសម្រួលកម្មវិធី




អេឡិចត្រូនិចវចនានុក្រមសម្តេចសង្ឃរាជជួនណាតដោយសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ជាងនេះទៅទៀត អគ្គិសនីកម្ពុជាតែងតែចូលរួមចែករំលែក និងផ្លាស់ប្តូរបទពិសោធន៍ការសិក្សា និងឧបត្ថម្ភថវិកាមួយចំនួនដល់យុវជន-យុវនារី ដែលនឹងត្រូវចូលរួមលើវេទិកាអន្តរជាតិផ្សេងៗផងដែរ។

## ៤-ការការពារបរិស្ថាន

អគ្គិសនីកម្ពុជាបានចូលរួមចំណែកក្នុងការថែរក្សាព្រៃឈើមិនអោយបាត់បង់ ដោយបានចូលរួមសហការជាមួយស្ថានីយ៍វិទ្យុ ABC ក្នុងការដាំកូនឈើរាប់រយដើមបន្ថែមនៅខេត្តពោធិ៍សាត់ក្នុងឆ្នាំ២០១៧។






**អគ្គិសនីកម្ពុជា**

អាគារលេខ២ ផ្លូវព្រះអង្គយុគន្ធរ(១៩) សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ

រាជធានីភ្នំពេញ ប្រទេសកម្ពុជា

ទូរស័ព្ទ : (+៨៥៥)២៣ ៧២៤ ៧៧១

អ៊ីម៉ែល : (+៨៥៥)២៣ ៤២៦ ០១៨

អ៊ីម៉ែល : info@edc.com.kh

គេហទំព័រ : www.edc.com.kh